ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពជាតិ

# ស្តីពី

# ការអភិវឌ្ឍយុវជនកម្ពុជា

# ២០១៦-២០១៨

បានទទួលការឯកភាពពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
ក្នុងកិច្ចប្រជុំលើកទី១ នាថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦

# មាតិកា


១- សារបាន ..... ១

១.១- គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា ..... ១

១.២- ស្ថានភាព ..... ១

១.៣- បញ្ហាអាទិភាព ..... ២

២- យុទ្ធសាស្ត្រ ..... ៣

២.១- វត្ថុបំណង ..... ៣

២.២- ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍយុវជនកម្ពុជា ..... ៣

២.២.១- គោលការណ៍នៃការរៀបចំផែនការសកម្មភាពជាតិ ..... ៤

២.២.២- យន្តការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា ..... ៤

២.២.២.១- ក្រសួង ស្ថាប័នថ្នាក់ជាតិ ..... ៥

ក- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) ..... ៥

ខ- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) ..... ៦

គ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ..... ៩

២.២.២.២- ស្ថាប័នថ្នាក់ក្រោមជាតិ ..... ១០

ក- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ..... ១០

ខ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ..... ១០

គ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់ ..... ១១

២.២.២.៣- ដៃគូអភិវឌ្ឍនិងសង្គមស៊ីវិល ..... ១១

៣- ផែនការសកម្មភាព ..... ១៣

ក- បរិយាយសង្ខេបអំពីវិសាលភាពផែនការសកម្មភាព ..... ១៣

៣.១- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី១ : អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ ..... ១៣

៣.១.១- សេវាកម្មព័ត៌មានយុវជនច្រកតែមួយ ..... ១៣

៣.១.២- ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ..... ១៤

៣.១.៣- ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ..... ១៤

៣.១.៤- ការសម្របសម្រួលជាមួយសង្គមស៊ីវិល ..... ១៥

៣.១.៥- ការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា ..... ១៦

៣.១.៦- ការតស៊ូមតិនៅក្នុងសភាជាតិ ក្រសួង ស្ថាប័ន និងថ្នាក់រាជធានី ខេត្ត ..... ១៦

៣.១.៧- ការស្រាវជ្រាវអំពីយុវជន ..... ១៧

៣.១.៨- ការពិនិត្យ កែសម្រួល និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារយុវជន ..... ១៨

៣.១.៩- ការអភិវឌ្ឍធនធានមនុស្ស ..... ១៨

៣.១.១០- ការកៀរគរធនធាន ........................................ ១៩

៣.២- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី២ : លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព ........................................ ២០

៣.២.១- សាលារៀនជាទីកន្លែងមូលដ្ឋានសម្រាប់រៀនសូត្រតាមរយៈការអប់រំមានគុណភាព ........ ២០

៣.២.២- យុវជនទទួលបាននូវគុណវុឌ្ឍិខ្ពស់ ........................................ ២១

៣.២.៣- ឱកាសទទួលបានការអប់រំលើកទីពីរ ........................................ ២២

៣.២.៤- ការអភិវឌ្ឍលទ្ធភាពទទួលបានការសិក្សាបន្តឬការសិក្សាពេញមួយជីវិត ............ ២៣

៣.២.៥- ការគាំទ្រយុវជននៅពេលពួកគេកំពុងឈានចូលពេញវ័យ ........................ ២៤

៣.២.៦- សម្ភារៈនិងមធ្យោបាយបម្រើឱ្យយុវជនក្នុងសហគមន៍ ........................ ២៤

៣.២.៧- ការពង្រីកកម្មវិធីអប់រំក្រោយមធ្យមសិក្សានិងមជ្ឈមណ្ឌលយុវជនសម្រាប់យុវជនក្រៅសាលា ជាពិសេស យុវជនពិការ ដើម្បីឱ្យពួកគេមានឱកាសបានចូលរួមយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ........................ ២៥

៣.២.៨- ប្រាក់កម្ចីសិក្សាសម្រាប់សិស្សនិងនិស្សិត ........................................ ២៦

៣.២.៩- ភាពជាតំណាងយុវជន ........................................ ២៧

៣.២.១០- ការលើកកម្ពស់បណ្តាញការងារនិងគំរូនៅក្នុងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ........ ២៨

៣.២.១១- ព័ត៌មានវិទ្យានិងការអប់រំពីចម្ងាយ ........................................ ២៩

៣.៣- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៣ : បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព ........................................ ២៩

៣.៣.១- ការប្រឹក្សាយោបល់ស្តីពីសុខភាពយុវជន ........................................ ២៩

៣.៣.២- ការយល់ដឹងរបស់យុវជនអំពីជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍ .......... ៣០

៣.៣.៣- ការគាំទ្រយុវតីមានគភ៌និងវត្តមានសិស្ស ........................................ ៣១

៣.៤- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៤ : បណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ .... ៣២

៣.៤.១- ការប្រឹក្សាយោបល់ស្តីពីមុខរបរនៅតាមសាលារៀន ........................................ ៣២

៣.៤.២- សេវាកម្មប្រឹក្សាយោបល់ស្តីពីមុខរបរសម្រាប់យុវជន ........................................ ៣៣

៣.៤.៣- ការបង្កើតការងារសម្រាប់យុវជន ........................................ ៣៤

៣.៤.៤- ការតស៊ូមតិនិងភាពជាតំណាងយុវជននៅក្នុងស្ថាប័នរដ្ឋបាលនានា ........................ ៣៥

៣.៤.៥- ការអប់រំយុវសហគ្រិនភាព ........................................ ៣៥

៣.៤.៦- ការផ្តួចផ្តើមការអភិវឌ្ឍយុវសហគ្រាសជាតិ ........................................ ៣៦

៣.៥- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៦ : បង្កើនការចូលរួមរបស់យុវជន ........................ ៣៧

៣.៥.១- ការពង្រឹងនិងពង្រីកក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន ........................ ៣៧

៣.៦- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី១០ : បង្កើនការងារស្ម័គ្រចិត្ត ........................ ៣៧

៣.៦.១- កម្មវិធីសេវាកម្មជាតិយុវជន ........................................ ៣៧

៣.៦.២- ការលើកកម្ពស់ការផ្តួចផ្តើមសហគមន៍ ........................................ ៣៨

៣.៦.៣- ការសម្របសម្រួលនិងការអភិវឌ្ឍអង្គភាពជាមួយការរីទ្ធិកម្ពុជា ........................ ៣៩

ខ- តារាងសង្ខេបសកម្មភាព ........................................ ៤១

៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ........................................ ៦១

៥- គម្រោងចំណាយ ........................................ ៦១

៦- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........................................ ៦២

៦.១- ការពិនិត្យផលប៉ះពាល់ ........................................ ៦២
៦.២- ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពជាតិ ........................................ ៦២
៦.៣- ការពិនិត្យតាមដានការអនុវត្តកម្មវិធីនិងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍយុវជនតាមវិស័យ ... ៦២
៦.៤- ការរៀបចំឯកសារឧបសម្ព័ន្ធផែនការសកម្មភាពជាតិ ........................................ ៦៣
៧- សេចក្តីសន្និដ្ឋាន ........................................ ៦៤

# បុព្វកថា



សូមស្វាគមន៍យុវជនកម្ពុជាទាំងអស់ !

ក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមក កម្ពុជាបានធ្វើឱ្យមានការប្រែប្រួលនិងអភិវឌ្ឍគួរឱ្យកត់សម្គាល់លើគ្រប់វិស័យ ជាពិសេស ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ ពីពេលនេះឆ្ពោះទៅសម្រេចចក្ខុវិស័យនៃការអភិវឌ្ឍប្រទេសឆ្នាំ២០៥០ កម្ពុជានឹងពឹងផ្អែកលើភាគលាភដែលខ្លួនមាន ជាពិសេស ការទាញយកសក្តានុពលនៃប្រជាសាស្ត្រវ័យក្មេង ដែលស្ថិតក្នុងប្រភេទប្រជាជនសកម្មប្រមាណ៣០ភាគរយនៃប្រជាជនសរុប។ ដូចនេះ កម្ពុជាត្រូវធានាឱ្យបាននូវការផលិតធនធានមនុស្សដែលមានគុណភាព និងមានសមត្ថភាពអាចឈានចូលទៅក្នុងទីផ្សារការងារនិងប្រកបដោយភាពប្រកួតប្រជែង។

ការអភិវឌ្ឍយុវជនជាអាទិភាពបន្ទាន់និងជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា រួមទាំងយុវជនខ្លួនឯងផ្ទាល់។ យុវជនមានកាតព្វកិច្ចចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន និងស្មើមុខស្មើមាត់នៅលើឆាកអន្តរជាតិ រួមទាំងការអភិវឌ្ឍកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាពនិងភាពសុខដុម ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និងលើកកម្ពស់ការយល់ដឹងទូលំទូលាយអំពីសង្គម។ យុវជនជាអ្នកទទួលផលដោយផ្ទាល់ពីការអភិវឌ្ឍនិងជាកម្លាំងចលករជំរុញការលូតលាស់នៅកម្ពុជាផងដែរ ដូច្នេះការចូលរួមពីសំណាក់យុវជនក្នុងការដោះស្រាយបញ្ហាសង្គម ការបង្កើនការយល់ដឹងពីតម្លៃការងាររបស់យុវជន ការទទួលស្គាល់ពីសក្តានុពល និងតួនាទីដ៏សំខាន់របស់យុវជន រួមទាំងការទទួលស្គាល់ពីបំណងប្រាថ្នា តម្រូវការ និងលក្ខខណ្ឌរបស់យុវជន គឺជាកត្តាគន្លឹះសម្រាប់កសាងប្រជាជាតិមួយដែលមានភាពរុងរឿងនិងពោរពេញដោយសន្តិភាព។

រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់លើការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពយុវជនទាំងក្នុងនិងក្រៅសាលារៀន ការអប់រំ ថែទាំ និងការផ្តល់ សេវា សុខភាពដល់យុវជន ការបណ្តុះស្មារតីសហគ្រិនភាពនិងការបង្កើតទីផ្សារការងារ ការបង្កើនការចូលរួមរបស់យុវជន លើគ្រប់រូបភាពនិងការបង្កើនការងារស្ម័គ្រចិត្តរបស់យុវជន។

រាជរដ្ឋាភិបាលបានតាក់តែងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដែលមានចក្ខុវិស័យ ប្រមូលផ្តុំកម្លាំងគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិ សំដៅរួមចំណែកអភិវឌ្ឍយុវជនឱ្យកាន់តែមានលក្ខណសម្បត្តិវិជ្ជមាននិងផ្តល់ឱកាសឱ្យពួកគេអភិវឌ្ឍសក្តានុពលក្នុងការអប់រំ ការងារ សុខភាព ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។ ដើម្បីអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលបានរៀបចំក្របខណ្ឌច្បាប់និងយន្តការ អនុវត្តនៅគ្រប់កម្រិត ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ ដែលគាំទ្រដោយផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។

ការអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានឹងសម្រេចទៅបាន គឺអាស្រ័យលើការបន្តសមិទ្ធកម្មដែលមានកន្លងមក ការបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធ

ផលនៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍យុវជន និងការបង្កើតឱកាសដល់យុវជន និងការអន្តរាគមន៍ថ្មីៗ សម្រាប់អភិវឌ្ឍយុវជន ជាពិសេស ការកៀរគរកម្លាំងគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងថ្នាក់ ដឹកនាំនយោបាយ ស្ថាប័នជាតិ ដៃគូអភិវឌ្ឍ គ្រួសារ និងយុវជន។

ខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងឡាយដែលបានខិតខំប្រឹងប្រែង រួមចំណែកតាមគ្រប់ទិដ្ឋភាព ដើម្បីជំរុញ ផ្សព្វផ្សាយ អនុវត្ត និងគាំទ្រគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជននិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឱ្យបានជោគជ័យ។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជននិងតំណាងឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំនឹងប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត កម្លាំងប្រាជ្ញាស្មារតី ដើម្បីរួមចំណែកអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។ រាជរដ្ឋាភិបាលសង្ឃឹមនិងជឿជាក់ថា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ គ្រួសារ បុគ្គលនឹងលះបង់ធនធានសរុប មធ្យោបាយសរុប និងធ្វើជាកម្លាំងសរុបក្នុងការធានាអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិនេះឱ្យបានជោគជ័យដូចការរំពឹងទុក។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ១. សារបាន

## ១.១. គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ត្រូវបានទទួលការឯកភាពជាផ្លូវការពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។ គោលនយោបាយនេះ ត្រូវបានរៀបចំឡើងក្រោមការដឹកនាំនិងសម្របសម្រួលដោយក្រសួងអប់រំ យុវជន និងកីឡា និងមាន កិច្ចសហការពេញលេញពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលនានា ដែលកំពុងបំពេញការងារពាក់ព័ន្ធនឹងយុវជន។ គោលនយោបាយជាតិបានកំណត់នូវយុទ្ធសាស្ត្រមួយចំនួនដើម្បីបំពេញការងារឱ្យស្របតាមវិស័យរបស់ខ្លួន។ ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាអាចសម្រេចទៅបានប្រកបដោយប្រសិទ្ធភាព លុះត្រាតែគ្រប់វិស័យនៃសង្គមទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍយុវជននិងតួនាទីយុវជនត្រូវបំពេញនៅក្នុងសង្គម។

ដើម្បីអនុវត្តគោលនយោបាយជាតិនេះ យន្តការមួយត្រូវបានបង្កើតឡើង **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន** ហៅកាត់ថា"**ក.ជ.យ.**" ដែលមានតួនាទីជាអ្នកសម្របសម្រួល តាមដាន វាយតម្លៃ និងជួយរាជរដ្ឋាភិបាលអំពីដំណើរការអភិវឌ្ឍយុវជនឱ្យមានប្រសិទ្ធភាព។ ការអនុវត្តការងាររបស់ **ក.ជ.យ.** នឹងស្ថិតក្រោមក្របខណ្ឌរបស់ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ២០១៦-២០១៨ ដែលជាមគ្គុទ្ទេសក៍សម្រាប់បង្ហាញផ្លូវដល់ប្រតិបត្តិការរបស់ខ្លួន ដោយផ្តោតលើយុវជន យេនឌ័រ សមាហរណកម្មការងារយុវជន បរិយាកាសនៃការផ្តល់សិទ្ធិអំណាច ការចូលរួមរបស់យុវជន ការឆ្លើយតបប្រសិទ្ធផល ប្រសិទ្ធភាព តម្លាភាព លទ្ធភាព និងភាពចម្រុះ។ ផែនការសកម្មភាពជាតិនេះ មានគោលបំណងធានាឱ្យយុវជនមានអាយុចន្លោះពី១៥ឆ្នាំដល់៣០ឆ្នាំ មានការអភិវឌ្ឍកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាពនិងភាពសុខដុម ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និង លើកកម្ពស់ការយល់ដឹងទូលំទូលាយអំពីសង្គម។

## ១.២. ស្ថានភាព

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់លើយុវជន ដែលជាសសរទ្រូងប្រទេសជាតិ ដោយផ្តល់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពយុវជនទាំងក្នុងនិងក្រៅសាលារៀន ការអប់រំ ថែទាំ និងការផ្តល់សេវាសុខភាពដល់យុវជន ការបណ្តុះស្មារតីសហគ្រិនភាពនិងការបង្កើតទីផ្សារការងារ ការបង្កើនការចូលរួមរបស់យុវជនលើគ្រប់រូបភាព និងការបង្កើនការងារស្ម័គ្រចិត្តរបស់យុវជន។ ទន្ទឹមនឹងនេះមានយុវជនមួយចំនួនពុំទាន់មានឱកាសពេញលេញក្នុងការទទួលបានការងារសមស្របនៅឡើយដោយផ្អែកលើកត្តានានា រួមមានយុវជនមានចំណេះដឹងតិចតួច(ទាំងចំណេះដឹងនិងបំណិនក្នុងការគិត) ធ្វើឱ្យពួកគេបានប្រឈមនឹងការលំបាកឬធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះដែលរួមមានការបោះបង់ការសិក្សា គុណភាពអប់រំនៅមានកម្រិត កង្វះជំនាញដែលសមស្របតាមតម្រូវការទីផ្សារធ្វើឱ្យពួកគេមានការបាត់បង់ជម្រើសរបស់ខ្លួន បញ្ហាកង្វះសុវត្ថិភាពក្នុងសង្គម ដូចជាការសេពគ្រឿងញៀន ការសេពគ្រឿងស្រវឹង គ្រោះថ្នាក់នៅតាមកន្លែងធ្វើការ និងចំណាកស្រុក។ ហេតុផលទាំងនេះហើយដែលជាហេតុធ្វើឱ្យយុវជនទទួលបានទទួលប្រាក់កម្រៃទាបក្នុងនោះស្ត្រីមិនសូវទទួលបានការងារធ្វើដោយកម្រៃខ្ពស់នៅឡើយ។

នៅក្នុងអត្ថបទ Matching Aspirations: Skills for Implementing Cambodia's Growth Strategy នាឆ្នាំ២០១២ និយោជកចំនួន ៧៣% បានបញ្ជាក់ថាអ្នកបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យពុំមានជំនាញសមស្របតាមតម្រូវការ ៦២% បានបញ្ជាក់ថាអ្នកដែលបានបញ្ចប់ការសិក្សាពីមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈពុំទាន់មានជំនាញច្បាស់លាស់

៣១% បានបញ្ជាក់ថាមានការលំបាកក្នុងការបណ្តុះបណ្តាលឬការបង្កើនជំនាញរបស់ខ្លួន ៧០% បានបញ្ជាក់ថាមានកង្វះខាតលើជំនាញគ្រប់គ្រាន់សម្រាប់ការងារគ្រប់គ្រង ៣៦%បានបញ្ជាក់ថាខ្វះជំនាញគ្រប់គ្រងកម្រិតកណ្តាលនិងការត្រួតពិនិត្យ និង៣៥%បានបញ្ជាក់ថាខ្វះជំនាញវិជ្ជាជីវៈ។ កម្ពុជាកំពុងជួបប្រទះនឹងបញ្ហាប្រឈមកង្វះខាតជំនាញទន់(ជំនាញក្នុងការសម្រេចចិត្តនិងវិភាគ) និងជំនាញបច្ចេកទេស។ វិនិយោគិនមិនអាចរកកម្មករជំនាញបានគ្រប់គ្រាន់ នៅខណៈដែលនិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យមិនអាចរកការងារធ្វើបាន ដោយសារតែការសិក្សាមុខជំនាញមិនស្របតាមតម្រូវការទីផ្សារការងារ។ កម្ពុជាមានកម្លាំងពលកម្មដែលមានជំនាញទាប ជាហេតុធ្វើឱ្យប្រាក់បៀវត្សមានកម្រិតទាប។

ចំណែកឯវិស័យអប់រំនៅកម្រិតមធ្យមសិក្សាក្នុងរយៈពេលមួយទសវត្សកន្លងទៅនេះ ការចូលរៀននៅបឋមសិក្សាមានការកើនឡើងយ៉ាងខ្លាំង នាំឱ្យមានសម្ពាធយ៉ាងធ្ងន់ធ្ងរទៅលើការចូលរៀននៅកម្រិតមធ្យមសិក្សា។ អត្រាពិតនៃការសិក្សានៅបឋមសិក្សាសម្រេចបាន៩៧%នៅក្នុងឆ្នាំសិក្សា២០១២-២០១៣។ ដោយឡែក អត្រាពិតនៃការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ មានត្រឹមតែ ៣៨% ប៉ុណ្ណោះ ដែលក្នុងនោះ ៥០%ជាសិស្សស្រី ចំណែកឯអត្រាពិតនៃការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិសម្រេចបាន១៨%។ បញ្ហាប្រឈមនៃវិស័យអប់រំនៅកម្ពុជាគឺ អត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ ជាពិសេសនៅមធ្យមសិក្សាបឋមភូមិ។ អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាស្មើនឹង៨០% តែមានសិស្សប្រមាណ២០%បានបោះបង់ការសិក្សាមុននឹងបញ្ចប់ថ្នាក់ទី៩។ កត្តាសំខាន់ដែលធ្វើឱ្យសិស្សបោះបង់ការសិក្សាច្រើនគឺ ការចំណាយក្នុងការធ្វើដំណើរទៅសាលា ការធ្វើការផ្ទះ និងកាលានុវត្តភាពការងារដែលនឹងបាត់បង់ប្រសិនបើបន្តរៀនទៀត។ អ្នកសិក្សាក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួនត្រឹម៦%ប៉ុណ្ណោះ។

គម្លាតនៃការទទួលបានសេវាអប់រំ គុណភាពអប់រំនៅទាប និងសមត្ថភាពស្ថាប័ននៅមានកម្រិតបង្កជាឧបសគ្គក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយបរិយាបន្ន បានធ្វើឱ្យកម្ពុជាមិនអាចទាញយកផលប្រយោជន៍បានជាអតិបរមាពីសហគមន៍សេដ្ឋកិច្ចអាស៊ាន។ វិទ្យាល័យភាគច្រើនខ្វះខាតគ្រូមានបទពិសោធ សម្ភារៈសិក្សា ឧបករណ៍បង្រៀន សៀវភៅអាន បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ និងបណ្ណាល័យជាដើម។

## ១.៣- បញ្ហាអាទិភាព

ដើម្បីបង្កើតការងារសម្រាប់យុវជនប្រមាណជា៣៦៦.០០០នាក់ ដែលចូលទៅក្នុងទីផ្សារការងាររៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលបាននិងកំពុងជំរុញឱ្យសាកលវិទ្យាល័យនិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការកែលម្អកម្មវិធីសិក្សាដើម្បីផ្សារភ្ជាប់ការអប់រំជាមួយការងារ ធ្វើការអភិវឌ្ឍជំនាញចាំបាច់សម្រាប់ធ្វើការងារ(ជំនាញមូលដ្ឋាន ជំនាញប្រតិបត្តិ ជំនាញទន់ ជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ) ដើម្បីងាយចាប់យកអាជីពនិងមុខរបរក្នុងគោលដៅពង្រឹងការប្រកួតប្រជែងជំនាញ សំដៅឆ្លើយតបបានទៅនឹងសេចក្តីត្រូវការទីផ្សារពលកម្មនិងការបង្កើនឱកាសទទួលបានការងារ។

រាជរដ្ឋាភិបាលផ្តល់អាទិភាពលើការបណ្តុះបណ្តាលជំនាញសមស្របទៅនឹងទីផ្សារការងារ ដូចជាផ្នែកវិស្វកម្ម កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ អេឡិចត្រូនិក កម្មន្តសាល និងការបណ្តុះ បណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីដោះស្រាយកង្វះខាតជំនាញដែលវិនិយោគិនត្រូវការ និងដើម្បីឱ្យនិស្សិតមានការងារធ្វើក្រោយពេលរៀនចប់។

# ២. យុទ្ធសាស្ត្រ

## ២.១. ទិស្តបំណង

ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានេះមានវត្ថុបំណងដូចខាងក្រោម៖

- ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាព និងសមធម៌
- លើកទឹកចិត្តយុវជនឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព
- លើកកម្ពស់យេនឌ័រ ប្រកបដោយសមធម៌និងសមភាពដល់យុវជនទាំងពីរភេទ ជាពិសេស ផ្តល់ឱកាសនិងសិទ្ធិអំណាចដល់ស្ត្រី
- អភិវឌ្ឍយុវជនឱ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាពនិងសុខដុមនីយកម្ម ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និងលើកកម្ពស់ការយល់ដឹងទូលំទូលាយអំពីសង្គម
- បង្កឱកាសឱ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានា នៅក្នុងការអភិវឌ្ឍសហគមន៍និងសង្គមជាតិ
- ប្រមូលផ្តុំកម្លាំងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ មាតាបិតា ឬអាណាព្យាបាល ដើម្បីអភិវឌ្ឍយុវជនកម្ពុជា។

## ២.២. ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍយុវជនកម្ពុជា

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា បានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗ ចំនួន១២ដូច ខាងក្រោម៖

យុទ្ធសាស្ត្រទី១ : អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ
យុទ្ធសាស្ត្រទី២ : លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព
យុទ្ធសាស្ត្រទី៣ : បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព
យុទ្ធសាស្ត្រទី៤ : បណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ
យុទ្ធសាស្ត្រទី៥ : លើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ និងយុត្តិធម៌
យុទ្ធសាស្ត្រទី៦ : បង្កើនការចូលរួមរបស់យុវជន
យុទ្ធសាស្ត្រទី៧ : លើកកម្ពស់ការសម្រាក ការកម្សាន្ត និងកីឡា
យុទ្ធសាស្ត្រទី៨ : លើកកម្ពស់សិល្បៈនិងវប្បធម៌
យុទ្ធសាស្ត្រទី៩ : លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច
យុទ្ធសាស្ត្រទី១០ : បង្កើនការងារស្ម័គ្រចិត្ត
យុទ្ធសាស្ត្រទី១១ : លើកកម្ពស់សមភាពយេនឌ័រ
យុទ្ធសាស្ត្រទី១២ : ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននិងស្តារនីតិសម្បទាយុវជនដែលរងគ្រោះ

ក្នុងដំណាក់កាល ២០១៦-២០១៨ ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា នឹងផ្តោតលើយុទ្ធសាស្ត្រចំនួន៦ ក្នុងចំណោមក្របខណ្ឌយុទ្ធសាស្ត្រទាំង១២ ដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ក្នុងនោះ :

- យុទ្ធសាស្ត្រទី១ : អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ
- យុទ្ធសាស្ត្រទី២ : លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព
- យុទ្ធសាស្ត្រទី៣ : ការបង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព

- យុទ្ធសាស្ត្រទី៩ : បណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ
- យុទ្ធសាស្ត្រទី៦ : បង្កើនការចូលរួមរបស់យុវជន និង
- យុទ្ធសាស្ត្រទី១០ : បង្កើនការងារស្ម័គ្រចិត្ត។

ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន និងក្រុមយុវជននឹងរៀបចំផែនការសកម្មភាពលម្អិត ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដោយរួមបញ្ចូលទាំងការត្រួតពិនិត្យនិងវាយតម្លៃ។

## ២.២.១. គោលការណ៍នៃការរៀបចំផែនការសកម្មភាពជាតិ

ដើម្បីធានានូវតម្លៃនិងភាពជឿជាក់របស់ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា គោលការណ៍ដូចខាងក្រោមនឹងត្រូវអនុវត្ត៖

- **ការផ្តោតលើយុវជន** : ការតាក់តែង ការរៀបចំកម្មវិធី និងសេវាកម្មនានា ត្រូវធានាថាយុវជនបានចូលរួមពិភាក្សា រៀបចំផែនការ និងទទួលបានសេវាទាំងនេះ
- **ការលើកកម្ពស់សមភាពយេនឌ័រ** : ការអភិវឌ្ឍយុវជនដោយគិតគូរពីកត្តាយេនឌ័រ ជាពិសេសត្រូវធានាថាមានតំណាងស្ត្រី៣០%យ៉ាងតិច បានចូលរួមក្នុងដំណើរការតាក់តែង ការរៀបចំផែនការ កម្មវិធី យន្តការ និងសេវាកម្មនានា ព្រមទាំងទទួលផលពីសេវាទាំងនេះ
- **សមាហរណកម្មការងារយុវជន** : ការធ្វើសមាហរណកម្មយុវជនទៅក្នុងដំណើរការនៃការកសាងគោលនយោបាយនិងការសម្រេចចិត្តនានា
- **សមត្ថកិច្ច** : ការបង្កើតបរិយាកាសមួយដែលគាំទ្រដល់ការអភិវឌ្ឍជាបន្តបន្ទាប់ពេញមួយជីវិតរបស់យុវជន ដោយផ្តោតលើជំនាញនិងសមត្ថភាពរបស់ពួកគេ មិនថាពិការ ឬ មិនពិការឡើយ
- **ការចូលរួមរបស់យុវជន** : ការលើកកម្ពស់ការចូលរួមរបស់យុវជននៅក្នុងលទ្ធិប្រជាធិបតេយ្យនិងការកែប្រែនៃសង្គមនៅគ្រប់កម្រិត
- **ការឆ្លើយតប** : ការឆ្លើយតបនឹងតម្រូវការ បញ្ហាប្រឈម និងឱកាសនានាដែលយុវជនជួបប្រទះជាក់ស្តែង និងតាមបែបផែនការនៃការចូលរួម
- **ប្រសិទ្ធផលនិងប្រសិទ្ធភាព** : ការប្រើប្រាស់ធនធានឱ្យបានពេញលេញប្រកបដោយប្រសិទ្ធផល ដើម្បីផលប្រយោជន៍របស់យុវជនគ្រប់រូប
- **តម្លាភាពនិងមធ្យោបាយងាយស្រួល** : ការធានាប្រតិបត្តិការការងារប្រកបដោយតម្លាភាព និងគណនេយ្យភាព ដោយជំរុញឱ្យក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធចូលរួមសហការធ្វើការងារជាមួយយុវជនប្រកបដោយប្រសិទ្ធភាពខ្ពស់
- **ភាពចម្រុះ** : ការទទួលស្គាល់ភាពចម្រុះនៃស្ថានភាពនិងបទពិសោធនានាក្នុងចំណោមយុវជននៅទូទាំងរាជធានី ខេត្ត និងធ្វើការធានាថា គោលនយោបាយ កម្មវិធី រចនាសម្ព័ន្ធ និងសកម្មភាពទាំងអស់ ឆ្លុះបញ្ចាំងនិងឆ្លើយតបចំពោះភាពចម្រុះទាំងអស់នោះ។

## ២.២.២. យន្តការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា

ការអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឈរលើមូលដ្ឋាននៃការសម្របសម្រួលនិងការចូលរួមលក្ខណៈទូលំទូលាយពិស្តារ ដោយតម្រូវឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមក្នុងកម្មវិធីនិងសកម្មភាពអភិវឌ្ឍយុវជន។ យន្តការអនុវត្តនេះតម្រូវឱ្យមានការបង្កើត ការថែរក្សា កិច្ចសហការ និងការសម្របសម្រួលរវាងស្ថាប័ននិងស្ថាប័ន រវាងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងអង្គការដែលធ្វើការដោយផ្ទាល់ និងដោយប្រយោលលើសេវាកម្ម ការផ្តល់ឱកាស និងការអភិវឌ្ឍសមត្ថភាពយុវជន។




### ២.២.២.១- ក្រសួង ស្ថាប័នថ្នាក់ជាតិ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចបង្កើតនិងគាំទ្រដល់ស្ថាប័ននានា ដូចខាងក្រោម៖

### ក- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.)

**ក.ជ.យ.** មានបេសកកម្មសម្របសម្រួលនិងលើកកម្ពស់ការអភិវឌ្ឍយុវជន។ **ក.ជ.យ.** ផ្ដល់សេវាកម្មនានាដល់យុវជន តាមរយៈការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនិងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ **ក.ជ.យ.** ជាយន្តការសម្របសម្រួលតាមដាន វាយតម្លៃ និងជួយរាជរដ្ឋាភិបាលអំពីដំណើរការអភិវឌ្ឍយុវជនឱ្យឆ្លើយតបទៅនឹងច្បាប់ស្ដីពីការអប់រំនិងគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា។ **ក.ជ.យ.** មានសមាសភាពជាសមាជិករាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល តំណាងអង្គការមិនមែនរដ្ឋាភិបាលឬសមាគមដែលធ្វើការងារយុវជនហើយដែលក្រសួងយល់ថាជាតម្រូវការចាំបាច់ និងដឹកនាំដោយ នាយករដ្ឋមន្ត្រី ដូចមានក្នុងមាត្រា២នៃព្រះរាជក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន។

**ក.ជ.យ** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ជាយន្តការថ្នាក់ជាតិសម្រាប់សម្របសម្រួលនិងអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- អនុម័តផែនការសកម្មភាពជាតិសម្រាប់អនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- ជំរុញនិងបញ្ជ្រាបការអភិវឌ្ឍយុវជនទៅក្នុងគោលនយោបាយជាតិនិងកម្មវិធីអភិវឌ្ឍរបស់រាជរដ្ឋាភិបាល
- ណែនាំ ចង្អុលបង្ហាញ និងសម្របសម្រួលដល់ការចូលរួមរបស់យុវជនក្នុងវិស័យសេដ្ឋកិច្ច និងការសម្រេចបាននូវការអប់រំនិងការបណ្ដុះបណ្ដាល
- ប្រមូលផ្ដុំកម្លាំងយុវជនគ្រប់មជ្ឈដ្ឋាននិងកៀរគរធនធានសម្រាប់គាំទ្រនិងអភិវឌ្ឍយុវជនកម្ពុជា
- សិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ វាយតម្លៃ ផ្ដល់អនុសាសន៍ និងធ្វើរបាយការណ៍ពាក់ព័ន្ធនឹងការអភិវឌ្ឍនិងការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា ជូនរាជរដ្ឋាភិបាល

- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ការប្រព្រឹត្តទៅនិងប្រភពធនធានរបស់ **គ.ជ.យ.** មានកំណត់ក្នុងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន។

## ២- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (គ.ជ.យ.)

ដើម្បីគាំទ្រដល់ដំណើរការការងារប្រចាំថ្ងៃរបស់ **គ.ជ.យ.** និងដើម្បីអនុវត្តកម្មវិធីដែលមានកំណត់ក្នុងផែនការសកម្មភាពជាតិ រាជរដ្ឋាភិបាលបានបង្កើត "**អគ្គលេខាធិការដ្ឋាន**" មួយជាសេនាធិការ ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់ **គ.ជ.យ.**
- រៀបចំនិងប្រមូលផ្តុំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.យ.**
- រៀបចំនិងបង្កើតកម្មវិធីនិងសេវានានាដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- សម្របសម្រួលលើកកម្ពស់អន្តរកម្មនិងការងារជាបណ្តាញក្នុងចំណោមស្ថាប័នរដ្ឋ ស្ថាប័ន ឯកជន អង្គការជាតិ អង្គការអន្តរជាតិ និងអ្នកពាក់ព័ន្ធ
- រៀបចំការប្រជុំ សន្និសីទ ការបណ្តុះបណ្តាល សិក្ខាសាលា និងការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជន
- ផ្តល់ព័ត៌មានថ្មីៗចុងក្រោយទាន់សភាពការណ៍អំពីយុទ្ធសាស្ត្រសំខាន់ៗដើម្បីអភិវឌ្ឍយុវជន
- ជំរុញនិងតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជន
- សិក្សាស្រាវជ្រាវ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- លើកសំណើពិនិត្យនិងកែលម្អគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាជូន **គ.ជ.យ.**
- ធ្វើរបាយការណ៍ជូន **គ.ជ.យ.** និងស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.យ.** ប្រគល់ជូន។

រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានចែកជាបីផ្នែក ដើម្បីបំពេញតួនាទីនិងភារកិច្ចជាសេនាធិការជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (**គ.ជ.យ.**)។

តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗមានដូចខាងក្រោម៖

### ១- ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

- គ្រប់គ្រងមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.យ.**
- ផ្គត់ផ្គង់សម្ភារៈ បរិក្ខារនិងគ្រប់គ្រងឯកសាររដ្ឋបាល ចលនវត្ថុ អចលនវត្ថុ និងបញ្ជីសារពើភណ្ឌ
- រៀបចំកសាងផែនការនិងគ្រប់គ្រងហិរញ្ញវត្ថុ
- គ្រប់គ្រងស្ថិតិព័ត៌មាននិងតួលេខរបស់អង្គការស្ថាប័ននឹងការងារអភិវឌ្ឍយុវជន
- ធ្វើទំនាក់ទំនងនិងសហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន
- ធ្វើកំណត់ហេតុរាល់អង្គប្រជុំសាមញ្ញនិងវិសាមញ្ញរបស់ **គ.ជ.យ.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផល សកម្មភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.យ.** ប្រគល់ជូន។

ដើម្បីបន្ថែមពីលើការគាំទ្រផ្នែកភស្តុភារដល់ **គ.ជ.យ.** និងអគ្គលេខាធិការដ្ឋាន ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ត្រូវរៀបចំជាគម្រោងថវិកាយុវជនដែលកំណត់អំពីបន្ទុកចំណាយរបស់ក្រសួងទាំងអស់ទៅលើកម្មវិធី សេវាកម្ម និងសម្ភារៈនិងទីកន្លែងនានាដែលពាក់ព័ន្ធនឹងយុវជន។ គម្រោងថវិការួមនេះ ត្រូវប្រើប្រាស់ដើម្បីកំណត់អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះការអភិវឌ្ឍយុវជន។

គម្រោងថវិកាយុវជនមាន៖

- ផ្អែកទៅលើយន្តការនិងលក្ខខណ្ឌដែលមានការព្រមព្រៀងសម្រាប់កំណត់ហិរញ្ញវត្ថុដែលត្រូវចំណាយទៅលើកម្មវិធី សេវាកម្ម សម្ភារៈ និងទីកន្លែង
- ត្រូវផ្សព្វផ្សាយនៅខែមេសា ជារៀងរាល់ឆ្នាំ
- ត្រូវបង្កើតឡើងដោយមានការពិភាក្សាជាមួយ **គ.ជ.យ.**
- មានបច្ចុប្បន្នកម្មព័ត៌មានស្តីពីបន្ទុកចំណាយនៃកម្មវិធីយុវជនរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការងារយុវជន
- ផ្សព្វផ្សាយចំណេះដឹងអំពីការងារយុវជនក្នុងចំណោមក្រសួង ស្ថាប័ននានា។

ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ធ្វើការត្រួតពិនិត្យតាមដានការងាររបស់ក្រុមប្រឹក្សាដែលគាំទ្រកិច្ចការយេនឌ័រ និងពិការភាព និងផ្តល់អនុសាសន៍នៅពេលដែលអាចត្រូវមានវិធានការបង្ការ។

## ២- ផ្នែកអនុវត្តគោលនយោបាយ

- សម្របសម្រួលការអភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការផ្សេងៗ
- ជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងកម្មវិធីនានា
- ជំរុញនិងលើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពយុវជនប្រកប ដោយគំនិតច្នៃប្រឌិត
- សម្របសម្រួលនិងអនុវត្តការបណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ
- សហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងឯកជនពាក់ព័ន្ធនានា ដើម្បីជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- បង្កើនកិច្ចសហការដើម្បីផ្តល់ឱកាសឱ្យយុវជនធ្វើជំនួញខ្នាតតូច មធ្យម និងខ្នាតធំនិងផ្តល់ឥណទានក្នុងការចាប់ផ្តើមនិងពង្រីកមុខជំនួញ
- បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាពដល់យុវជន
- សម្របសម្រួលនិងលើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ យុត្តិធម៌ និងទប់ស្កាត់អំពើហិង្សាក្នុងចំណោមយុវជន
- សម្របសម្រួលនិងលើកកម្ពស់ការសម្រាក ការកម្សាន្តនិងកីឡា ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច
- សម្របសម្រួលទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងស្ការយុវនីតិសម្បទាក្នុងចំណោមយុវជន
- សម្របសម្រួលនិងលើកកម្ពស់កិច្ចការពារយុត្តិធម៌និងដោះស្រាយបញ្ហាយុវជន
- បង្កើនការចូលរួមរបស់យុវជនក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន សហគមន៍ និងការអភិវឌ្ឍប្រទេសជាតិ
- លើកទឹកចិត្តឱ្យយុវជនចូលរួមបំពេញការងារស្ម័គ្រចិត្តនិងលើកកម្ពស់សាមគ្គីភាពនិងសមភាពយេនឌ័រ
- សហការជាមួយគ្រប់ប្រព័ន្ធព័ត៌មានដើម្បីផ្សព្វផ្សាយអំពីការអភិវឌ្ឍយុវជន ជាពិសេស ការយល់ដឹងអំពីបរិស្ថាន កសិកម្ម និងទេសចរណ៍
- លើកកម្ពស់សិល្បៈ វប្បធម៌ និងការបណ្តុះបណ្តាលយុវអ្នកនិពន្ធ យុវសិល្បករដែលប្រកបដោយគំនិតច្នៃប្រឌិត

- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.យ.** ប្រគល់ជូន។

បន្ថែមពីនេះ ផ្នែកអនុវត្តគោលនយោបាយក៏អនុវត្តផងដែរនូវការៈ

- ពិនិត្យពិច័យលើការតាក់តែងនិងការអនុវត្តយុទ្ធសាស្ត្រនិងសកម្មភាពរបស់ **គ.ជ.យ.** មួយចំនួន និងធានាឱ្យមានការប្រកាន់ខ្ជាប់នូវគោលការណ៍
- បង្កើតនិងថែរក្សាបណ្ដាញការងារដែលផ្ដល់ការគាំទ្រដល់យុទ្ធសាស្ត្រនិងសកម្មភាពរបស់ **គ.ជ.យ.** ទាំងផ្នែករបៀបរបបធ្វើការងារនៅថ្នាក់រាជធានី ខេត្ត និងទាំងផ្នែកគ្រប់គ្រងអង្គភាព
- សម្របសម្រួលលំហូរព័ត៌មានរវាង **គ.ជ.យ.** និងអ្នកពាក់ព័ន្ធសំខាន់ៗរួមមានយុវជន និងសាធារណជនទូទៅ។ ការងារនេះត្រូវប្រើប្រាស់ច្រកបណ្ដាញ ដូចជា ក្រសួងកិច្ចការនារីដែលកំពុងធ្វើប្រតិបត្តិការសេវាកម្មពិគ្រោះយោបល់ស្ដីពី បញ្ហាសង្គមនិងផលប៉ះពាល់លើ យុវជន
- រៀបចំកម្មវិធីគ្រប់គ្រងការអនុវត្តផែនការសកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពប្រើប្រាស់ធនធាន ធានាការអនុវត្តសកម្មភាព និងការបំពេញគម្រោងដែលផ្សារភ្ជាប់គ្នាទៅវិញទៅមក និងកាត់បន្ថយការងារត្រួតគ្នាឱ្យនៅតិចបំផុត ដោយបង្កលទ្ធភាពរិះរកវិធីប្រើប្រាស់ឱ្យមានភាពខុសប្លែកគ្នា
- ធានាថាសកម្មភាពទាំងអស់ត្រូវគ្រប់គ្រងច្បាស់លាស់ជាគម្រោងការងារ ដែលមានការគ្រប់គ្រងធនធានបានត្រឹមត្រូវ ហើយសកម្មភាពទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ យុទ្ធសាស្ត្រ និងថវិការបស់ក្រសួងជាចាំបាច់ និងទាន់ពេលវេលា។

## ៣- ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

- រៀបចំផែនការសកម្មភាពនិងកំណត់សូចនាករដើម្បីត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្ដល់សេវាឱ្យឆ្លើយតបនឹងគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំសេចក្ដីព្រាងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអនុវត្តនិងការអភិវឌ្ឍគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- គ្រប់គ្រងទិន្នន័យយុវជននិងវិភាគលទ្ធផលការងារដើម្បីកែលម្អការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- សិក្សាស្រាវជ្រាវទៅលើបញ្ហាយុវជននៅក្នុងសង្គមដែលជាមូលដ្ឋានជាក់ស្ដែងសម្រាប់អភិវឌ្ឍគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.យ.** ប្រគល់ជូន។

ផ្នែកត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ប្រមូលព័ត៌មានទាំងអស់ពាក់ព័ន្ធនឹងសកម្មភាពគាំទ្រដល់យុទ្ធសាស្ត្ររបស់គោលនយោបាយ។ ផ្នែកនេះបង្កើតឱ្យមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃតាមបែបបរិមាណសម្រាប់យុទ្ធសាស្ត្រនីមួយៗក្នុងចំណោមយុទ្ធសាស្ត្រទាំង១២ នៅក្នុងគោលនយោបាយដែលជាដំបូងផ្ដើមចេញមកពីទិន្នន័យនៃគម្រោងនានាដែលមានស្រាប់។ កិច្ចការនេះរួមបញ្ចូលការវិភាគបំបែកទៅតាមភេទនីមួយៗក្នុងករណីអាចធ្វើបាន។

ផ្នែកនេះត្រូវបង្កើតៈ

- យុទ្ធសាស្ត្រត្រួតពិនិត្យតាមដាននិងវាយតម្លៃមួយដែលនឹងកំណត់អំពីតម្រូវការជំនាញសំខាន់ៗ
- ផែនការការងារសម្រាប់ឆ្នាំ២០១៦-២០១៨ និង
- ការស្ទាបស្ទង់មតិនិងឧបករណ៍មានប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងតម្រូវការដែលកំពុងផុសឡើងអំពីការទទួលបានព័ត៌មានប្រសើរជាងមុននៅក្នុងវដ្ដនៃការអភិវឌ្ឍជាបន្តបន្ទាប់។

ផ្នែកនេះត្រូវធ្វើរបាយការណ៍ជាប្រចាំសម្រាប់ **គ.ជ.យ.** និងការប្រើប្រាស់ជាសាធារណៈដើម្បីឈានទៅរកការសម្រេចគោលដៅរបស់គោលនយោបាយ របាយការណ៍ស្ថានភាពនៃការអនុវត្តគម្រោងគាំទ្ររបាយការណ៍លទ្ធផលគម្រោងគាំទ្រ។

## គ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នត្រូវបង្កើតឡើងដែលមានសមាជិក **គ.ជ.យ.** ជាប្រធាន និងមានសមាសភាពជាថ្នាក់ដឹកនាំក្រសួង និងអង្គភាពក្រោមឱវាទក្រសួង។

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នជាយន្តការសម្របសម្រួលទំនាក់ទំនងរវាងក្រសួង ស្ថាប័ន ជាមួយគណៈកម្មការជំនាញចំណុះ **គ.ជ.យ.** អគ្គលេខាធិការដ្ឋាននៃ **គ.ជ.យ.** និង **គ.ជ.យ.** និងដើម្បីសម្របសម្រួល និងសមាហរណកម្មកម្មវិធីទៅក្នុងអង្គភាពពាក់ព័ន្ធ។

ក្រុមប្រឹក្សាអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ជាយន្តការតាមដានវាយតម្លៃអំពីការអភិវឌ្ឍយុវជនក្នុងវិស័យរបស់ខ្លួន និងរាយការណ៍ជូន **គ.ជ.យ.**។

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងការងារយុវជននៅក្នុងក្រសួង ស្ថាប័ន
- រៀបចំផែនការសកម្មភាព កម្មវិធី សេវាកម្ម និងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍របស់យុវជនក្រសួង ស្ថាប័ន
- ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តសន្ធិសញ្ញានានាពាក់ព័ន្ធយុវជន ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានៅក្រសួង ស្ថាប័ន និងលើកសំណើជូន **គ.ជ.យ.** ដើម្បីដោះស្រាយ និងជានាឧត្តមប្រយោជន៍របស់យុវជនក្រសួង ស្ថាប័ន
- ធ្វើការផ្សព្វផ្សាយច្បាប់ សន្ធិសញ្ញានានាពាក់ព័ន្ធនិងយុវជន គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និង **គ.ជ.យ.** ពាក់ព័ន្ធនឹងបញ្ហារបស់យុវជន បំផុសចលនាគាំទ្រ និងចូលរួមអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឱ្យមានប្រសិទ្ធភាព
- ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជនដែលមានគម្រោងការងារពាក់ព័ន្ធយុវជននៅក្នុងក្រសួង ស្ថាប័ន ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធ និងទស្សនៈរីកចម្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការអភិវឌ្ឍយុវជន
- រៀបចំមូលដ្ឋានទិន្នន័យស្តីពីស្ថានភាពយុវជននៅក្នុងក្រសួង ស្ថាប័ន
- សហការរៀបចំទិវាអន្តរជាតិសម្រាប់យុវជន ១២ សីហា
- សហការអនុវត្តគោលការណ៍និងផែនការសកម្មភាពរបស់ **គ.ជ.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារតាមកាលកំណត់ ជូន **គ.ជ.យ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែល **គ.ជ.យ.** ប្រគល់ជូន។

សមាជិកភាពក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ននីមួយៗមានតំណាងមកពីអង្គភាពក្រោមឱវាទរបស់ខ្លួន គឺជាមន្ត្រីបង្គោលការងារយុវជន។ មន្ត្រីបង្គោលការងារយុវជនត្រូវធ្វើរបាយការណ៍ស្តីពីគោលនយោបាយ កម្មវិធី សេវាកម្ម សកម្មភាពនានាដែលប៉ះពាល់យុវជន ពាក់ព័ន្ធនឹងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ហើយត្រូវបានបញ្ចូលទៅក្នុងផែនការរបស់នាយកដ្ឋានខ្លួនជូន ក្រុមប្រឹក្សាចំនួនបួនដងក្នុងមួយឆ្នាំ។

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នត្រូវបង្កើតក្រុមការងារបច្ចេកទេស។ សមាជិកភាពនៃក្រុមការងារបច្ចេកទេសត្រូវជ្រើសរើសចេញពីសមាជិកភាពនៃក្រុមប្រឹក្សា ហើយអាចបញ្ចូលបន្ថែមនូវអ្នកជំនាញ និងអ្នកតំណាងយុវជនតាមការចាំបាច់។ ក្រុមការងារបច្ចេកទេសខ្លះដែលមានស្រាប់ អាចត្រូវស្នើឱ្យបញ្ចូលការអភិវឌ្ឍយុវជនទៅក្នុងសមត្ថកិច្ចការងាររបស់ខ្លួន។

### ២.២.២.២- ស្ថាប័នថ្នាក់ក្រោមជាតិ

#### ក- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្តត្រូវបង្កើតឡើងដែលមានសមាសភាពជាថ្នាក់ដឹកនាំរាជធានី ខេត្ត អង្គភាពក្រោមឱវាទរដ្ឋបាលរាជធានី ខេត្ត មន្ទីរជំនាញពាក់ព័ន្ធជុំវិញរាជធានី ខេត្ត តំណាងសាខាកាកបាទក្រហមកម្ពុជារាជធានី ខេត្ត តំណាងស្នងការដ្ឋានកាយរឹទ្ធិរាជធានី ខេត្ត និងមន្ត្រីដែលមានបទពិសោធលើការងារយុវជនឬដែលកំពុងធ្វើការងារយុវជន។ ស្ត្រីត្រូវបានផ្តល់អាទិភាពឱ្យចូលរួមក្នុងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត។

ក្រុមប្រឹក្សាអភិវឌ្ឍយុវជនរាជធានី ខេត្ត ជាបណ្តាញរបស់ **គ.ជ.យ.** និងជាយន្តការថ្នាក់ក្រោមជាតិសម្រាប់សម្របសម្រួល និងជួយគណៈអភិបាលរាជធានី ខេត្តអំពីដំណើរការអភិវឌ្ឍយុវជននៅរាជធានី ខេត្ត។

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្តមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងការងារយុវជននៅក្នុងរាជធានី ខេត្ត
- រៀបចំផែនការសកម្មភាព កម្មវិធី សេវាកម្ម និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍របស់យុវជនរាជធានី ខេត្ត
- ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តសន្និសញ្ញានានាពាក់ព័ន្ធយុវជន ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានៅរាជធានី ខេត្ត និងលើកសំណើជូន **គ.ជ.យ.** ដើម្បីធានាឧត្តមប្រយោជន៍របស់យុវជនក្នុងរាជធានី ខេត្ត
- ផ្សព្វផ្សាយច្បាប់ សន្និសញ្ញានានាពាក់ព័ន្ធយុវជន គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និង **គ.ជ.យ.** ពាក់ព័ន្ធនឹងបញ្ហារបស់យុវជន បំផុសចលនាគាំទ្រ និងចូលរួមអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឱ្យមានប្រសិទ្ធភាព
- ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជនដែលមានគម្រោងការងារពាក់ព័ន្ធយុវជននៅក្នុងរាជធានី ខេត្ត ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធ និងទស្សនៈរីកចម្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការអភិវឌ្ឍយុវជន
- រៀបចំមូលដ្ឋានទិន្នន័យស្តីពីស្ថានភាពយុវជននៅក្នុងរាជធានី ខេត្ត
- សហការរៀបចំទិវាអន្តរជាតិសម្រាប់យុវជន ១២ សីហា
- សហការអនុវត្តគោលការណ៍និងផែនការសកម្មភាពរបស់ **គ.ជ.យ.**
- ធ្វើរបាយការណ៍សកម្មភាពការងារតាមកាលកំណត់ជូន **គ.ជ.យ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែល **គ.ជ.យ.** ប្រគល់ជូន។

#### ខ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ត្រូវបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ដែលជាយន្តការសម្របសម្រួលដំណើរការអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ។

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតឡើងដែលមានសមាសភាពជាថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌ អង្គភាពក្រោមឱវាទរដ្ឋបាលក្រុង ស្រុក ខណ្ឌ ការិយាល័យជំនាញពាក់ព័ន្ធជុំវិញក្រុង ស្រុក ខណ្ឌ និងមន្ត្រីដែលមានបទពិសោធលើការងារយុវជន ឬដែលកំពុងធ្វើការងារយុវជន។ ស្ត្រីត្រូវបានផ្តល់អាទិភាពឱ្យចូលរួមក្នុងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ។

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងការងារយុវជននៅក្នុងក្រុង ស្រុក ខណ្ឌ

- រៀបចំផែនការសកម្មភាព កម្មវិធី សេវាកម្ម និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍របស់យុវជនក្រុង ស្រុក ខណ្ឌ
- ពិនិត្យ តាមដាន វាយតម្លៃលើការផែនការសកម្មភាពស្តីពីការអភិវឌ្ឍយុវជនកម្ពុជានៅក្រុង ស្រុក ខណ្ឌ និងលើកសំណើជូនក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ដើម្បីធានាឧត្តមប្រយោជន៍របស់យុវជនក្នុងក្រុង ស្រុក ខណ្ឌ
- ផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និង **គ.ជ.យ.** ពាក់ព័ន្ធនឹងបញ្ហារបស់យុវជន បំផុសចលនាគាំទ្រ និងចូលរួមអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឱ្យមានប្រសិទ្ធភាព
- ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជនដែលមានគម្រោងការងារពាក់ព័ន្ធយុវជននៅក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធ និងទស្សនៈរីកចម្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការអភិវឌ្ឍយុវជន
- រៀបចំមូលដ្ឋានទិន្នន័យស្តីពីស្ថានភាពយុវជននៅក្នុងក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍សកម្មភាពការងារតាមកាលកំណត់ជូនក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែល **គ.ជ.យ.** ប្រគល់ជូន។

### គ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់ ដែលជាយន្តការនៅផ្ទាល់ជាងគេ ដើម្បីសម្របសម្រួលដំណើរការអភិវឌ្ឍយុវជនឃុំ សង្កាត់។

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់មានតួនាទីនិងភារកិច្ច សម្របសម្រួល ចង្អុលបង្ហាញ និងបង្កឱ្យមានសហប្រតិបត្តិការរាល់គ្រប់ដៃគូទាំងអស់ដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការទទួលខុសត្រូវមួយចំនួនទៀតគឺការចែករំលែកការទទួលខុសត្រូវនិងគាំទ្រដើម្បីផលប្រយោជន៍ទៅវិញទៅមក។ ការចែករំលែកទំហំទទួលខុសត្រូវនិងគាំទ្រដើម្បីផលប្រយោជន៍ទៅវិញទៅមក មានដូចខាងក្រោម៖

- លើកកម្ពស់ការអភិវឌ្ឍយុវជន
- បង្កើតនូវបរិយាកាសគាំទ្រនិងជំរុញដល់ការអភិវឌ្ឍយុវជន
- ធានាថាសកម្មភាពគន្លឹះដែលបង្កើតលទ្ធផលសម្រាប់អភិវឌ្ឍការងារអភិបាលកិច្ចកម្រិតឃុំ សង្កាត់ ត្រូវបានផ្តល់អាទិភាពនិងតាមដានត្រួតពិនិត្យ
- ប្រើប្រាស់រចនាសម្ព័ន្ធនិងយន្តការដែលមានស្រាប់ ដើម្បីធ្វើសមាហរណកម្មនិងបង្កើតតួនាទីអភិវឌ្ឍយុវជននិងការទទួលខុសត្រូវ
- អភិវឌ្ឍនិងតាមដានត្រួតពិនិត្យនូវសូចនាករលទ្ធផលគន្លឹះសម្រាប់មន្ត្រីយុវជនដែលទទួលខុសត្រូវការអភិវឌ្ឍយុវជនក្នុងកម្រិតឃុំ សង្កាត់
- ចូលរួមគាំទ្រដល់ផែនការអភិវឌ្ឍយុវជន
- ចូលរួមសហការជិតស្និទ្ធជាមួយថ្នាក់ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត ថ្នាក់ជាតិ ដើម្បីកំណត់នូវការរៀបចំនិងសម្របសម្រួលដល់ការងារអភិវឌ្ឍយុវជន
- រក្សានិងវិភាគនូវព័ត៌មាន បញ្ហាប្រឈមនៃការអភិវឌ្ឍយុវជន និងការជះឥទ្ធិពលទៅលើការផ្តល់សេវាកម្មអភិវឌ្ឍ ការរៀបចំ និងការអនុវត្តផែនការគាំទ្រដល់ការងារអភិវឌ្ឍយុវជន។

### ២.២.២.៣- ដៃគូអភិវឌ្ឍនិងសង្គមស៊ីវិល

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន ទទួលស្គាល់តួនាទីអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិក្នុងការអភិវឌ្ឍយុវជន។ **គ.ជ.យ.** ត្រូវធ្វើការងារដោយផ្សារភ្ជាប់ជាមួយអង្គការសង្គមស៊ីវិលតាមរយៈកម្រង

សមាគម ដើម្បីកំណត់ពីតម្រូវការធនធាន និងលទ្ធភាពរបស់រាជរដ្ឋាភិបាល វិស័យឯកជន និងកិច្ចគាំទ្ររបស់ដៃគូអភិវឌ្ឍ។ **ក.ខ.យ.**ជំរុញឱ្យមានការចូលរួមយ៉ាងសកម្មជាមួយបណ្តាញអង្គការ សង្គមស៊ីវិលសមាគមក្នុងការលើកកម្ពស់ការអភិវឌ្ឍនិងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។

ជាតុចូលនិងការរួមវិភាគទានរបស់វិស័យឯកជន មានសារៈសំខាន់បំផុតសម្រាប់កម្មវិធីគាំទ្រយុវជន។ **ក.ខ.យ.** មានតួនាទីអភិវឌ្ឍនិងពង្រឹងទំនាក់ទំនងជាមួយសមាគមនានាក្នុងវិស័យឯកជន ក៏ដូចជាសមាគមដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យជាក់លាក់ផ្សេងៗដូចជាវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្មទូទៅ និងហិរញ្ញវត្ថុជាដើម។

# ៣- ផែនការសកម្មភាព

## ក- បរិយាយសង្ខេបអំពីវិសាលភាពផែនការសកម្មភាព

### ៣.១- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី១ : អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ

សកម្មភាពចំនួន១០ត្រូវបានកំណត់ រួមមាន (១) សេវាកម្មព័ត៌មានយុវជនច្រកតែមួយ (២) ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន (៣) ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត (៤)ការសម្របសម្រួលជាមួយសង្គមស៊ីវិល (៥) ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (៦) ការតស៊ូមតិនៅក្នុងសភាជាតិ ក្រសួង ស្ថាប័ន និងថ្នាក់រាជធានី ខេត្ត (៧) ការស្រាវជ្រាវអំពីយុវជន (៨) ការពិនិត្យកែសម្រួលនិងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តការងារយុវជន (៩) ការអភិវឌ្ឍធនធានមនុស្ស និង(១០) ការកៀរគរធនធាន។

#### ៣.១.១- សេវាកម្មព័ត៌មានយុវជនច្រកតែមួយ

សេវាកម្មព័ត៌មានយុវជនច្រកតែមួយគឺជាការអភិវឌ្ឍថ្មីមួយសម្រាប់យុវជនដែលត្រូវដាក់ឱ្យសាកល្បងដោយ **គ.ជ.យ.**។ សេវាកម្មព័ត៌មាននេះរួមចំណែកដល់ការអភិវឌ្ឍចំណេះដឹង និងការផ្តល់សិទ្ធិអំណាចដល់យុវជន តាមរយៈការផ្តល់ព័ត៌មានពិតត្រឹមត្រូវ ពាក់ព័ន្ធនឹងមានប្រយោជន៍ដល់ការអភិវឌ្ឍរបស់ពួកគេ។ សេវាកម្មនេះមានធាតុចំនួន៥ ដូចតទៅ៖

- វេបសាយនិងទិន្នន័យលើប្រព័ន្ធអ៊ីនធឺណិត រួមមាន ការទាញយកព័ត៌មានបានតាមរយៈប្រព័ន្ធទូរស័ព្ទដៃ
- សេវាកម្មព័ត៌មានយុវជនតាមរយៈទូរស័ព្ទនិងការបញ្ជូនបន្ត
- សេវាកម្មផ្តល់ព័ត៌មានដោយផ្ទាល់នៅតាមមជ្ឈមណ្ឌលយុវជន មជ្ឈមណ្ឌលការងារ និងទីកន្លែងប្រហាក់ប្រហែលគ្នានៅគ្រប់រាជធានី ខេត្ត
- កូនសៀវភៅសេវាកម្មនិងកម្មវិធីយុវជន
- សេវាកម្មផ្សព្វផ្សាយតាមរយៈព្រឹត្តិការណ៍នានា(កីឡា តន្ត្រី។ល។)កម្មវិធីវិទ្យុនិងទូរទស្សន៍ជាប្រចាំក៏ដូចជាប្រព័ន្ធព័ត៌មានសង្គមដទៃទៀត។

*គោលបំណងសកម្មភាព*

ផ្តល់លទ្ធភាពនិងមធ្យោបាយតាមច្រកតែមួយក្នុងការទទួលបានព័ត៌មានទាំងអស់ដែលមានប្រយោជន៍សម្រាប់យុវជន។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជនទាំងអស់ រួមទាំងជនជាតិភាគតិច ក្រុមយុវជនងាយរងគ្រោះ និងអ្នកធ្វើការងារយុវជនទាំងអស់។

***កិច្ចការសំខាន់ៗ***

- ការសិក្សាលម្អិតដោយមានគោលការណ៍ច្បាស់លាស់ ការអភិវឌ្ឍយុទ្ធសាស្ត្រទំនាក់ទំនងគម្រោងការងារ និងគម្រោងថវិកា
- សេវាកម្មព័ត៌មានសាកល្បង(វេបសាយនិងទិន្នន័យលើប្រព័ន្ធអ៊ីនធឺណិត និងបណ្តាញទូរស័ព្ទយុវជន)
- ការពិនិត្យឡើងវិញលើការពាក់ព័ន្ធរបស់ទិន្នន័យលើប្រព័ន្ធអ៊ីនធឺណិត និងការប្រើប្រាស់ព័ត៌មាន
- ផែនការការងារនិងសំណើមូលនិធិរៀបចំឡើងដើម្បីបន្តប្រតិបត្តិការសេវាកម្ម
- ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងដែលមាននិរន្តរភាព។

***លទ្ធផលរំពឹងទុកពីសកម្មភាព***

យុវជនទទួលបានព័ត៌មានអំពីសេវាកម្ម ជម្រើសនានា និងការគាំទ្រសម្រាប់ពួកគេ។

***សូចនាករអនុវត្ត***

- យុទ្ធសាស្ត្រទំនាក់ទំនង
- បណ្តាញទំនាក់ទំនងនិងផ្សព្វផ្សាយ
- អត្រាការប្រើប្រាស់ទម្រង់នានានៃលទ្ធភាពនិងមធ្យោបាយទទួលបានសេវាកម្ម
- ចំណេះដឹងស្តីពីសេវាកម្ម និង **គ.ជ.យ.** សាធារណជន និងយុវជន
- ចំណេះនិងការយល់ដឹងអំពីយុវជននិងអ្នកធ្វើការងារយុវជន។

***ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត***

**គ.ជ.យ.** ធ្វើការងារសហការជាមួយក្រសួងព័ត៌មាន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់។

### ៣.១.២- ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន

***គោលបំណងសកម្មភាព***

លើកកម្ពស់ការសម្របសម្រួលសេវាកម្មអភិវឌ្ឍន៍យុវជន ការបង្កើតកម្មវិធី និងគំនិតផ្តួចផ្តើមអភិវឌ្ឍយុវជននៅក្នុងក្រសួង ស្ថាប័នទាំងអស់។

***ក្រុមគោលដៅរបស់សកម្មភាព***

ក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើងដោយមានសមាជិកមកពីអង្គភាពពាក់ព័ន្ធនីមួយៗក្នុងក្រសួង ស្ថាប័នសាមី។

***កិច្ចការសំខាន់ៗ***

- រៀបចំផែនការកម្មវិធីសម្រាប់ឆ្នាំ២០១៤-២០១៨
- សម្ពោធដំណើរការមគ្គុទ្ទេសក៍កម្មវិធីនិងសេវាកម្មយុវជនរបស់រាជរដ្ឋាភិបាល
- សម្ពោធប្រតិបត្តិតាមមគ្គុទ្ទេសក៍កម្មវិធីនិងអនុវត្តសេវាកម្មយុវជនរបស់រាជរដ្ឋាភិបាលលើកទី២។

***លទ្ធផលរំពឹងទុកពីសកម្មភាព***

វិធីសាស្ត្រសម្របសម្រួលសកម្មភាពយុវជននៅក្នុងក្រសួង ស្ថាប័នទាំងអស់។

***សូចនាករអនុវត្ត***

- ចំនួនអង្គភាពដែលចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នបានទៀងទាត់
- ការអនុលោមតាមផែនការកម្មវិធីរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន
- របាយការណ៍ស្តីពីសកម្មភាពក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន
- ការផលិត និងការចែកចាយមគ្គុទ្ទេសក៍កម្មវិធីរាជរដ្ឋាភិបាលប្រចាំឆ្នាំ។

***ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត***

ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ដែលមានប្រធានជាសមាជិក **គ.ជ.យ.**។ ផ្នែកអនុវត្តគោលនយោបាយនឹងផ្តល់ការគាំទ្រផ្នែកភស្តុភារ និងលេខាធិការជាមួយនឹងការគាំទ្ររបស់ក្រសួង ស្ថាប័នសម្រាប់ផែនការកម្មវិធីរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន។

### ៣.១.៣- ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត

***គោលបំណងសកម្មភាព***

លើកកម្ពស់ការសម្របសម្រួលសេវាកម្មការអភិវឌ្ឍយុវជន និងសម្ភារៈ មធ្យោបាយ ការបង្កើតកម្មវិធី និងការផ្តួចផ្តើមអភិវឌ្ឍយុវជននៅកម្រិតថ្នាក់ក្រោមជាតិ។

***ក្រុមគោលដៅរបស់សកម្មភាព***

មន្ត្រី និងអ្នកដឹកនាំសំខាន់ៗនៅក្នុងអាជ្ញាធររាជធានី ខេត្ត។

*កិច្ចការសំខាន់ៗ*

- ចងក្រងកម្រងឯកសាររចនាសម្ព័ន្ធនៃមុខងាររបស់រាជធានី ខេត្ត
- រៀបចំធ្វើផែនការការងារប្រចាំឆ្នាំនៃកិច្ចប្រជុំថ្នាក់រាជធានី ខេត្ត
- ធ្វើសវនកម្មគោលនយោបាយ កម្មវិធី និងការផ្តួចផ្តើមការអភិវឌ្ឍយុវជនរាជធានី ខេត្ត
- រៀបចំសិក្ខាសាលាស្តីពីសារៈសំខាន់របស់គោលនយោបាយយុវជនរាជធានី ខេត្ត និងសេចក្តីណែនាំការធ្វើផែនការកម្មវិធី។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

ការផលិតសេចក្តីណែនាំស្តីពីសកម្មភាពអភិវឌ្ឍយុវជនរាជធានី ខេត្ត។

*សូចនាករអនុវត្ត*

- ការបង្កើតវេទិកាប្រចាំត្រីមាស
- ចំនួនវេទិកាដែលបានរៀបចំ
- ការបោះពុម្ពផ្សព្វផ្សាយព័ត៌មានស្តីពីការងារអភិវឌ្ឍន៍យុវជនដែលរាជធានី ខេត្តកំពុងអនុវត្ត
- ការចូលរួមរបស់រាជធានី ខេត្តក្នុងវេទិកា កិច្ចប្រជុំ និងសិក្ខាសាលានានា
- ការរៀបចំនិងអនុវត្តឱ្យមានការពង្រឹងនិងពង្រីកបន្ថែមទៅលើគោលនយោបាយ និងកម្មវិធីថ្នាក់រាជធានី ខេត្តសម្រាប់ការអភិវឌ្ឍយុវជន។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

**គ.ជ.យ.** (ផ្នែកអនុវត្តគោលនយោបាយ) ត្រូវគ្រប់គ្រងដំណើរការនេះ ដោយមានការចូលរួមពីថ្នាក់រាជធានី ខេត្ត។

### *៣.១.៤- ការសម្របសម្រួលជាមួយសង្គមស៊ីវិល*

*គោលបំណងសកម្មភាព*

កំណត់នូវកិច្ចសហការនិងបណ្តាញការងារបានច្បាស់លាស់។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជន អង្គភាពពាណិជ្ជកម្មនិងហិរញ្ញវត្ថុ អ្នកធ្វើការងារយុវជន អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។

*កិច្ចការសំខាន់ៗ*

- ប្រមូលនិងបញ្ជ្រាបការងារអភិវឌ្ឍន៍យុវជនទៅក្នុងសង្គមស៊ីវិល ដោយប្រើប្រាស់ផែនការយុទ្ធសាស្ត្ររួមគ្នា ដូចជា សិក្ខាសាលា និងកិច្ចប្រជុំ
- ចូលរួមចំណែកយ៉ាងជាក់លាក់ក្នុងការកសាងសមត្ថភាពរបស់អង្គការយុវជន តាមរយៈកម្មវិធីបណ្តុះបណ្តាល
- ណែនាំបទពិសោធអនុវត្តល្អៗ ដើម្បីឱ្យពួកគេមានលទ្ធភាពកាន់តែកើនឡើងខ្លាំងជាងមុនក្នុងការងារអភិវឌ្ឍន៍យុវជន
- ធានាការគាំទ្រសម្រាប់គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជន
- ធ្វើសវនកម្មការផ្តួចផ្តើម និងគម្រោងនានាដែលពាក់ព័ន្ធនឹងយុវជន ដែលនៅក្រៅរដ្ឋាភិបាល ហើយដែលត្រូវធ្វើបច្ចុប្បន្នកម្មនៅក្នុងផែនទីបង្ហាញផ្លូវរបស់អង្គការសង្គមស៊ីវិល
- ស្តាប់ ចូលរួមពិគ្រោះយោបល់ និងស្វែងយល់អំពីការព្រួយបារម្ភរបស់យុវជន តាមរយៈសមាគមតំណាង និងការស្ទាបស្ទង់មតិនានា។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

មានការចូលរួមពីសំណាក់យុវជន និងសង្គមស៊ីវិលកាន់តែច្រើនជាងមុនក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។

*សូចនាករអនុវត្ត*

- កំណត់ហេតុអង្គប្រជុំនានា
- កម្រិតនៃការចូលរួមនិងការរួមចំណែករបស់រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីឆ្លើយតបនឹងតម្រូវការរបស់យុវជន
- ការចូលរួមរបស់យុវជននៅក្នុងកិច្ចដំណើរការអនុវត្តបន្តលើគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- ការធ្វើបច្ចុប្បន្នកម្មផែនទីបង្ហាញផ្លូវសកម្មភាពរបស់អង្គការសង្គមស៊ីវិល។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ផ្នែកអនុវត្តគោលនយោបាយ នៃអគ្គលេខាធិការដ្ឋាន **គ.ជ.យ.** ត្រូវគ្រប់គ្រងសកម្មភាពនេះ។

### ៣.១.៥- ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា

*គោលបំណងសកម្មភាព*

ផលិតនិងថែរក្សាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។

*ក្រុមគោលដៅរបស់សកម្មភាព*

អ្នកពាក់ព័ន្ធនឹងយុវជនទាំងអស់។

*កិច្ចការសំខាន់ៗ*

- ជំនួយបច្ចេកទេសត្រូវបានផ្តល់ដោយក្រុមបច្ចេកទេសពាក់ព័ន្ធ។
- សិក្ខាសាលានិងកិច្ចពិគ្រោះយោបល់។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

- ការប្រកាសនិងដាក់ឱ្យអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។
- ការប្រកាសនិងដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាលើកទី២។

*សូចនាករអនុវត្ត*

- ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវធ្វើកិច្ចពិគ្រោះយោបល់។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

**គ.ជ.យ.** គ្រប់គ្រងរាល់ទិដ្ឋភាពនៃការរៀបចំផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាដែលគាំទ្រដោយផ្នែកអនុវត្តគោលនយោបាយ។

### ៣.១.៦- ការតស៊ូមតិនៅក្នុងសភាជាតិ ក្រសួង ស្ថាប័ន និងថ្នាក់រាជធានី ខេត្ត

*គោលបំណងសកម្មភាព*

ទំនាក់ទំនងជាមួយអ្នកតាក់តែងច្បាប់និងអ្នករដ្ឋបាលនានា ដើម្បីពួកគេទទួលបាននូវទស្សនៈមួយឈានទៅរកការបង្កើត និងជាមធ្យោបាយឆ្ពោះទៅរកការអភិវឌ្ឍយុវជនប្រកបដោយប្រសិទ្ធភាព។ កិច្ចការនេះអាចសម្រេចទៅបាន តាមរយៈការវិភាគលើផលប៉ះពាល់របស់សំណើទាំងអស់ ដែលទំនងជាប៉ះពាល់លើយុវជន។

*ក្រុមគោលដៅរបស់សកម្មភាព*

អ្នកនយោបាយ និងអ្នកច្បាប់នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

*កិច្ចការសំខាន់ៗ*

- ការបង្កើតការិយាល័យក្រៅម៉ោងរបស់ **គ.ជ.យ.** នៅក្នុងសភាជាតិ
- ការបង្កើតទម្រង់នៃការវិភាគផលប៉ះពាល់គំរូ
- មន្ត្រីដែលមានសមត្ថភាពអនុវត្តការវិភាគផលប៉ះពាល់
- ការផលិតកញ្ចប់ព័ត៌មានសម្រាប់សមាជិកសភាជាតិនិងអ្នកដឹកនាំក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

បញ្ហាយុវជននឹងត្រូវទទួលបានការពិចារណា និងដាក់បញ្ចូលទៅក្នុងលិខិតបទដ្ឋានគតិយុត្ត។

*សូចនាករអនុវត្ត*

- សមាជិកសភាជាតិ អ្នកគ្រប់គ្រងរដ្ឋបាលនៅតាមក្រសួងស្ថាប័ន និងថ្នាក់ដឹកនាំរាជធានី ខេត្ត ត្រូវទទួលបាននូវព័ត៌មានពាក់ព័ន្ធយុវជន និងផលប៉ះពាល់របស់សេចក្តីព្រាងច្បាប់នានាដែលកំពុងជជែកពិភាក្សា ហើយប៉ះពាល់ការអភិវឌ្ឍយុវជន
- **គ.ជ.យ.** ទទួលបានការទទួលស្គាល់កាន់តែប្រសើរជាងមុនពីសំណាក់សភាជាតិនិងសមាជិកសភាជាតិ
- សមាមាត្រនៃលិខិតបទដ្ឋានគតិយុត្ត អំពីអ្វីដែលការវិភាគផលប៉ះពាល់ត្រូវបានអនុវត្ត។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

សកម្មភាពនេះគ្រប់គ្រងដោយប្រធាន **គ.ជ.យ.** គាំទ្រដោយផ្នែកការអនុវត្តគោលនយោបាយ និងត្រូវមានការិយាល័យនៅក្នុងសភាជាតិ។

### *៣.១.៧- ការស្រាវជ្រាវអំពីយុវជន*

*គោលបំណងសកម្មភាព*

- ផ្តល់នូវមូលដ្ឋាននៃការយល់ដឹងដ៏ទំលំទូលាយមួយពាក់ព័ន្ធនឹងបទពិសោធរបស់យុវជន ការរួមបញ្ចូលភាពចម្រុះនៃយេនឌ័រ ពិការភាព និងទីតាំងភូមិសាស្ត្រ
- ផ្តល់នូវក្របខណ្ឌនិងទស្សនៈមួយសម្រាប់ការសិក្សាស្រាវជ្រាវតាមវិស័យឱ្យកាន់តែស៊ីជម្រៅ ក៏ដូចជាការស្រាវជ្រាវអំពីបញ្ហានានារបស់ក្រុមគោលដៅ និង
- ផ្តល់នូវក្របខណ្ឌមួយសម្រាប់បញ្ជ្រាបការងារយុវជនទៅក្នុងក្រសួង ស្ថាប័ននានាដែលធ្វើការងារប្រមូល និងវិភាគព័ត៌មាន។

*ក្រុមគោលដៅរបស់សកម្មភាព*

អ្នកគ្រប់គ្រងព័ត៌មាននិងអ្នកប្រមូលព័ត៌មាន។

*កិច្ចការសំខាន់ៗ*

- ឯកសារយោងនានា រួមមាន វិស័យស្រាវជ្រាវ វិធីសាស្ត្រ គំរូស្ទាប់ស្ទង់មតិ។ល។
- ការត្រួតពិនិត្យនិងគ្រប់គ្រងការស្រាវជ្រាវដែលមានស្រាប់
- ការកំណត់អំពីការស្រាវជ្រាវដែលត្រូវទទួលការអនុញ្ញាត
- ការអនុញ្ញាតឱ្យមានកម្មវិធីសម្រាប់ធ្វើការស្រាវជ្រាវ
- ការប្រជុំទ្វេភាគីជាមួយក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងវិទ្យាស្ថានស្ថិតិជាតិ ដើម្បីកសាងបាននូវការយល់ដឹងអំពីដំណើរការ នៃការតាក់តែងកម្រងសំណួរ និងការវិភាគពាក់ព័ន្ធនឹងយុវជនក្នុងការងារស្រាវជ្រាវរបស់ពួកគេ
- កិច្ចសហការជាមួយដៃគូអប់រំនិងអ្នកពាក់ព័ន្ធផ្សេងទៀត។

### លទ្ធផលរំពឹងទុកពីសកម្មភាព

លទ្ធផលស្រាវជ្រាវត្រូវបានបង្ហាញជូន **អ.ជ.យ.**។

### សូចនាករអនុវត្ត

- ចំនួនយុវជនដែលត្រូវបានធ្វើការស្ទាបស្ទង់មតិ
- ការកែសម្រួលគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ
- ការបោះពុម្ពផ្សាយ(អ៊ីនធឺណិត) ការស្រាវជ្រាវឯកសារ និងរបាយការណ៍ដែលទទួលបានការអនុញ្ញាត។

### ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត

ផ្នែកអនុវត្តគោលនយោបាយនៃអគ្គលេខាធិការដ្ឋាន **អ.ជ.យ.**ត្រូវពិនិត្យសកម្មភាពទាំងនេះ គ្រប់គ្រង និងសម្របសម្រួលជាមួយអ្នកស្រាវជ្រាវ។

## ៣.១.៨- ការពិនិត្យ កែសម្រួល និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារយុវជន

### គោលបំណងសកម្មភាព

កំណត់ភាពមិនស្របគ្នាឬការខ្វះខាតនានានៅក្នុងក្របខណ្ឌច្បាប់ គោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្ត ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះផលប៉ះពាល់លើយុវជន។

### ក្រុមគោលដៅរបស់សកម្មភាព

យុវជនទាំងអស់។

### កិច្ចការសំខាន់ៗ

ក្រុមពិនិត្យ កែសម្រួលច្បាប់ គោលនយោបាយ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធយុវជនត្រូវបានបង្កើតឡើងដោយមានតំណាងយេនឌ័រ ជនពិការ និងអ្នកតំណាងផលប្រយោជន៍ដទៃទៀត។ ក្រុមនេះត្រូវអភិវឌ្ឍកម្មវិធីការងារ និងធ្វើការស្ទាបស្ទង់មតិលើស្ថានភាពការងាររវាងច្បាប់ គោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តនានាដែលប៉ះពាល់យុវជន ព្រមទាំងធ្វើកិច្ចពិគ្រោះយោបល់ជាមួយ យុវជន និងក្រុមពាក់ព័ន្ធដទៃទៀតស្តីពីបញ្ហាការងារទាំងនេះ។

### លទ្ធផលរំពឹងទុកពីសកម្មភាព

ឯកសារច្បាប់ គោលនយោបាយ និង/ឬលិខិតបទដ្ឋានគតិយុត្តផ្លូវការត្រូវបានចែករំលែក។

### សូចនាករអនុវត្ត

- ចំនួនអង្គការយុវជន ក្រុមទទួលផលប្រយោជន៍ អង្គការក្រៅរដ្ឋាភិបាល និងក្រសួង ស្ថាប័ន ត្រូវបានធ្វើការពិភាក្សា
- ចំនួននៃការឆ្លើយតបចំពោះគោលនយោបាយ
- ចំនួននៃការងារដែលត្រូវបានត្រួតពិនិត្យកែសម្រួលដោយក្រុម
- ការផលិតនិងការទទួលយកគោលនយោបាយដោយរាជរដ្ឋាភិបាល។

### ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត

**អ.ជ.យ.** គ្រប់គ្រងសកម្មភាពនិងជាប្រធានក្រុមកែសម្រួលត្រួតពិនិត្យច្បាប់យុវជន គាំទ្រដោយផ្នែកអនុវត្តគោលនយោបាយ។

## ៣.១.៩- ការអភិវឌ្ឍធនធានមនុស្ស

### គោលបំណងសកម្មភាព

ធានាបានអ្នកធ្វើការងារយុវជននិងមន្ត្រីគាំទ្រយុវជនដែលមានជំនាញ និងទទួលបានការបណ្តុះបណ្តាល។

*ក្រុមគោលដៅរបស់សកម្មភាព*

មន្ត្រីទាំងអស់ដែលធ្វើការងារជាមួយ និងសម្រាប់យុវជន។

*កិច្ចការសំខាន់ៗ*

- **គ.ជ.យ.**នឹងជួបជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំរបៀបរបបការងារសម្រាប់ឱ្យដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធ
- **គ.ជ.យ.** និងអ្នកពាក់ព័ន្ធនឹងកំណត់នូវលក្ខខណ្ឌ និងលក្ខណសម្បត្តិក្នុងការជ្រើសរើសសិក្ខាកាម ដើម្បីចូលរួមទទួលការបណ្ដុះបណ្ដាលនាពេលអនាគត
- **គ.ជ.យ.** នឹងជួបជាមួយតំណាងក្រសួងអប់រំ យុវជន និងកីឡា តំណាងក្រសួងការងារនិងបណ្ដុះ-បណ្ដាលវិជ្ជាជីវៈដើម្បីបង្កើតនូវមធ្យោបាយជួយនិងទទួលស្គាល់អ្នកធ្វើការងារយុវជនមានលក្ខណៈអាជីពប្រព្រឹត្តទៅបានដោយមានលក្ខណៈស្របទៅនឹងក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា
- រៀបចំផែនការលម្អិតសម្រាប់ការបណ្ដុះបណ្ដាលមន្ត្រីអគ្គលេខាធិការដ្ឋាន **គ.ជ.យ.**។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

អ្នកធ្វើការងារយុវជននិងមន្ត្រីគាំទ្រយុវជនដែលមានប្រសិទ្ធភាពនិងប្រសិទ្ធផលនៅក្នុងអគ្គលេខាធិការ-ដ្ឋានមានចំនួនកើនឡើង។

*សូចនាករអនុវត្ត*

- ផែនការស្ដីពីការកសាងសមត្ថភាពត្រូវបានរៀបចំជាសេចក្ដីព្រាង
- វគ្គបណ្ដុះបណ្ដាលខ្លីៗត្រូវបានរៀបចំធ្វើ
- ការទទួលស្គាល់ជាផ្លូវការចំពោះការងារយុវជនដែលមានដោយក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា និងចំនួននៃការទទួលបានគុណវុឌ្ឍ
- របាយការណ៍អំពីការវាយតម្លៃការផ្លាស់ប្ដូរនៅក្នុងប្រសិទ្ធផលនៃការងារយុវជន។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ផ្នែកអនុវត្តគោលនយោបាយរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ជាអ្នកសម្របសម្រួលសកម្មភាពទាំងនេះ។

### *៣.១.១០- ការកៀរគរធនធាន*

ដើម្បីឱ្យការអនុវត្តផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា សម្រេចបានដោយជោគជ័យ ការផ្ដល់មូលនិធិគឺជារឿងសំខាន់។ បន្ថែមពីលើមូលនិធិដែលផ្ដល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានតម្រូវការមូលនិធិបន្ថែមសម្រាប់សកម្មភាពនានាជាច្រើន។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកៀងគរធនធានសម្រាប់ការអភិវឌ្ឍយុវជន **គ.ជ.យ.** ត្រូវរៀបចំសន្និសីទម្ចាស់ជំនួយការអភិវឌ្ឍយុវជនប្រចាំឆ្នាំ។

*គោលបំណងសកម្មភាព*

សន្និសីទម្ចាស់ជំនួយនឹងផ្ដល់នូវឱកាសសម្រាប់៖

- អង្គការយុវជន ដើម្បីធ្វើការបកស្រាយបង្ហាញពីការងាររបស់ខ្លួន និងកំណត់នូវផ្នែកនានាដែលត្រូវការជំនួយពីម្ចាស់ជំនួយ
- អតីតអ្នកស្ម័គ្រចិត្តនិងអ្នកទទួលផលប្រយោជន៍នៃកម្មវិធីពីមុនកន្លងមក ដើម្បីបកស្រាយបង្ហាញអំពីផលប្រយោជន៍ដែលពួកគេបានទទួលកន្លងមក
- រំលេចនូវផ្នែកដែលត្រូវពង្រីកការងារនិងត្រូវការជំនួយបន្ថែមដូចបានកំណត់នៅក្នុងគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា

- អង្គការម្ចាស់ជំនួយ ដើម្បីបកស្រាយបង្ហាញអំពីចំណាប់អារម្មណ៍ ក្តីព្រួយបារម្ភ សេចក្តីប្រាថ្នារបស់ពួកគេនៅពេលដែលពួកគេធ្វើការផ្តល់មូលនិធិដល់សកម្មភាពអភិវឌ្ឍយុវជន
- ណែនាំអំពីអង្គការយុវជនដល់ម្ចាស់ជំនួយពាក់ព័ន្ធ និង
- ការសម្របសម្រួលសកម្មភាពអភិវឌ្ឍយុវជន។

*ក្រុមគោលដៅរបស់សកម្មភាព*

អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ទីភ្នាក់ងារម្ចាស់ជំនួយ និងអ្នកឧបត្ថម្ភដែលជាអ្នកជំនួញកម្ពុជា និងមានសក្តានុពលនាពេលបច្ចុប្បន្ន។

*កិច្ចការសំខាន់ៗ*

រៀបចំសន្និសីទម្ចាស់ជំនួយ។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

- ការយល់ដឹងរវាងម្ចាស់ជំនួយនិងអ្នកទទួលជំនួយអំពីការរំពឹងទុកនិងតម្រូវការពីគ្នាទៅវិញទៅមក មានភាពច្បាស់លាស់និងប្រសើរឡើង។
- ការផ្តល់មូលនិធិបន្ថែមមានការកើនឡើង។

*សូចនាករអនុវត្ត*

- ចំនួននៃប្រតិភូសន្និសីទ
- ការយល់ដឹងប្រសើរជាងមុននៅក្នុងចំណោមអង្គការយុវជនអំពីចំណាប់អារម្មណ៍និងលក្ខខណ្ឌនានារបស់ម្ចាស់ជំនួយ
- ការយល់ដឹងប្រសើរជាងមុនក្នុងចំណោមទីភ្នាក់ងារម្ចាស់ជំនួយអំពីតម្រូវការនិងឱកាសនៃការអភិវឌ្ឍ និងការទទួលបានមូលនិធិផ្គត់ផ្គង់ការអភិវឌ្ឍ។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

**ក.ជ.យ.** (ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ) សម្របសម្រួលនិងគ្រប់គ្រងសន្និសីទដោយមានការគាំទ្រពីគណៈកម្មាធិការរៀបចំតូចមួយដែលមានតំណាងមកពី **ក.ជ.យ.** អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារមួយចំនួន ក៏ដូចជាអ្នកឧបត្ថម្ភដែលជាអ្នកជំនួញកម្ពុជា។

## ៣.២- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី២ : លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព

សកម្មភាពចំនួន១១ ត្រូវបានកំណត់ដោយ **ក.ជ.យ.** រួមមាន(១) សាលារៀនជាទីកន្លែងមូលដ្ឋានសម្រាប់រៀនសូត្រ តាមរយៈការអប់រំប្រកបដោយគុណភាព (២) យុវជនទទួលបាននូវគុណវុឌ្ឍិខ្ពស់ (៣) ឱកាសទទួលបានការអប់រំលើកទីពីរ (៤) ការអភិវឌ្ឍលទ្ធភាពទទួលបានការសិក្សាបន្តឬការសិក្សាពេញមួយជីវិត (៥) ការគាំទ្រយុវជននៅពេលពួកគេកំពុងឈានចូលពេញវ័យ (៦) សម្ភារៈនិងមធ្យោបាយបម្រើឱ្យយុវជនក្នុងសហគមន៍ (៧) ការពង្រីកមហាវិទ្យាល័យនៅតាមសហគមន៍និងមជ្ឈមណ្ឌលយុវជនសម្រាប់យុវជនក្រៅសាលា ជាពិសេស យុវជនពិការ ដើម្បីឱ្យពួកគេមានឱកាសបានចូលរួមយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ (៨) ប្រាក់កម្ចីសិក្សាសម្រាប់សិស្សនិងនិស្សិត (៩) ភាពជាតំណាងយុវជន (១០) ការលើកកម្ពស់បណ្តាញការងារនិងគំរូនៅក្នុងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និង(១១) ព័ត៌មានវិទ្យានិងការអប់រំពីចម្ងាយ។ សកម្មភាពនីមួយៗ មានលក្ខណៈដូចតទៅៈ

### ៣.២.១- សាលារៀនជាទីកន្លែងមូលដ្ឋានសម្រាប់រៀនសូត្រ តាមរយៈការអប់រំមានគុណភាព

*គោលបំណងសកម្មភាព*

- គុណភាពនិងភាពពាក់ព័ន្ធនៃការអប់រំមានការកើនឡើង
- ការលើកកម្ពស់សេវាកម្មសុខភាព ការអប់រំសុខភាព និងបច្ចេកទេសធ្វើផែនការគ្រួសារ
- ការចុះឈ្មោះចូលរៀនរបស់យុវជននៅកម្រិតមធ្យមសិក្សានិងឧត្តមសិក្សាមានការកើនឡើង។

*ក្រុមគោលដៅរបស់សកម្មភាព*

សិស្សជាយុវជននៅក្នុងសាលា រួមទាំងយុវជនពិការ។

*កិច្ចការសំខាន់ៗ*

- ការពិនិត្យកែសម្រួលកម្មវិធីសិក្សា
- ការពង្រឹងគុណភាពអប់រំ
- ការផ្តល់ព័ត៌មានសម្រាប់សិស្សឱ្យមានភាពប្រសើរជាងមុន
- ការបង្កើតបាននូវឧត្តមភាពនៅក្នុងសហគមន៍ដែលងាយរងគ្រោះ។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

តាមរយៈសកម្មភាពនេះ គេរំពឹងថា យុវជននៅក្នុងសាលានិងក្រៅសាលា និងយុវជនមានការងារធ្វើនៅក្នុងវិស័យសាធារណៈនិងឯកជន នឹងទទួលបានចំណេះដឹងបន្ថែមអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជានិងប្រើប្រាស់រចនាសម្ព័ន្ធ និងកម្មវិធីអប់រំឱ្យអស់លទ្ធភាព ខណៈពេលដែលពួកគេត្រូវទទួលខុសត្រូវអំពីអត្តចរិតនិងអាកប្បកិរិយារបស់ពួកគេចំពោះសហគមន៍។

*សូចនាករអនុវត្ត*

- ការបង្កើតនិងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨
- អត្រាភាគរយខ្ពស់នៃចំនួនយុវជនបានចុះឈ្មោះគ្រប់ភូមិសិក្សា
- កម្មវិធីសិក្សាជាតិដែលមានបច្ចុប្បន្នកម្មនៅគ្រប់ភូមិសិក្សា
- គណៈគ្រប់គ្រងសាលារៀនដែលបង្ហាញនូវចំណាប់អារម្មណ៍និងការប្តេជ្ញាចិត្តចំពោះការអប់រំយុវជន
- ភាពប្រសើរឡើងនៃគុណភាពអប់រំ ដូចបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធានាសកម្មភាពនេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

### ៣.២.២- យុវជនទទួលបាននូវគុណវុឌ្ឍិខ្ពស់

*គោលបំណងសកម្មភាព*

- ការបែងចែកកម្មវិធី និងស្ថាប័នអប់រំជំនាញ ដើម្បីបម្រើតាមតម្រូវការរបស់យុវជនពិការ
- ធានាថា តម្រូវការនានារបស់យុវជនទាំងផ្នែកសង្គមនិងបរិស្ថាននៅក្នុងប្រព័ន្ធអប់រំនិងបណ្តុះ-បណ្តាលត្រូវបានឆ្លើយតប រួមមាន សំណង់ ស្ថាបត្យកម្ម និងរចនាសម្ព័ន្ធដែលមានផលប៉ះពាល់លើយុវជនពិការ ដើម្បីពួកគេអាចទាញយកប្រយោជន៍បានយ៉ាងពេញលេញពីកំណែទម្រង់នានានៅក្នុងវិស័យនេះ
- ធានាឱ្យមានឱកាសទទួលបានការអប់រំស្មើៗគ្នា ដោយមិនប្រកាន់ភេទ សាវតារ សាសនា តំបន់ភូមិសាស្ត្រ ឬឋានៈសង្គម ឬ សេដ្ឋកិច្ចឡើយ
- កែទម្រង់កម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិនិងឧត្តមសិក្សា ដោយផ្អែកលើទស្សនៈវិស័យបង្កើតឱ្យមានភាពស៊ីចង្វាក់គ្នារវាងការអប់រំក្នុងប្រព័ន្ធនិងតម្រូវការលក្ខខណ្ឌទីផ្សារការងារក៏ដូចជា ទំនាក់ទំនងដែលសមស្របរវាងគ្រឹះស្ថានឧត្តមសិក្សានិងឧស្សាហកម្ម
- បង្កើតឱ្យមានគំរូស្តង់ដាជាតិអប់រំទាំងក្នុងកម្មវិធីអប់រំក្នុងនិងក្រៅប្រព័ន្ធដើម្បីលើកកម្ពស់គុណភាព។

### ក្រុមគោលដៅរបស់សកម្មភាព

យុវជនដែលជាសិស្សនៅតាមសាលារៀននិងធ្វើការងារនៅក្នុងវិស័យសាធារណៈនិងឯកជន នៅក្រៅសាលារៀន ជាពិសេស យុវជនពិការ និងយុវជនមកពីសហគមន៍ជនជាតិភាគតិច ស្រឡាញ់ភេទដូចគ្នា ស្រឡាញ់ភេទទាំងពីរនិងប្តូរភេទ។

### កិច្ចការសំខាន់ៗ

- ការអភិវឌ្ឍការអប់រំជំនាញសម្រាប់យុវជនពិការ
- ការធ្វើសនវកម្មនិងផែនការសកម្មភាព ដើម្បីធានាឱ្យមានអគារសិក្សាដែលយុវជនពិការអាចប្រើប្រាស់បាន
- គុណភាពនៃផែនការនិងសកម្មភាពកែលម្អការអប់រំ
- ការអភិវឌ្ឍការធានាឱកាសទទួលបាននានា។

### លទ្ធផលរំពឹងទុកពីសកម្មភាព

យុវជននៅក្នុងសាលារៀននិងនៅក្រៅសាលារៀន ដែលមានការងារធ្វើនៅតាមវិស័យសាធារណៈនិងឯកជននឹងទទួលបានចំណេះដឹងបន្ថែមស្តីពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាពលរដ្ឋកម្ពុជា ក៏ដូចជាអាចទទួលប្រយោជន៍នានាយ៉ាងពេញលេញពីរចនាសម្ព័ន្ធនិងកម្មវិធីអប់រំដែលមានស្រាប់ក្នុងពេលដែលពួកគេត្រូវទទួលខុសត្រូវចំពោះឥរិយាបថនិងអាកប្បកិរិយារបស់ពួកគេនៅក្នុងសហគមន៍។

### សូចនាករអនុវត្ត

- ភាគរយនៃចំនួនយុវជនដែលទទួលបានគុណវុឌ្ឍិវិជ្ជាជីវៈ
- ភាគរយនៃចំនួនយុវជនដែលបានបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ
- អត្រារួមនៃការសិក្សាគ្រប់ភូមិសិក្សា
- កម្មវិធីសិក្សាដែលមានបច្ចុប្បន្នកម្មសម្រាប់គ្រប់ភូមិសិក្សា
- ភាគរយនៃអគារសិក្សាដែលយុវជនពិការអាចប្រើប្រាស់បាន។

### ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត

ក្រសួងអប់រំ យុវជន និងកីឡាធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធានាការអនុវត្តសកម្មភាពនេះឱ្យមានប្រសិទ្ធភាព។

## ៣.២.៣- ឱកាសទទួលបានការអប់រំលើកទីពីរ

### គោលបំណងសកម្មភាព

- ឆ្លើយតបទៅនឹងបញ្ហានានាដែលយុវជននៅក្រៅប្រព័ន្ធអប់រំប្រឈម ដើម្បីធានាថាក្រុមយុវជននេះទទួលបានឱកាសថ្មីនានា ដើម្បីចូលរួមក្នុងការអប់រំនិងបណ្តុះបណ្តាល
- ការពង្រីកកម្មវិធីអក្ខរកម្មក្រៅប្រព័ន្ធ ដើម្បីទាក់ទាញយុវជន ក៏ដូចជាមនុស្សពេញវ័យ។

### ក្រុមគោលដៅរបស់សកម្មភាព

យុវជនមានការងារធ្វើនៅក្នុងវិស័យសាធារណៈ និងឯកជន និងយុវជនគ្មានការងារធ្វើនៅក្រៅប្រព័ន្ធអប់រំ ជាពិសេស យុវជនពិការ។

### កិច្ចការសំខាន់ៗ

- ពិនិត្យកែសម្រួលនិងអភិវឌ្ឍកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ
- អភិវឌ្ឍមធ្យោបាយនិងដំណោះស្រាយដែលមានភាពទន់ភ្លន់ ហើយយុវជនអាចចាប់ផ្តើមទទួលការអប់រំសារជាថ្មីពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

យុវជននៅក្នុងសាលា យុវជននៅក្រៅសាលា និងយុវជនមានការងារធ្វើនៅក្នុងវិស័យសាធារណៈនិងឯកជន នឹងទទួលបានចំណេះដឹងអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាទទួលបាននូវប្រយោជន៍នានាយ៉ាងពេញលេញពីរចនាសម្ព័ន្ធ និងកម្មវិធីអប់រំដែលមាន ខណៈពេលដែលពួកគេត្រូវទទួលខុសត្រូវចំពោះឥរិយាបថ និងអាកប្បកិរិយាក្នុងសហគមន៍ខ្លួន។

*សូចនាករអនុវត្ត*

- ចំនួនយុវជនត្រឡប់មករកការអប់រំវិញបន្ទាប់ពីចាកចេញពីសាលារៀន
- កម្មវិធីសិក្សាជាតិដែលមានបច្ចុប្បន្នភាពនៅគ្រប់កម្រិតនិងភូមិសិក្សា រួមមានគុណវុឌ្ឍការបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅក្រោមក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងអប់រំ យុវជន និងកីឡានឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល និងក្រសួង ស្ថាប័នពាក់ព័ន្ធទៃទៀត ដើម្បីធានាថាសកម្មភាពនេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

### ៣.២.៤- ការអភិវឌ្ឍលទ្ធភាពទទួលបានការសិក្សាបន្តឬការសិក្សាពេញមួយជីវិត

*គោលបំណងសកម្មភាព*

- ការគ្របដណ្ដប់កាន់តែធំឡើងនៃការអប់រំក្រៅប្រព័ន្ធតាមទម្រង់ជាច្រើនទៅលើយុវជន
- ការគាំទ្រយុវជនដើម្បីក្រេបយកចំណេះដឹងខ្ពស់ជាងមុនដើម្បីទីផ្សារការងារនិងការបន្តការសិក្សា
- បង្កើតប្រព័ន្ធអប់រំក្នុងនិងក្រៅប្រព័ន្ធដែលមានប្រសិទ្ធភាពជាងមុននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជនដែលមានការងារធ្វើនៅក្នុងវិស័យសាធារណៈនិងឯកជន និងយុវជនដែលគ្មានការងារធ្វើនៅក្រៅសាលារៀន ជាពិសេស យុវជនពិការ។

*កិច្ចការសំខាន់ៗ*

- ជម្រើសនៃការផ្ដត់ផ្គង់មូលនិធិបន្ថែមត្រូវបានបង្កើត
- ផែនការសម្រាប់ការអភិវឌ្ឍសិល្បៈសហគមន៍និងមជ្ឈមណ្ឌលយុវជន។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

យុវជននៅក្នុងសាលា យុវជននៅក្រៅសាលា និងយុវជនមានការងារធ្វើនៅក្នុងវិស័យសាធារណៈនិងឯកជន នឹងទទួលបានចំណេះដឹងអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាទទួលបាននូវប្រយោជន៍នានាយ៉ាងពេញលេញពីរចនាសម្ព័ន្ធ និងកម្មវិធីអប់រំដែលមាន ខណៈពេលដែលពួកគេត្រូវទទួលខុសត្រូវចំពោះឥរិយាបថនិងអាកប្បកិរិយាក្នុងសហគមន៍ខ្លួន។

*សូចនាករអនុវត្ត*

- ឱកាសកើនឡើងសម្រាប់យុវជននៅក្នុងការអប់រំក្រៅប្រព័ន្ធនិងក្នុងប្រព័ន្ធ
- ប្រភពមូលនិធិបន្ថែមសម្រាប់យុវជននៅក្នុងការអប់រំ ជាពិសេសយុវនារីដែលមានតម្រូវការពិសេស
- សិល្បៈសហគមន៍និងមជ្ឈមណ្ឌលយុវជន ត្រូវបានធ្វើផែនការបង្កើត/កំពុងដំណើរការបង្កើត/កំពុងប្រតិបត្តិ។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងអប់រំ យុវជន និងកីឡាធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល និងក្រសួង ស្ថាប័នពាក់ព័ន្ធទៃទៀត ដើម្បីធានាថាសកម្មភាពនេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

### ៣.២.៥- ការគាំទ្រយុវជននៅពេលពួកគេកំពុងឈានចូលពេញវ័យ

#### គោលបំណងសកម្មភាព

- ការកែលម្អការអប់រំវិជ្ជាជីវៈ តាមរយៈការធ្វើបំណែងចែកសម្ភារៈ និងឧបករណ៍បណ្តុះបណ្តាលដែលមានបច្ចុប្បន្នភាព និងអភិវឌ្ឍការផ្ទេរការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឱ្យស៊ីចង្វាក់គ្នា ហើយឆ្លើយតបនឹងតម្រូវការទីផ្សារការងារនៅកម្រិតថ្នាក់ជាតិនិងថ្នាក់រាជធានី ខេត្ត
- ការគាំទ្រដល់ការអភិវឌ្ឍកិច្ចសន្ទនាសង្គមនៅកម្រិតថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត រវាងតំណាងប្រព័ន្ធអប់រំ វិស័យឯកជន ដូចជា សភាពាណិជ្ជកម្ម និយោជក សហជីព និងវិស័យផ្សេងៗទៀត
- ការកែលម្អនិងការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធបណ្តុះបណ្តាល និងអនុវត្តការងារនៅកន្លែងធ្វើការសម្រាប់សិស្សមកពីសាលាវិជ្ជាជីវៈនិងនិស្សិតដទៃទៀត
- ផ្តល់ជំនួយដល់យុវជន សិស្សមធ្យមសិក្សានិងនិស្សិត ដើម្បីគ្រប់គ្រងអាជីពរបស់ពួកគេឱ្យបានយ៉ាងល្អនិងមានប្រសិទ្ធផល។

#### ក្រុមគោលដៅរបស់សកម្មភាព

- យុវជនដែលស្វែងរកការងារធ្វើ ជាពិសេស អ្នកដែលមិនអាចរៀនសូត្រក្នុងសាលាទៀត
- យុវជនក្នុងសាលារៀននិងយុវជនមានការងារធ្វើក្នុងវិស័យសាធារណៈនិងវិស័យឯកជន យុវជនគ្មានការងារធ្វើនៅក្រៅសាលារៀន ជាពិសេស ជនពិការ។

#### កិច្ចការសំខាន់ៗ

លើកកម្ពស់ឱកាសអប់រំបន្ត។

#### លទ្ធផលរំពឹងទុកពីសកម្មភាព

យុវជនក្នុងសាលារៀន ក្រៅសាលារៀន និងយុវជនមានការងារធ្វើនៅក្នុងវិស័យសាធារណៈនិងវិស័យឯកជន នឹងទទួលបានចំណេះដឹងអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាទទួលបាននូវប្រយោជន៍នានាយ៉ាងពេញលេញពីរចនាសម្ព័ន្ធនិងកម្មវិធីអប់រំដែលមាន ខណៈដែលពួកគេត្រូវទទួលខុសត្រូវចំពោះឥរិយាបថ និងអាកប្បកិរិយាក្នុងសហគមន៍ខ្លួន។

#### សូចនាករអនុវត្ត

- ការយល់ដឹងប្រសើរជាងមុនក្នុងចំណោមសិស្ស និស្សិត យុវជន និងសហគមន៍អំពីសេវាកម្មអប់រំ និងកម្មវិធីផ្សេងៗដទៃទៀត
- ការចូលរួមរបស់និយោជកនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបំពេញបានតាមតម្រូវការរបស់និយោជក
- ចំណេះដឹងអំពីផលប្រយោជន៍នៃការចុះឈ្មោះចូលរៀនបន្តនៅគ្រប់ផ្នែកទាំងអស់របស់ការអប់រំ។

#### ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មាធិការជាតិបណ្តុះបណ្តាល ទីភ្នាក់ងារជាតិមុខរបរនិងការងារ សង្គមស៊ីវិល និងអង្គភាពធុរកិច្ច។

### ៣.២.៦- សម្ភារៈនិងមធ្យោបាយបម្រើឱ្យយុវជនក្នុងសហគមន៍

#### គោលបំណងសកម្មភាព

- វាស់វែងការងារបង្កើតមជ្ឈមណ្ឌលយុវជនពហុបំណង
- បង្កើតបណ្តាញផែនការស្តីពីការអភិវឌ្ឍ និងថែរក្សាមជ្ឈមណ្ឌលយុវជនពហុបំណង
- បង្កើតគម្រោងសាកល្បងសម្រាប់ការអនុវត្តមជ្ឈមណ្ឌលយុវជនពហុបំណងនៅក្នុងរាជធានី ខេត្តនីមួយៗ។

*ក្រុមគោលដៅរបស់សកម្មភាព*

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាល។ **គ.ជ.យ.** និងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័នមានតួនាទីសម្របសម្រួលការងារនេះ។

*កិច្ចការសំខាន់ៗ*

- ក្រសួងដឹកនាំការងារសវនកម្មទីតាំងនិងបង្កើតក្រុមមួយក្នុងការពិភាក្សាជាមួយក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីពិនិត្យនិងកែសម្រួលការងារ
- ផែនការស្តីពីអភិវឌ្ឍ និងថែរក្សាមជ្ឈមណ្ឌលយុវជនពហុបំណង ត្រូវបានអនុម័ត
- ក្រសួងដឹកនាំការងារ សហការជាមួយអាជ្ញាធររាជធានី ខេត្តពាក់ព័ន្ធ ត្រូវកំណត់នូវវិស័យសម្រាប់ការសាកល្បងមជ្ឈមណ្ឌលយុវជនពហុបំណង
- ក្រសួងដឹកនាំការងារនឹងសម្របសម្រួលការធ្វើផែនការនិងការបង្កើតមជ្ឈមណ្ឌលយុវជនពហុបំណង។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

- សវនកម្មទីតាំងមជ្ឈមណ្ឌលយុវជនពហុបំណងដែលអាចមាន
- ការវាស់ស្ទង់លទ្ធផលការងារវិជ្ជមានលើការអភិវឌ្ឍមជ្ឈមណ្ឌលយុវជនពហុបំណង
- ផែនការការសាកល្បងមជ្ឈមណ្ឌលនិងពង្រាងផែនការ។

*សូចនាករអនុវត្ត*

- ការធ្វើសវនកម្មលើទីតាំងនានា
- ការងារគ្រប់គ្រងការអនុវត្តត្រូវបានកំណត់
- ផែនការមានសុពលភាព។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី។

### *៣.២.៧- ការពង្រីកកម្មវិធីអប់រំក្រោយមធ្យមសិក្សានិងមជ្ឈមណ្ឌលយុវជនសម្រាប់យុវជនក្រៅសាលា ជាពិសេស យុវជនពិការ ដើម្បីឱ្យពួកគេមានឱកាសបានចូលរួមយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ*

*គោលបំណងសកម្មភាព*

- សិស្សបានយល់ដឹងប្រសើរជាងមុនអំពីសិទ្ធិនិងទំនួលខុសត្រូវរបស់ពួកគេ និងសិទ្ធិរបស់អ្នកដទៃ កំណត់និងលើកកម្ពស់កម្មវិធីអប់រំក្រោយមធ្យមសិក្សា និងសហគមន៍គំរូដែលបានធ្វើការងារឆ្លើយតបនឹងតម្រូវការនិងផលប្រយោជន៍ជាក់លាក់របស់យុវជនក្រៅប្រព័ន្ធអប់រំ
- អភិវឌ្ឍកម្មវិធីអប់រំក្រោយមធ្យមសិក្សានិងសហគមន៍គំរូសម្រាប់យុវជនក្រៅប្រព័ន្ធអប់រំ និងយុវជនពិការតាមតំបន់ជនបទដាច់ស្រយាល
- ផ្តល់នូវគំរូនិងវិធីសាស្ត្រសម្រាប់ការបែងចែកជំនាញវិជ្ជាជីវៈ និងមុនទទួលបានការងារធ្វើដល់យុវជនក្រៅប្រព័ន្ធអប់រំ និងយុវជនពិការនៅតាមតំបន់ជនបទដាច់ស្រយាល
- ជំរុញនិងសម្របសម្រួលការងាររបស់យុវជនពិការ ជាពិសេស នៅតាមទីកន្លែងដែលមានការកម្រិតចំនួនជាផ្លូវការ។

*ក្រុមគោលដៅរបស់សកម្មភាព*

- យុវជននៅក្រៅប្រព័ន្ធអប់រំ
- យុវជនពិការ
- អ្នកប្រើប្រាស់គ្រឿងញៀន
- យុវជនមានបញ្ហាគ្រួសារឬពិការស្មារតី។

*កិច្ចការសំខាន់ៗ*

- ក្រសួងអប់រំ យុវជន និងកីឡាធានាថា ព័ត៌មានស្ដីពីសិទ្ធិពលរដ្ឋ សិទ្ធិអក្ខរកម្ម និងសិទ្ធិពិការភាព ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សា តាមរយៈគណៈកម្មការអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាជាតិ
- ក្រសួងអប់រំ យុវជន និងកីឡានឹងកំណត់មធ្យោបាយ ដើម្បីពង្រឹងសមត្ថភាពគណៈគ្រប់គ្រងសាលា និងធានាឱ្យមានការឆ្លើយតបបានគ្រប់គ្រាន់នូវបរិបទសាលារៀន
- **គ.ជ.យ.** នឹងតែងតាំងអ្នកសម្របសម្រួលគម្រោង១រូប រួមជាមួយនឹងផ្នែកអនុវត្តគោលនយោបាយរបស់ **គ.ជ.យ.** នឹងធ្វើការពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡានឹងអង្កេតលើកម្មវិធីសិក្សាបច្ចុប្បន្ន និងវិធីសាស្ត្របណ្តុះបណ្តាលប្រើប្រាស់ក្នុងកម្មវិធីអប់រំក្រោយមធ្យមសិក្សា និងសហគមន៍គំរូ
- អ្នកសម្របសម្រួលគម្រោងនឹងរៀបចំផែនការលម្អិតសម្រាប់គម្រោង
- វាយតម្លៃគម្រោង។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

- កម្មវិធីសិក្សាសមស្របសម្រាប់កម្មវិធីអប់រំក្រោយមធ្យមសិក្សា និងសហគមន៍គំរូ ត្រូវបានតាក់តែង និងសាកល្បង
- កម្មវិធីអប់រំក្រោយមធ្យមសិក្សា និងសហគមន៍គំរូមួយចំនួន សាងសង់រួចរាល់នៅខែធ្នូ ឆ្នាំ២០១៨
- តាមរយៈសកម្មភាពនេះ គេរំពឹងថា យុវជននៅក្នុងសាលារៀនទទួលបានចំណេះបន្ថែមអំពីសិទ្ធិ និងទំនួលខុសត្រូវរបស់ពួកគេក្នុងនាមជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា និងអាចទាញយកប្រយោជន៍បានពេញលេញពីរចនាសម្ព័ន្ធ សីលធម៌ពលរដ្ឋ ខណៈពេលត្រូវទទួលខុសត្រូវចំពោះឥរិយាបថ និងអាកប្បកិរិយារបស់ពួកគេចំពោះសង្គម
- ការងាររបស់យុវជនពិការកើនឡើង។

*សូចនាករអនុវត្ត*

- ការចុះឈ្មោះចូលរៀននៅកម្មវិធីអប់រំក្រោយមធ្យមសិក្សា និងសហគមន៍គំរូ របស់យុវជនក្រៅប្រព័ន្ធអប់រំ និងយុវជនពិការមកពីជនបទ
- វត្តមានកម្មវិធីសិក្សាការអប់រំពលរដ្ឋ នៅតាមសាលារៀន
- ការលើកកម្ពស់ចំណេះដឹងអំពីព័ត៌មាននិងទំនួលខុសត្រូវចំពោះសិទ្ធិពលរដ្ឋ សិទ្ធិអក្ខរកម្មនិងសិទ្ធិពិការភាពក្នុងចំណោមសិស្ស និស្សិត
- គណៈគ្រប់គ្រងសាលា បំពេញតួនាទីបង្ហាញអំពីផលប្រយោជន៍ និងការប្តេជ្ញាចិត្តចំពោះការអប់រំសិទ្ធិស៊ីវិល
- កម្រិតអត្រាអក្ខរកម្មរបស់យុវជនក្រៅប្រព័ន្ធអប់រំ និងយុវជនពិការ មានការកើនឡើង
- ចំនួននៃក្រសួង ស្ថាប័ន និងនិយោជកដែលគោរពបានតាមចំនួនកំណត់របស់និយោជិកពិការមានការកើនឡើង។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

**គ.ជ.យ.** ដោយមានកិច្ចពិភាក្សាយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា នឹងធ្វើការងារជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីធានាថា សកម្មភាពនេះត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។

### ៣.២.៨- ប្រាក់កម្ចីសិក្សាសម្រាប់សិស្សនិងនិស្សិត

*គោលបំណងសកម្មភាព*

អភិវឌ្ឍសំណើហិរញ្ញវត្ថុសិស្ស សម្រាប់ការអប់រំបន្តនៅឧត្តមសិក្សា។

*ក្រុមគោលដៅរបស់សកម្មភាព*

- យុវជននៅមធ្យមសិក្សាទុតិយភូមិ និងក្នុងសាកលវិទ្យាល័យ
- សាកលវិទ្យាល័យសាធារណៈដែលមានស្រាប់(ក្រសួងអប់រំ យុវជន និងកីឡាគាំទ្រដល់មជ្ឈមណ្ឌលគម្រោងអាហារូបករណ៍សិស្សនៅទូទាំងវិស័យ)។

*កិច្ចការសំខាន់ៗ*

- ចងក្រងគម្រោងហិរញ្ញវត្ថុសិស្សដែលមានស្រាប់ រួមមាន អាហារូបករណ៍ ប្រាក់ឧបត្ថម្ភការសិក្សា និងជំនួយឥតសំណងផ្សេងៗ
- អភិវឌ្ឍជម្រើសនានាសម្រាប់ការកើនឡើងទឹកប្រាក់ត្រូវបង់ពន្ធអាករ និងទម្រង់ហិរញ្ញវត្ថុផ្សេងៗ រួមគម្រោងផ្សេងៗទៀតដែលប្រសើរជាងនេះ
- កំណត់គុណវុឌ្ឍអាទិភាពដែលប្រសើរជាងមុននិងបន្ថែមទៀតដែលអាចទាក់ទាញអាហារូបករណ៍។ល។
- កិច្ចពិភាក្សាជាមួយសាកលវិទ្យាល័យ ស្ថាប័នឧត្តមសិក្សា និងជាមួយសមាគមធុរកិច្ចអំពីព័ត៌មានទីផ្សារការងារនិងការទស្សន៍ទាយផ្សេងៗ
- កិច្ចពិភាក្សាជាមួយអង្គការយុវជន សិស្ស និស្សិត និងអ្នកពាក់ព័ន្ធដទៃទៀត។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

សំណើហិរញ្ញវត្ថុសិស្ស ត្រូវបានអភិវឌ្ឍដើម្បីឆ្លុះបញ្ចាំងអំពីអាទិភាពជាតិ។

*សូចនាករអនុវត្ត*

សំណើត្រូវបានផលិតឡើង។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងអប់រំ យុវជន និងកីឡា នឹងអនុវត្តសកម្មភាពដែលបានលើកឡើងខាងលើដោយធ្វើការពិភាក្សាយ៉ាងជិតស្និទ្ធជាមួយ **គ.ជ.យ.**។ ទំហំការងារទាំងនេះ ពាក់ព័ន្ធនឹងកិច្ចពិភាក្សាជាមួយអង្គការ យុវជន សិស្ស និស្សិត សមាគមហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

### *៣.២.៩. ភាពជាតំណាងយុវជន*

*គោលបំណងសកម្មភាព*

លើកកម្ពស់គុណភាពនិងស្តង់ដាគុណវុឌ្ឍ។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជននៅក្នុងវិស័យអប់រំឧត្តមសិក្សា និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

*កិច្ចការសំខាន់ៗ*

- បង្កើតឱ្យមានភាពជាតំណាងយុវជននៅក្នុងអាជ្ញាធរគុណវុឌ្ឍកម្ពុជា
- ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រយុវជនដែលនឹងទៅធ្វើជាអ្នកតំណាងយុវជន
- បង្កើតយន្តការជ្រើសរើស/បោះឆ្នោត សម្រាប់ការជ្រើសរើសតំណាងយុវជន។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

យុវជនចូលរួមពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងវិស័យអប់រំ។

*សូចនាករអនុវត្ត*

- តំណាងយុវជនត្រូវបានបោះឆ្នោតជ្រើសរើស
- យុវជនចូលរួមនិងធ្វើវិភាគទានក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់អាជ្ញាធរគុណវុឌ្ឍជាតិ។

### *ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន។

## ៣.២.១០- ការលើកកម្ពស់បណ្ដាញការងារនិងគំរូនៅក្នុងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

### *គោលបំណងសកម្មភាព*

បង្កើនចំណេះដឹងនិងចំណាប់អារម្មណ៍នៅក្នុងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងចំណោមប្រជាជន។

### *ក្រុមគោលដៅរបស់សកម្មភាព*

សិស្សនៅមធ្យមសិក្សាទុតិយភូមិ និស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា យុវនារី និងយុវជនពិការ។

### *កិច្ចការសំខាន់ៗ*

- ក្រសួងអប់រំ យុវជន និងកីឡារៀបចំផែនការសកម្មភាពដើម្បីបង្កើតចំណេះដឹងនិងចំណាប់អារម្មណ៍ក្នុងចំណោមសិស្សសាលាផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ពានរង្វាន់យុវជនវិទ្យាសាស្ត្រ : ក្រសួងអប់រំ យុវជន និងកីឡាស្វែងរកក្រុមហ៊ុនឯកជនក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដើម្បីឧបត្ថម្ភ និងលើកកម្ពស់ការប្រគល់ពានរង្វាន់ប្រចាំឆ្នាំ។ កម្មវិធីពានរង្វាន់នេះ ជំរុញដល់ការចូលរួមពាក់ព័ន្ធរបស់យុវជននៅក្នុងវិស័យវិទ្យាសាស្ត្រ
- ការជំរុញក្លឹបវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជាពិសេស នៅក្នុងសាលារៀន។ ក្រសួងអប់រំ យុវជន និងកីឡារួមជាមួយមន្ទីរអប់រំ យុវជន និងកីឡាតាមរាជធានី ខេត្ត នឹងផ្តល់នូវកម្មវិធីគាំទ្រមួយសម្រាប់ការបង្កើតក្លឹបវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅក្នុងសាលារៀន រួមទាំងការគាំទ្រដល់គ្រូដែលដឹកនាំក្លឹបទាំងនោះ។ ក្លឹបទាំងនោះនឹងលើកកម្ពស់បណ្តាញមិត្តនិងក្រុមដែលមានចំណាប់អារម្មណ៍ចំពោះវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ក្រសួងអប់រំ យុវជន និងកីឡាពិភាក្សាជាមួយមហាវិទ្យាល័យ សាកលវិទ្យាល័យដើម្បីរិះរកមធ្យោបាយលើកកម្ពស់មុខវិជ្ជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព ក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សា។ ការងារនេះអាចរួមការធ្វើបទបង្ហាញអំពីកម្មវិធីនិងមុខរបរផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា តាមរយៈការតាំងពិព័រណ៍ និងការផ្តល់ប្រឹក្សាស្តីពីការសិក្សា និងការចាប់អាជីព ក៏ដូចជាការអភិវឌ្ឍវគ្គបំប៉នកម្រិតឧត្តមសិក្សាសម្រាប់និស្សិតដែលមានប្រវត្តិការសិក្សាមានកំណត់នៅក្នុងវិទ្យាល័យ។ ការងារនេះក៏ពាក់ព័ន្ធក្រុមហ៊ុនដែលពឹងផ្អែកលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាផងដែរ
- ក្រសួងអប់រំ យុវជន និងកីឡា និងទីភ្នាក់ងារជាតិមុខរបរ និងការងារ រៀបចំកូនសៀវភៅ រួមមានមុខរបរនៅក្នុងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់សិស្សនៅកម្រិតមធ្យមសិក្សា
- ក្រសួងអប់រំ យុវជន និងកីឡាធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម ដើម្បីជួយក្រុមហ៊ុនឯកជននាំចូល ឬផលិតឧបករណ៍ និងសម្ភារៈវិទ្យាសាស្ត្រសម្រាប់សាលារៀន។

### *លទ្ធផលរំពឹងទុកពីសកម្មភាព*

ចំណេះដឹងរបស់យុវជនអំពីវគ្គសិក្សាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងមុខរបរ មានការកើនឡើង។

### *សូចនាករអនុវត្ត*

- ចំនួនយុវជនមកពីក្រុមគោលដៅដែលបានឧទ្ទេសនាម ចូលរួមក្នុងពានរង្វាន់វិទ្យាសាស្ត្រយុវជន
- ចំនួនយុវជនមកពីក្រុមគោលដៅដែលបានឧទ្ទេសនាម ចូលរួមក្នុងក្លឹបវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ការបោះពុម្ពនិងចែកផ្សាយវគ្គសិក្សាវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងព័ត៌មានអំពីមុខរបរដល់សិស្សថ្នាក់ទី៧
- ចំនួនយុវជនមកពីក្រុមគោលដៅដែលបានឧទ្ទេសនាម ចុះឈ្មោះសិក្សាក្នុងកម្មវិធីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅឧត្តមសិក្សា។

***ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត***

ក្រសួងអប់រំ យុវជន និងកីឡា។

### ៣.២.១១- ព័ត៌មានវិទ្យានិងការអប់រំពីចម្ងាយ

***គោលបំណងសកម្មភាព***

បង្កនិងជំរុញឱ្យសហគមន៍ ជនបទ និងតំបន់ដាច់ស្រយាលមានលទ្ធភាពអាចទទួលបានសេវាកម្មបន្ថែមនៅក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលផ្សេងៗ។

***ក្រុមគោលដៅរបស់សកម្មភាព***

យុវជននៅតាមជនបទនិងតំបន់ដាច់ស្រយាល និងយុវជនដែលត្រូវការលទ្ធភាពទទួលបានការបណ្តុះបណ្តាលឬការអប់រំ។

***កិច្ចការសំខាន់ៗ***

ក្រសួងអប់រំ យុវជន និងកីឡា ទំនាក់ទំនង និងសហការជាមួយក្រុមនានាដូចជា សភាពាណិជ្ជកម្ម ធ្វើការអង្កេតលើវិធី និងមធ្យោបាយនានាដែលអាចបង្កើតលទ្ធភាពទទួលបានបច្ចេកវិទ្យាព័ត៌មានដើម្បីគាំទ្រដល់ការអប់រំ និងបណ្តុះបណ្តាលពីចម្ងាយ។

***លទ្ធផលរំពឹងទុកពីសកម្មភាព***

ការអភិវឌ្ឍលទ្ធភាពទទួលបានបច្ចេកវិទ្យាព័ត៌មាននៅតាមជនបទនិងតំបន់ដាច់ស្រយាល ដូចជាការផ្តល់និងបំពាក់សម្ភារៈ និងមធ្យោបាយគាំទ្រសម្រាប់អ្នកសិក្សាពីចម្ងាយ។

***សូចនាករអនុវត្ត***

- ការកំណត់អំពីតម្រូវការព័ត៌មាន និងការគាំទ្ររបស់អ្នកសិក្សាពីចម្ងាយ និងអ្នកនៅជនបទ
- ការអភិវឌ្ឍសំណើគម្រោងមួយអំពីសេវាកម្ម ការគ្រប់គ្រង និងលក្ខខណ្ឌហិរញ្ញវត្ថុសម្រាប់បង្កឱ្យមានលទ្ធភាពទទួលបច្ចេកវិទ្យាព័ត៌មាននៅក្នុងសហគមន៍។

***ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត***

ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ ក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្ម និងអង្គការមិនមែនរដ្ឋាភិបាលនិងនៅតាមសហគមន៍ផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន ឬការអប់រំពីចម្ងាយ។

## ៣.៣- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៣ : បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព

សកម្មភាពចំនួន៣ត្រូវបានកំណត់រួមមាន : (១) ការប្រឹក្សាយោបល់ស្តីពីសុខភាពយុវជន (២)ការយល់ដឹងអំពីយុវជននិងជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍ និង (៣) ការគាំទ្រយុវតីមានគភ៌ និងវត្តមានសិស្ស។ សកម្មភាពនីមួយៗ មានលក្ខណៈដូចតទៅ៖

### ៣.៣.១- ការប្រឹក្សាយោបល់ស្តីពីសុខភាពយុវជន

***គោលបំណងសកម្មភាព***

កែលម្អសេវាកម្មនិងព័ត៌មានសុខភាព រួមទាំងសុខភាពបន្តពូជ ដែលបម្រើដល់យុវជនឱ្យបានគ្រប់ជ្រុងជ្រោយ ដោយធ្វើការសហការជាមួយទីភ្នាក់ងារសំខាន់ៗដទៃទៀត។

***ក្រុមគោលដៅរបស់សកម្មភាព***

- យុវជនងាយរងគ្រោះដោយការធ្វើអត្តឃាត
- យុវជនប្រើប្រាស់គ្រឿងស្រវឹងនិងគ្រឿងញៀន

- យុវជនប្រកបរបរផ្លូវភេទ
- យុវជនមានបញ្ហាសុខភាពផ្លូវចិត្ត រួមទាំងយុវជនដែលទទួលរងវិបត្តិផ្លូវចិត្ត
- យុវជនមានជំងឺប្រចាំកាយរង់ចាំថ្ងៃស្លាប់
- យុវជនរស់នៅនិងធ្វើការនៅតាមដងផ្លូវ
- យុវជនពិការ
- យុវជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍
- សុខភាពបន្តពូជរបស់យុវជន។

*កិច្ចការសំខាន់ៗ*

- ប្រមូលព័ត៌មានអំពីយុវជននៅក្នុងក្រុមគោលដៅ តាមរយៈទីភ្នាក់ងារ និងអង្គការដែលសមស្រប
- ពិនិត្យកែសម្រួលសេចក្តីណែនាំ និងទម្រង់នានាដែលមានស្រាប់ (មិនមែនភាសាខ្មែរនិងមិនមានលាយលក្ខណ៍អក្សរ) ជាមួយក្រសួងសុខាភិបាល និងនាយកដ្ឋានសុខភាពសិក្សា និងកំណត់នូវតម្រូវការបច្ចុប្បន្ននានាប្រសិនបើមាន
- ធ្វើសេចក្តីណែនាំថ្មីៗពេលដែលចាំបាច់និងធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំដទៃទៀត ប្រសិនបើមានតម្រូវការ
- អភិវឌ្ឍនិងអនុវត្តផែនការផ្សព្វផ្សាយ តាមរយៈសេវាកម្មច្រកតែមួយ សាលារៀន មាតាបិតា អង្គការមិនមែនរដ្ឋាភិបាល សាកលវិទ្យាល័យ សម្ភារៈ និងមធ្យោបាយនៅតាមមជ្ឈមណ្ឌលយុវជនពហុបំណង។ ធ្វើការផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធព័ត៌មាននិងប្រព័ន្ធបណ្តាញសង្គម ទទួលយកមតិត្រឡប់ពីយុវជនតាមរយៈទូរស័ព្ទក្នុងកម្មវិធីវិទ្យុ។ ជានាថា ព័ត៌មានទាំងនោះទៅដល់សហគមន៍ដាច់ស្រយាល និងរបស់ជនជាតិភាគតិច និងក្រុមដទៃទៀត។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

- ព័ត៌មានប្រសើរជាងមុនទៅដល់យុវជនពាក់ព័ន្ធនឹងបញ្ហាសុខភាពសំខាន់ៗ នៅទូទាំងប្រទេស
- សេវាកម្មសុខភាពដែលប្រសើរជាងមុន ឆ្លើយតបនឹងតម្រូវការផ្នែកសុខភាពរបស់យុវជន។

*សូចនាករអនុវត្ត*

- ការទទួលបានព័ត៌មានប្រសើរជាងមុនរបស់ក្រុមគោលដៅសំខាន់ៗ
- ការផលិតសេចក្តីណែនាំនិងការផ្តល់ប្រឹក្សាយោបល់ថ្មីៗឬមានបច្ចុប្បន្នកម្ម
- ចំណេះដឹងស្តីពីសុខភាពមានភាពប្រសើរជាងមុនក្នុងចំណោមយុវជន
- លទ្ធភាពទទួលបានព័ត៌មានសុខភាព មានភាពប្រសើរជាងមុន។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងសុខាភិបាលធ្វើការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការយុវជន អង្គការមិនមែនរដ្ឋាភិបាលដែលជាអ្នកផ្តល់សេវាកម្មសុខភាព និងបុគ្គលិក និងអង្គការនៅតាមសហគមន៍នានាដែលធ្វើការជាមួយយុវជន។

### ៣.៣.២- ការយល់ដឹងរបស់យុវជនអំពីជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍

*គោលបំណងសកម្មភាព*

កែលម្អលទ្ធភាពទទួលបានព័ត៌មាននិងសេវាកម្មការពារ និងព្យាបាលជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍សម្រាប់យុវជន។ កាត់បន្ថយការរីករាលដាលចម្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ ក្នុងចំណោមយុវជន ជាពិសេស ចំនួនប្រជាជនសំខាន់ៗដែលមានវ័យជាយុវជន។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជន អង្គការយុវជន អង្គការមេរោគអេដស៍ ជំងឺអេដស៍ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធ រួមមាន ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា អង្គការសាសនា អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ អង្គការនៅតាមសហគមន៍ និងអង្គភាពក្រុមហ៊ុននានាក្នុងវិស័យឯកជន។

*កិច្ចការសំខាន់ៗ*

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងពិភាក្សាជាមួយយុវជន អង្គការយុវជន អង្គការនៅតាមសហគមន៍ អង្គការក្រៅរដ្ឋាភិបាល។ល។ ដើម្បីធានាប្រសិទ្ធភាពកម្មវិធីនិងផ្តោតលើការប្រមូលយុវជន
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ជាតិនឹងពិនិត្យកែសម្រួលការស្រាវជ្រាវដែលមានស្រាប់អំពីយុវជន និងកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍រៀបចំសេចក្តីសង្ខេបទំនាក់ទំនងមួយ សម្រាប់យុទ្ធនាការព័ត៌មានសាធារណៈពាក់ព័ន្ធនឹងយុវជន ជំងឺកាមរោគ និងជំងឺអេដស៍។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

ចំណេះដឹងកាន់តែប្រសើរនិងច្រើនឡើងជាងមុនក្នុងចំណោមយុវជននិងអង្គការយុវជន អំពីបទពិសោធនិងបញ្ហានានាដែលយុវជនប្រឈមពាក់ព័ន្ធនឹងជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍។

*សូចនាករអនុវត្ត*

- ចំនួនយុវជននិងអង្គការយុវជនដែលត្រូវបានធ្វើការពិភាក្សាជាមួយមានការកើនឡើង
- ចំនួននៃអត្រាភាគរយប្រជាជនដែលបាននិងប្រមូលមកទទួលសេវាកម្ម ជាពិសេស ក្រុមដែលងាយស្រួលប្រមូល ជនពិការ ជនជាតិភាគតិច ជនងាយរងគ្រោះ អ្នកដែលនៅតំបន់ជនបទដាច់ស្រយាល ឬអ្នកដែលពិបាកក្នុងការប្រមូល
- ការកំណត់នូវបញ្ហាសំខាន់ៗដែលប៉ះពាល់ដល់យុវជន និងជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍
- ការផលិតនិងការអនុវត្តសេចក្តីសង្ខេបទំនាក់ទំនងសម្រាប់យុទ្ធនាការព័ត៌មានសាធារណៈ។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងពិនិត្យកែសម្រួលនិងអភិវឌ្ឍសំណើនេះ។

### ៣.៣.៣- ការគាំទ្រយុវតីមានគភ៌និងវត្តមានសិស្ស

*គោលបំណងសកម្មភាព*

បង្កើតនិងតាមដានយន្តការដែលធានាការពន្យល់បកស្រាយបានត្រឹមត្រូវ និងការអនុវត្តគោលនយោបាយស្តីពីការចូលរៀន ដោយផ្តោតលើសិស្សដែលមានគភ៌។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជនក្នុងសាលារៀន រចនាសម្ព័ន្ធគ្រប់គ្រងសាលារៀន ក្រសួង ស្ថាប័ន រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ អង្គការដៃគូ និងគណៈកម្មាធិការសមភាពយេនឌ័រ។

*កិច្ចការសំខាន់ៗ*

- ក្រសួងអប់រំ យុវជន និងកីឡាបង្កើតក្រុមការងារ ដែលមានតំណាងមកពីក្រសួងសុខាភិបាល ក្រុមប្រឹក្សាឆ្មប អង្គការមិនមែនរដ្ឋាភិបាល **ន.ជ.យ.** និងគណៈកម្មាធិការសមភាពយេនឌ័រ ដើម្បីពិនិត្យតាមដានការអនុវត្តសកម្មភាពនេះ។ ក្រុមការងារនឹងធ្វើការស្រាវជ្រាវដើម្បី៖

➢ កំណត់អំពីសារៈសំខាន់នៃបញ្ហាមានគភ៌ក្នុងវ័យសិក្សានិងបញ្ហានៅតាមមូលដ្ឋាន
➢ យល់ដឹងអំពីមូលហេតុនៃការអនុវត្តគោលនយោបាយស្តីពីការចូលរៀនមិនបានពេញលេញ
➢ កំណត់វិធានការដែលត្រូវការដើម្បីធានាថាកិច្ចការនេះត្រូវបានអនុវត្ត
➢ កំណត់ការគាំទ្រមុនសម្រាលកូន ដែលយុវនារីត្រូវការ។

- ក្រសួងអប់រំ យុវជន និងកីឡារៀបចំនិងអនុវត្តសិក្ខាសាលាមួយចំនួននៅតាមបណ្តារាជធានី ខេត្ត ដែលត្រូវធ្វើការកំណត់អំពីតម្រូវការដើម្បីឆ្លើយតបនឹងបញ្ហាសិស្សមានគភ៌វ័យក្មេង និងការអនុវត្តគោលនយោបាយស្តីពីការចូលរៀន
- ក្រសួងអប់រំ យុវជន និងកីឡាដោយមានការសហការជាមួយក្រសួងសុខាភិបាល **គ.ជ.យ.** និងគណៈកម្មាធិការសមភាពយេនឌ័រ នឹងរៀបចំឯកសារព័ត៌មាន ការអប់រំ និងទំនាក់ទំនង សម្រាប់ការបន្តចែកចាយដល់សាលារៀន។

### *លទ្ធផលរំពឹងទុកពីសកម្មភាព*

- ចំណេះដឹងមានការកើនឡើងក្នុងចំណោមសាលារៀន រួមមានលោកគ្រូ អ្នកគ្រូ និងរចនាសម្ព័ន្ធគ្រប់គ្រង ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់បានត្រឹមត្រូវចំពោះសិស្សមានគភ៌ និងមធ្យោបាយដើម្បីគាំទ្រសិស្សទាំងនេះឱ្យចូលរៀននិងបន្តការសិក្សារបស់ពួកគេ
- កាត់បន្ថយចំនួនយុវនារីដែលត្រូវបានបណ្តេញចេញពីសាលា ឬបោះបង់ការសិក្សាដោយសារមានគភ៌។

### *សូចនាករអនុវត្ត*

- ចំនួនសាលារៀនដែលអនុវត្តគោលនយោបាយជាតិស្តីពីសាលារៀនបានត្រឹមត្រូវមានការកើនឡើង
- ចំនួនសិស្សដែលត្រូវបណ្តេញចេញពីសាលារៀនដោយសារតែការមានគភ៌
- ការផលិតនិងចែកផ្សាយឯកសារព័ត៌មាន ការអប់រំ និងទំនាក់ទំនង។

### *ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងអប់រំ យុវជន និងកីឡា។

## *៣.៤- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៤ៈ បណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ*

សកម្មភាពចំនួន៦ត្រូវបានកំណត់រួមមាន (១) ការប្រឹក្សាយោបល់ស្តីពីមុខរបរនៅតាមសាលារៀន (២) សេវាកម្មប្រឹក្សាយោបល់ស្តីពីមុខរបរសម្រាប់យុវជន (៣) ការបង្កើតការងារសម្រាប់យុវជន (៤) ការតស៊ូមតិ និងភាពជាតំណាងយុវជននៅក្នុងស្ថាប័នរដ្ឋបាលនានា (៥) ការអប់រំយុវសហគ្រិនភាព និង (៦) ការផ្តួចផ្តើមការអភិវឌ្ឍយុវសហគ្រាសជាតិ។ សកម្មភាពនីមួយៗ មានលក្ខណៈដូចតទៅៈ

### *៣.៤.១- ការប្រឹក្សាយោបល់ស្តីពីមុខរបរនៅតាមសាលារៀន*

### *គោលបំណងសកម្មភាព*

ផ្តល់ឱ្យសិស្ស និស្សិតនូវព័ត៌មានស្តីពីជម្រើសមុខរបរ និងឱកាសការងារនានា ដែលអាចត្រូវនឹងចំណាប់អារម្មណ៍របស់ពួកគេឬពាក់ព័ន្ធនឹងពួកគេ។

### *ក្រុមគោលដៅរបស់សកម្មភាព*

សិស្ស និស្សិតនៅវិទ្យាល័យនិងសាកលវិទ្យាល័យ។

### *កិច្ចការសំខាន់ៗ*

- ក្រសួងនិងទីភ្នាក់ងារដឹកនាំការងារ វាស់ស្ទង់ព័ត៌មានអំពីការប្រឹក្សាយោបល់ស្តីពីមុខរបរដែលត្រូវផ្តល់ដល់សិស្ស និស្សិត និងតម្រូវការការបណ្តុះបណ្តាលនានាសម្រាប់បុគ្គលិក និងមន្ត្រីដែលជាអ្នកផ្តល់សេវា

- ក្រសួងនិងទីភ្នាក់ងារដឹកនាំការងារនឹងរៀបចំជាអនុសាសន៍ផ្តល់ជូនគណៈកម្មាធិការជាតិ កម្មវិធីសិក្សាអំពីមធ្យោបាយ និងវិធីសាស្ត្រនានាក្នុងការកែលម្អព័ត៌មានអំពីការប្រឹក្សាយោបល់ស្តីពីមុខរបរនៅក្នុងសាលារៀន។ របាយការណ៍ស្តីពីអនុសាសន៍ទាំងនេះនឹងត្រូវផ្ញើបញ្ជូនទៅ **គ.ជ.យ.**
- ក្រសួងនិងទីភ្នាក់ងារដឹកនាំការងារ ធ្វើការងារជាមួយស្ថាប័នឧត្តមសិក្សា ដើម្បីផ្សព្វផ្សាយព័ត៌មានលទ្ធផលការងារសម្រាប់សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សា
- ក្រសួងនិងទីភ្នាក់ងារដឹកនាំការងារ សហការជាមួយសមាគមនិយោជក នឹងលើកជាសំណើនានាដូចជារបៀបផ្តល់ជូនព័ត៌មានមានបច្ចុប្បន្នកម្មដល់សាលារៀន និងសាកលវិទ្យាល័យ។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

យុវជននៅតាមសាលារៀនទទួលបានព័ត៌មានអំពីមុខរបរដែលសមស្របជាមួយពួកគេ និងមានបច្ចុប្បន្នភាព ដែលឆ្លុះបញ្ចាំងទៅនឹងទំនោរនាពេលបច្ចុប្បន្នក្នុងទីផ្សារការងារ។

*សូចនាករអនុវត្ត*

- អនុសាសន៍របស់ក្រសួង និងទីភ្នាក់ងារដឹកនាំការងារ ត្រូវបានទទួលយក និងអនុម័តដោយគណៈ-កម្មាធិការជាតិកម្មវិធីសិក្សា
- ព័ត៌មានអំពីមុខរបរដែលមានបច្ចុប្បន្នកម្មអាចស្វែងរកបានដោយងាយនៅតាមសាលារៀននិងសាកលវិទ្យាល័យ ដែលឆ្លុះបញ្ចាំងអំពីទំនោរទីផ្សារការងារនាពេលបច្ចុប្បន្ន
- ព័ត៌មានអំពីលទ្ធផលមានការងារធ្វើត្រូវបានផ្សព្វផ្សាយសម្រាប់វិទ្យាល័យ និងស្ថាប័នឧត្តមសិក្សា
- ចំនួនអ្នកផ្តល់ប្រឹក្សាយោបល់អំពីមុខរបរដែលទទួលបានការបណ្តុះបណ្តាល។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងអប់រំ យុវជន និងកីឡាធ្វើការងារជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ទីភ្នាក់ងារជាតិមុខរបរនិងការងារ និងស្ថាប័នឧត្តមសិក្សា។

### *៣.៤.២- សេវាកម្មប្រឹក្សាយោបល់ស្តីពីមុខរបរសម្រាប់យុវជន*

*គោលបំណងសកម្មភាព*

អង្កេតនិងបង្កើតសេវាកម្មដែលផ្តល់ការប្រឹក្សាយោបល់ និងព័ត៌មានដល់យុវជននៅក្រៅប្រព័ន្ធអប់រំ ហើយអាចជាជំនួយដល់ពួកគេក្នុងការស្វែងរកការងារធ្វើ ឬទទួលការអប់រំ និងការបណ្តុះបណ្តាលបន្ត។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជនគ្មានការងារធ្វើនៅក្រៅប្រព័ន្ធអប់រំ រួមទាំងយុវជនរស់នៅតាមតំបន់ជនបទ។

*កិច្ចការសំខាន់ៗ*

- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំឯកសារពិភាក្សាលើការវាយតម្លៃមជ្ឈមណ្ឌលការងារ និងបញ្ហានានារបស់យុវជន និងការផ្តល់ប្រឹក្សាយោបល់អំពីមុខរបរ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ទីភ្នាក់ងារជាតិមុខរបរនិងការងារ ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សាកលវិទ្យាល័យ និងវិស័យឯកជន ដោយមានការគាំទ្រពី **គ.ជ.យ.** នឹងអង្កេតលើលទ្ធភាពនៃការបង្កើតសេវាកម្មប្រឹក្សាយោបល់យុវជនអំពីមុខរបរ។ ប្រសិនបើមានការបង្ហាញថាសេវាកម្មនេះអាចដំណើរការបង្កើតបានកម្មវិធីសេវាកម្មប្រឹក្សាយោបល់ជាតិយុវជនអំពីការងារ នឹងត្រូវរៀបចំឡើងដោយផ្តល់ការគាំទ្រជាក់ស្តែងសម្រាប់ការបង្កើត និងការគ្រប់គ្រងទីតាំងសេវាកម្មក្នុងមូលដ្ឋាននិងសេវាកម្មជាតិតាមប្រព័ន្ធអ៊ីនធឺណិតនិងប្រព័ន្ធទូរស័ព្ទ។
- ការសិក្សាអំពីលទ្ធភាព គួរផ្តោតលើៈ

➢ តម្រូវការបណ្តុះបណ្តាលសម្រាប់មន្ត្រីបុគ្គលិកផ្តល់ប្រឹក្សាយោបល់អំពីមុខរបរផ្សារភ្ជាប់ និងតម្រូវការបណ្តុះបណ្តាលសម្រាប់អ្នកផ្តល់ប្រឹក្សាយោបល់នៅតាមសាលារៀន

➢ ការអភិវឌ្ឍសៀវភៅណែនាំអំពីការផ្តល់ការប្រឹក្សាយោបល់អំពីមុខរបរ ឬឯកសារបណ្តុះបណ្តាល។

- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការគាំទ្រពី **អ.ខ.យ.** នឹងរៀបចំសន្និសីទថ្នាក់ជាតិស្តីពីយុវជននិងភាពគ្មានការងារធ្វើ។ សន្និសីទនេះនឹងប្រមូលអ្នកផ្តល់ព័ត៌មាននិងការប្រឹក្សាយោបល់នាពេលបច្ចុប្បន្នដល់អ្នកគ្មានការងារធ្វើឱ្យមកចូលរួម។ សន្និសីទនេះនឹងដាក់បង្ហាញនូវសំណើនានាសម្រាប់កម្មវិធីសេវាកម្មប្រឹក្សាយោបល់ជាតិយុវជនអំពីមុខរបរ។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

ការជ្រើសរើសមុខរបរដោយយុវជនមានភាពកាន់តែប្រសើរឡើង។

*សូចនាករអនុវត្ត*

- របាយការណ៍អំពីលទ្ធភាពអាចធ្វើបាន ត្រូវបានរៀបចំ
- សំណើនានាសម្រាប់កម្មវិធីប្រឹក្សាយោបល់ជាតិយុវជនអំពីមុខរបរ ត្រូវបានសរសេរឡើង
- សន្និសីទត្រូវបានធ្វើឡើង។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ទីភ្នាក់ងារជាតិមុខរបរនិងការងារ និងក្រសួងអប់រំ យុវជន និងកីឡា គាំទ្រដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានារួមមាន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត អង្គការមិនមែនរដ្ឋាភិបាលនិងនៅតាមសហគមន៍។

### *៣.៤.៣- ការបង្កើតការងារសម្រាប់យុវជន*

*គោលបំណងសកម្មភាព*

បង្កើតវេទិកាសម្រាប់ការអភិវឌ្ឍគោលនយោបាយនិងកម្មវិធី ដែលផ្តោតលើស្ថានភាពការងារ តម្រូវការបណ្តុះបណ្តាល និងសហគ្រាសរបស់យុវជន។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជនគ្មានការងារធ្វើនិងជាពិសេស យុវនារី យុវជនពិការ និងអ្នកមកពីក្រុមជនជាតិភាគតិច។

*កិច្ចការសំខាន់ៗ*

គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ដែលផ្តោតលើយុវជន និងយុវនារី នឹងសម្របសម្រួលសកម្មភាពមួយចំនួន ដែលត្រូវធ្វើឡើងដើម្បីលើកកម្ពស់ការងារយុវជន និងកំណត់និងស្រាវជ្រាវអំពីបញ្ហានានាដែលប៉ះពាល់យុវជនគ្មានការងារធ្វើ។ កិច្ចការនេះរួមមានការវិភាគទីផ្សារការងារ ការធ្វើកិច្ចព្រមព្រៀង និងកម្មវិធីបណ្តុះបណ្តាលយុវជន និងការលើកកម្ពស់វិស័យជាក់លាក់សម្រាប់ការងារយុវជន ដូចជា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

ឱកាសការងារមានការកើនឡើងសម្រាប់យុវជន ជាពិសេស អ្នកនៅក្នុងក្រុមអាទិភាព។

*សូចនាករអនុវត្ត*

- ចំនួនយុវជនទទួលបានការងារធ្វើតាមរយៈកម្មសិក្សា ការហ្វឹកហ្វឺនការងារ កិច្ចព្រមព្រៀងបណ្តុះបណ្តាល ឬគម្រោងផ្សេងៗទៀតដែលកើតមានឡើងតាមរយៈកម្មវិធី
- ចំនួនយុវនារី យុវជនពិការ និងអ្នកមកពីក្រុមជនជាតិភាគតិច ទទួលបានការងារតាមរយៈកម្មសិក្សា ការហ្វឹកហ្វឺនការងារ កិច្ចព្រមព្រៀងបណ្តុះបណ្តាលឬគម្រោងផ្សេងៗទៀតដែលកើតមានឡើងតាមរយៈកម្មវិធី
- ការផ្សព្វផ្សាយ ការចែកចាយ និងការឆ្លើយតបចំពោះសកម្មភាពកម្មវិធីការងារយុវជន។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

គោលនយោបាយនឹងត្រូវរៀបចំឡើង តាមរយៈការសហការរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងអង្គការអន្តរជាតិខាងការងារ ដោយមានធាតុចូលមកពីក្រសួងអប់រំ យុវជន និងកីឡានិង **គ.ជ.យ.** ដោយធ្វើកិច្ចពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងការគាំទ្រយុវជនគ្មានការងារធ្វើ។

### ៣.៤.៤- ការតស៊ូមតិនិងភាពជាតំណាងយុវជននៅក្នុងស្ថាប័នរដ្ឋបាលនានា

*គោលបំណងសកម្មភាព*

លើកកម្ពស់គុណភាពនិងស្តង់ដាកម្មវិធីដែលមានអត្ថប្រយោជន៍ដល់យុវជន។

*ក្រុមគោលដៅរបស់សកម្មភាព*

យុវជនដែលទើបទទួលបានការងារ តាមរយៈការហ្វឹកហ្វឺនការងារ កម្មសិក្សា និងគោលនយោបាយប្រហាក់ប្រហែល ការធានាយេនឌ័រ ពិការភាព និងភាពជាតំណាងជនជាតិភាគតិចដែលមាន។

*កិច្ចការសំខាន់ៗ*

- បង្កើតឱ្យមានការចូលរួមរបស់យុវជននៅក្នុងទីភ្នាក់ងារ ដែលទទួលខុសត្រូវសម្រាប់អភិបាលកិច្ចកម្មវិធីការងារនិងការបណ្តុះបណ្តាលនានា
- ផ្តល់ការបណ្តុះបណ្តាលនិងការគាំទ្រដល់យុវជនដែលនឹងត្រូវបានជ្រើសរើសជាតំណាង
- បង្កើតយន្តការជ្រើសរើស ការបោះឆ្នោត សម្រាប់ភាពជាតំណាង។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

យុវជនចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការងារយុវជន។

*សូចនាករអនុវត្ត*

- តំណាងយុវជនត្រូវបានជ្រើសរើស
- អត្រាភាគរយនៃទីភ្នាក់ងារអភិបាលកិច្ច ជាមួយយុវជនសកម្ម និងមានអត្ថន័យ។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គាំទ្រដោយ គ.ជ.យ. គណៈកម្មាធិការជាតិបណ្តុះបណ្តាលនិងអង្គភាពពាក់ព័ន្ធផ្សេងៗទៀត។

### ៣.៤.៥- ការអប់រំយុវសហគ្រិនភាព

*គោលបំណងសកម្មភាព*

- យុវជនយល់ដឹងនិងចាត់ទុកសហគ្រិនភាពជាផ្លូវមួយសម្រាប់មុខរបរដែលមិនមែនមិនអាចធ្វើបាន
- អាជីវកម្មខ្នាតតូច និងការប្រកបរបរដោយខ្លួនឯង ត្រូវបានបញ្ជ្រាបជាផ្លូវសម្រាប់មុខរបរមួយ។

*ក្រុមគោលដៅរបស់សកម្មភាព*

- យុវជននៅក្នុងប្រព័ន្ធអប់រំ និងយុវជនគ្មានការងារធ្វើ
- យុវជនពិការ។

*កិច្ចការសំខាន់ៗ*

- រៀបចំការប្រជុំកម្រិតខ្ពស់ជាមួយក្រសួងនិងដៃគូសំខាន់ៗ ដើម្បីឱ្យមានការព្រមព្រៀងគ្នាលើការធ្វើសមាហរកម្មការអប់រំសហគ្រិនភាពទីក្នុងកម្មវិធីសិក្សា
- អនុវត្តមេរៀន KAB នៅក្នុងសាលា និងសាកលវិទ្យាល័យដែលបានជ្រើសរើសមុននឹងបញ្ចូលផ្សព្វផ្សាយទូទាំងប្រទេស។

***លទ្ធផលរំពឹងទុកពីសកម្មភាព***

- ការប្រកបមុខរបរដោយខ្លួនឯង ត្រូវបានយល់និងចាត់ទុកជាមុខរបរដែលជាគោលសំខាន់មួយ
- យុវជនត្រូវបានទាក់ទាញទៅរកការប្រកបមុខរបរដោយខ្លួនឯង ជាជម្រើសសំខាន់មួយសម្រាប់ការងារពេញម៉ោងនិងពេញលេញ។

***សូចនាករអនុវត្ត***

- ការប្រជុំកម្រិតខ្ពស់ជាមួយក្រសួង ស្ថាប័ន និងដៃគូសំខាន់ៗ ត្រូវបានធ្វើឡើងដោយបានឯកភាពយល់ព្រមលើផែនការគម្រោងមួយ
- មេរៀនត្រូវបានសាកល្បងនិងទទួលបានការវាយតម្លៃខ្ពស់ នៅក្នុងសាលារៀននិងសាកលវិទ្យាល័យដែលបានជ្រើសរើស
- តាមដានការអនុវត្ត។

***ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត***

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គាំទ្រដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

### ៣.៤.៦. ការផ្តួចផ្តើមការអភិវឌ្ឍយុវសហគ្រាសជាតិ

***គោលបំណងសកម្មភាព***

- គាំទ្រយុវជននៅក្នុងការអភិវឌ្ឍសហគ្រិនភាព
- ធ្វើឱ្យការអភិវឌ្ឍសហគ្រិនភាពមានភាពងាយស្រួលក្នុងការផ្តួចផ្តើម។

***ក្រុមគោលដៅរបស់សកម្មភាព***

យុវជនដែលបង្ហាញពីចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍធុរកិច្ចរបស់ពួកគេ នៅពេលអនុវត្តការងារនេះត្រូវយកចិត្តទុកដាក់ទៅលើតម្រូវការពិសេសរបស់យុវជនក្រៅប្រព័ន្ធអប់រំ និងយុវជនដែលត្រឡប់មកវិញ។

***កិច្ចការសំខាន់ៗ***

- យន្តការសម្របសម្រួលត្រូវបង្កើតឡើង ដើម្បីត្រួតពិនិត្យការផ្តួចផ្តើមការអភិវឌ្ឍសហគ្រិនភាពដែលរួមបញ្ចូលអ្នកពាក់ព័ន្ធសំខាន់ៗ
- ការផ្ទេរការបណ្តុះបណ្តាល និងការគាំទ្រធុរកិច្ច
- ការធ្វើឱ្យដំណើរការធុរកិច្ចមានភាពងាយស្រួល
- សំណើលម្អិត និងករណីធុរកិច្ចសម្រាប់ការប្រកួតប្រជែងសហគ្រិនភាព។

***លទ្ធផលរំពឹងទុកពីសកម្មភាព***

សកម្មភាពសហគ្រិនភាពកើនឡើង ជាការគាំទ្រសេដ្ឋកិច្ចដែលមានភាពចម្រុះជាងមុន។

***សូចនាករអនុវត្ត***

- ចំនួនការបណ្តុះបណ្តាលដែលបានផ្តល់
- លទ្ធផលនៃការបណ្តុះបណ្តាល ធុរកិច្ចមាននិរន្តរភាព ទាំងអត្រាភាគរយ និងលក្ខខណ្ឌដើមទុន
- ដំណើរការធុរកិច្ចមានភាពងាយស្រួល ត្រូវបានវាស់ស្ទង់ដោយប្រព័ន្ធភាពងាយស្រួលក្នុងការធ្វើធុរកិច្ច
- សេវាកម្មអភិវឌ្ឍធុរកិច្ច ត្រូវបានបង្កើត និងផ្តល់
- មូលនិធិអភិវឌ្ឍសហគ្រិនភាពត្រូវបានផ្តល់។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

មជ្ឈមណ្ឌលសម្រាប់ការលើកកម្ពស់អាជីវកម្មខ្នាតតូច នៅក្នុងក្រសួងឧស្សាហកម្មនិងសិប្បកម្ម ធ្វើការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមធុរកិច្ចនិងហិរញ្ញវត្ថុសំខាន់ៗ។ ទីភ្នាក់ងារយុវជនសំខាន់ៗ និងទីភ្នាក់ងារពាក់ព័ន្ធដទៃទៀត ក៏ត្រូវចូលរួមពាក់ព័ន្ធធ្វើការងារដែរ។

## ៣.៥- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៦ : បង្កើនការចូលរួមរបស់យុវជន

### ៣.៥.១- ការពង្រឹងនិងពង្រីកក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន

*គោលបំណងសកម្មភាព*

ធានាថាសាលារៀនទាំងអស់មានក្រុមប្រឹក្សាកុមារនិងយុវជនដែលមានការដឹកនាំបានល្អហើយគាំទ្រ និងជំរុញអាកប្បកិរិយារួមសហការគ្នារបស់សិស្ស។

*ក្រុមគោលដៅរបស់សកម្មភាព*

កុមារនិងយុវជននៅតាមសាលារៀន។

*កិច្ចការសំខាន់ៗ*

កម្មវិធីគាំទ្រដើម្បីអភិវឌ្ឍនិងធ្វើឱ្យសាលារៀន និងក្រុមប្រឹក្សាមានភាពប្រសើរឡើងសម្រាប់ការអនុវត្តការងារចលនា ៣ល្អ ការកែលម្អសកម្មភាពសាលារៀន និងភាពពាក់ព័ន្ធធ្វើឡើងដោយក្រសួង៖

- ប្រជុំបូកសរុបការងារប្រឡងប្រណាំងចលនា ៣ល្អ ធ្វើឡើងរៀងរាល់ឆ្នាំ
- ទស្សនកិច្ចសិក្សា និងជំរំសម្រាប់ក្រុមប្រឹក្សាយុវជន ក៏ដូចជាកម្មវិធីផ្លាស់ប្តូរបទពិសោធរវាងរាជធានីខេត្ត
- ការបណ្តុះបណ្តាលប្រធានក្រុមប្រឹក្សាយុវជននិងកីឡាករ
- ការរៀបចំសេចក្តីណែនាំសម្រាប់ក្រុមប្រឹក្សា។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

ការគាំទ្ររបស់ក្រុមប្រឹក្សាមានការកើនឡើង ការសិក្សាត្រូវបានកែលម្អ។

*សូចនាករអនុវត្ត*

- សិស្សចាប់ពីថ្នាក់ទី៤ដល់ទី៩ បានចូលរួមក្នុងក្រុមប្រឹក្សាកុមារ ចំនួន១០០% ក្នុងឆ្នាំ២០១៨
- សិស្សចាប់ពីថ្នាក់ទី១០ដល់ទី១២ បានចូលរួមក្នុងក្រុមប្រឹក្សាយុវជន ចំនួន១០០% ក្នុងឆ្នាំ២០១៨
- ពិន្ទុគុណភាពសរុបសម្រាប់ក្រុមប្រឹក្សានីមួយៗ។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងអប់រំ យុវជន និងកីឡា។

## ៣.៦- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី១០ : បង្កើនការងារស្ម័គ្រចិត្ត

សកម្មភាពចំនួន៣ ត្រូវបានកំណត់ រួមមាន (១) កម្មវិធីសេវាកម្មជាតិយុវជន និង (២) ការលើកកម្ពស់ការផ្តួចផ្តើមសហគមន៍ និង(៣) ការសម្របសម្រួល និងការអភិវឌ្ឍអង្គភាពជាមួយកាយរឹទ្ធិកម្ពុជា។ សកម្មភាពនីមួយៗ មានលក្ខណៈដូចតទៅ៖

### ៣.៦.១- កម្មវិធីសេវាកម្មជាតិយុវជន

*គោលបំណងសកម្មភាព*

ផ្តល់ឱកាសសម្រាប់យុវជនដើម្បីធ្វើវិភាគទាន រួមចំណែកឆ្ពោះទៅរកការអភិវឌ្ឍប្រទេសកម្ពុជា ទន្ទឹមនឹងការពង្រឹងមុខរបរផ្ទាល់ខ្លួនរបស់ពួកគេ តាមរយៈការអភិវឌ្ឍជំនាញថ្មីៗ។

*ក្រុមគោលដៅរបស់សកម្មភាព*

ក្រុមគោលដៅនឹងត្រូវកំណត់ដោយឯកសារជម្រើសគោលនយោបាយនានា ហើយអាចជាយុវជននៅក្រៅប្រព័ន្ធអប់រំ ការងារនិងបណ្តុះបណ្តាល ឬ និស្សិតបញ្ចប់ការសិក្សានៅឧត្តមសិក្សា។

*កិច្ចការសំខាន់ៗ*

- ក្រុមបច្ចេកទេសផ្តល់ជំនាញនិងជំបូន្មានបច្ចេកទេស
- ក្រុមបច្ចេកទេសត្រូវបានបង្កើត
- ការបង្កើតគណៈកម្មការនានារបស់ **គ.ជ.យ.** ដើម្បីទទួលឯកសារជម្រើសគោលនយោបាយនានា
- សេចក្តីព្រាងឯកសារគោលនយោបាយនានា ត្រូវបានចងក្រងនិងចែកចាយ ដើម្បីទទួលមតិយោបល់
- កិច្ចប្រជុំកំពូលថ្នាក់ជាតិស្តីពីកម្មវិធីសេវាកម្មជាតិយុវជនដែលបានអនុវត្ត
- ឯកសារជម្រើសគោលនយោបាយនានា ត្រូវបានចងក្រងនិងដាក់ជូន **គ.ជ.យ.** ពិនិត្យនិងសម្រេច។
- ការសាកល្បងអនុវត្តកម្មវិធី បានចាប់ផ្តើមនិងត្រូវបានវាយតម្លៃ។

*លទ្ធផលរំពឹងទុកពីសកម្មភាព*

ការសាកល្បងកម្មវិធី ត្រូវបានចាប់ផ្តើម។

*សូចនាករអនុវត្ត*

- ចំនួនអង្គការយុវជននិងក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ត្រូវបានធ្វើការពិគ្រោះពិភាក្សាជាមួយ
- ការផលិតឯកសារជម្រើសគោលនយោបាយនានា
- ចំនួនយុវជនដែលបង្ហាញអំពីចំណាប់អារម្មណ៍ក្នុងការចូលរួមក្នុងកម្មវិធី
- ការយល់ដឹងនិងការទទួលយករបស់សាធារណជនអំពីគោលការណ៍ និងកម្មវិធី
- ក្របខណ្ឌច្បាប់ស្តីពីការងារស្ម័គ្រចិត្ត ត្រូវបានអនុម័ត
- កម្មវិធីសាកល្បងត្រូវបានចាប់ផ្តើម និង
- របាយការណ៍ស្តីពីដំណើរការពិគ្រោះយោបល់ ត្រូវបានរៀបចំ។

*ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រុមការងារបច្ចេកទេសនឹងគ្រប់គ្រងដំណើរការពិគ្រោះយោបល់និងការអភិវឌ្ឍ និងធ្វើរបាយការណ៍ជូនផ្នែកអនុវត្តគោលនយោបាយរបស់ **គ.ជ.យ.** ដែលផ្តល់ការគាំទ្រផ្នែកភស្តុភារនិងលេខាធិការដល់ក្រុមការងារបច្ចេកទេស។

### *៣.៦.២- ការលើកកម្ពស់ការផ្តួចផ្តើមសហគមន៍*

*គោលបំណងសកម្មភាព*

កសាងកម្មវិធីគាំទ្រមួយដែលលើកកម្ពស់ការជួយខ្លួនឯង ការផ្តួចផ្តើមការអភិវឌ្ឍយុវជននៅតាមសហគមន៍ និងការផ្តួចផ្តើមការងារស្ម័គ្រចិត្ត។

*ក្រុមគោលដៅរបស់សកម្មភាព*

**គ.ជ.យ.** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាស្ថាប័ន រដ្ឋាភិបាលផ្សេងទៀត រាជធានី ខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធនៅតាមសហគមន៍។

*កិច្ចការសំខាន់ៗ*

- **គ.ជ.យ.** នឹងរៀបចំឱ្យមានឯកសារពិភាក្សារវាងមិត្តនិងមិត្ត អំពីតួនាទី និងលក្ខណសម្បត្តិនៃកម្មវិធីមួយដែលលើកកម្ពស់ការជួយខ្លួនឯង និងការផ្តួចផ្តើមការងារស្ម័គ្រចិត្តសម្រាប់ការពិគ្រោះ

យោបល់នៅក្នុងសិក្ខាសាលារាជធានី ខេត្តមួយចំនួន ដើម្បីកំណត់ពីតម្រូវការ ចំណាប់អារម្មណ៍ បំណងប្រាថ្នា និងសមត្ថភាពរបស់អង្គការយុវជននៅតាមសហគមន៍ពាក់ព័ន្ធនឹងកម្មវិធី

- **គ.ជ.យ**. នឹងរៀបចំឱ្យមានឯកសារកម្មវិធីមួយសម្រាប់ការពិភាក្សាជាមួយក្រសួងដឹកនាំការងារ និងអង្គការពាក់ព័ន្ធដទៃទៀត រួមទាំងទីភ្នាក់ងារម្ចាស់ជំនួយ
- **គ.ជ.យ**. នឹងធ្វើផែនការការងារដើម្បីអនុវត្តកម្មវិធីដែលបានស្នើ។ ការអភិវឌ្ឍសាកល្បងនឹងត្រូវធ្វើការវាយតម្លៃករណីចាំបាច់ មុននឹងដាក់ឱ្យអនុវត្តជាទូលំទូលាយ។

### *លទ្ធផលរំពឹងទុកពីសកម្មភាព*

- ការពិគ្រោះយោបល់មានលក្ខណៈទូលំទូលាយអំពីតម្រូវការ បំណងប្រាថ្នា និងឱកាសនានា ដែលគាំទ្រការផ្តួចផ្តើមការជួយខ្លួនឯងត្រូវបានធ្វើឡើង
- លទ្ធភាពនៃកម្មវិធីអភិវឌ្ឍការជួយខ្លួនរបស់យុវជន ត្រូវបានកំណត់
- កិច្ចសហការរវាងទីភ្នាក់ងារពាក់ព័ន្ធនិងដៃគូកម្មវិធីសក្តានុពល ត្រូវបានធ្វើឡើង។

### *សូចនាករអនុវត្ត*

- ចំនួននៃការពិគ្រោះយោបល់ដែលបានធ្វើឡើង
- ចំនួនអ្នកពាក់ព័ន្ធដែលចូលរួមនិងប្តេជ្ញាចិត្តចំពោះដំណើរការ
- កម្រិតនៃការយល់ស្របជាទូទៅអំពីការតាក់តែងកម្មវិធីនិងលទ្ធភាពអនុវត្តរបស់កម្មវិធី
- ការអនុវត្តកម្មវិធីសាកល្បង។

### *ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត*

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ក្រសួងដឹកនាំការងារ) ក្រសួងអប់រំ យុវជន និងកីឡា និង **គ.ជ.យ**.។

## *៣.៦.៣- ការសម្របសម្រួលនិងការអភិវឌ្ឍអង្គភាពជាមួយកាយរឹទ្ធិកម្ពុជា*

### *គោលបំណងសកម្មភាព*

ផ្តល់នូវផែនការយុទ្ធសាស្រ្តមួយដល់កាយរឹទ្ធិកម្ពុជានិងធ្វើឱ្យមានភាពច្បាស់លាស់អំពីទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល។

### *ក្រុមគោលដៅរបស់សកម្មភាព*

កាយរឹទ្ធិកម្ពុជា។

### *កិច្ចការសំខាន់ៗ*

- ជំនួយបច្ចេកទេសនៅក្នុងការអភិវឌ្ឍអង្គភាពដើម្បីអភិវឌ្ឍផែនការយុទ្ធសាស្រ្ត និងកិច្ចព្រមព្រៀងលើការគាំទ្រ
- ការប្តេជ្ញាចិត្តនិងការរួមចំណែកពីសំណាក់អ្នកពាក់ព័ន្ធដើម្បីអភិវឌ្ឍផែនការយុទ្ធសាស្រ្ត
- រៀបចំកិច្ចប្រជុំ ការពិគ្រោះយោបល់ជាមួយសមាជិកកាយរឹទ្ធិ និងសិក្ខាសាលា។

### *លទ្ធផលរំពឹងទុកពីសកម្មភាព*

- ផែនការយុទ្ធសាស្រ្ត៥ឆ្នាំ សម្រាប់កាយរឹទ្ធិកម្ពុជា
- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងកាយរឹទ្ធិកម្ពុជា លើកិច្ចគាំទ្រដែលអាចរំពឹងទៅវិញទៅមក។

### *សូចនាករអនុវត្ត*

- ការចូលរួមរបស់អ្នកពាក់ព័ន្ធ ក្រសួងអប់រំ យុវជន និងកីឡា អគ្គលេខាធិការដ្ឋាននៃ **គ.ជ.យ**. ក្នុងការពិគ្រោះយោបល់ កិច្ចប្រជុំ និងសិក្ខាសាលា

- ការផលិតផែនការយុទ្ធសាស្ត្រនិងកិច្ចព្រមព្រៀងលើការគាំទ្ររវាងរាជរដ្ឋាភិបាលកម្ពុជា និងកាយរឹទ្ធិកម្ពុជា។

***ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត***

ផ្នែកអនុវត្តគោលនយោបាយ ផ្តល់ការគាំទ្រផ្នែកភស្តុភារនិងការងារលេខាធិការ។

## ខ. តារាងសង្ខេបសកម្មភាព

តារាងអនុវត្តការងារនៃផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងបង្ហាញអំពីយុទ្ធសាស្ត្រ យុទ្ធសាស្ត្ររង កម្មវិធី និងសកម្មភាពគោល កិច្ចការ និងការគ្រប់ដណ្តប់របស់កម្មវិធីសកម្មភាព សូចនាករ ពេលវេលាកំណត់ ធនធាន និងក្រសួង ស្ថាប័នទទួលខុសត្រូវ។

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| ៣.១- សកម្មភាពអនុវត្តយុទ្ធសាស្ត្រទី១ : អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ | ៣.១.១- សេវាកម្មព័ត៌មានយុវជនច្រកតែមួយ | ១. វេបសាយ និងទិន្នន័យលើប្រព័ន្ធអ៊ីនធឺណិត រួមមានការអាចចូលប្រើប្រាស់យកព័ត៌មានបានតាមរយៈប្រព័ន្ធទូរស័ព្ទដៃ។<br>២. សេវាកម្មព័ត៌មានយុវជនតាមរយៈទូរស័ព្ទ និងការបញ្ជូនបន្ត។<br>៣. សេវាកម្មផ្តល់ព័ត៌មានដោយផ្ទាល់នៅតាមមជ្ឈមណ្ឌលយុវជន មជ្ឈមណ្ឌលការងារ និងទីកន្លែងប្រហាក់ប្រហែលគ្នានៅគ្រប់រាជធានី ខេត្ត។<br>៤. កូនសៀវភៅសេវាកម្មនិងកម្មវិធីយុវជន សេវាកម្មផ្សព្វផ្សាយតាមរយៈព្រឹត្តិការណ៍នានា (កីឡា តន្ត្រី។ល។) កម្មវិធីវិទ្យុ និងទូរទស្សន៍ជាប្រចាំ ក៏ដូចជាប្រព័ន្ធព័ត៌មានសង្គមដទៃទៀត។<br>៥. សិក្ខាសាលម្អិតដោយមានគោលការណ៍ច្បាស់លាស់ ការអភិវឌ្ឍយុទ្ធសាស្ត្រទំនាក់ទំនង គម្រោងការងារ និងគម្រោងថវិកា។<br>៦. សេវាកម្មព័ត៌មានសាកល្បង (វេបសាយ និងទិន្នន័យលើប្រព័ន្ធអ៊ីនធឺណិត | ១. យុទ្ធសាស្ត្រទំនាក់ទំនង។<br>២. បណ្តាញទំនាក់ទំនងនិងផ្សព្វផ្សាយ។<br>៣. អត្រាការប្រើប្រាស់ទម្រង់នានានៃលទ្ធភាព និងមធ្យោបាយទទួលបានសេវាកម្ម។<br>៤. ចំណេះដឹងស្តីពីសេវាកម្មនិងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន សាធារណៈជន និងយុវជន។<br>៥. ចំណេះនិងការយល់ដឹងអំពីយុវជន និងអ្នកធ្វើការងារយុវជន។ | ២០១៦ - ២០១៨ | **ក.ជ.យ.**<br>- ក្រសួងព័ត៌មាន<br>- ដៃគូ និង<br>- អ្នកពាក់ព័ន្ធទាំងអស់។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | | និងបណ្ដាញទូរស័ព្ទយុវជន)។<br>៧. ពិនិត្យសម្រួលឡើងវិញលើការពាក់ព័ន្ធរបស់ទិន្នន័យលើប្រព័ន្ធអ៊ីនធឺណិត និងការប្រើប្រាស់ព័ត៌មាន។<br>៨. ផែនការការងារ និងសំណើមូលនិធិរៀបចំឡើងដើម្បីបន្តប្រតិបត្តិការសេវាកម្ម។<br>៩. ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងដែលមាននិរន្តរភាព។ | | | |
| | ៣.១.២- ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន | ១. រៀបចំផែនការកម្មវិធីសម្រាប់ឆ្នាំ២០១៤-២០១៨។<br>២. សម្ពោធដំណើរការមគ្គុទ្ទេសក៍កម្មវិធីនិងសេវាកម្មយុវជនរបស់រាជរដ្ឋាភិបាល។<br>៣. សម្ពោធប្រតិបត្តិតាមមគ្គុទ្ទេសក៍កម្មវិធីនិងអនុវត្តសេវាកម្មយុវជនរបស់រដ្ឋាភិបាលលើកទី២។ | ១. ចំនួនក្រសួងដែលចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួងបានទៀងទាត់។<br>២. ការអនុលោមតាមផែនការកម្មវិធីរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍក្រសួងដោយក្រសួងទាំងអស់។<br>៣. របាយការណ៍ពិនិត្យកែសម្រួលស្ដីពីសកម្មភាពក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួងដើម្បីវាស់ស្ទង់ប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង។<br>៤. ការផលិតនិងការចែកចាយមគ្គុទ្ទេសក៍កម្មវិធីរដ្ឋាភិបាលប្រចាំឆ្នាំ។ | ២០១៦ - ២០១៨ | - **គ.ជ.យ.**<br>- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន។ |
| | ៣.១.៣- ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត | ១. ចងក្រងកម្រងឯកសាររចនាសម្ព័ន្ធនៃមុខងាររបស់រាជធានី ខេត្ត។<br>២. រៀបចំធ្វើផែនការការងារប្រចាំឆ្នាំនៃកិច្ចប្រជុំថ្នាក់រាជធានី ខេត្ត។<br>៣. ធ្វើសវនកម្មគោលនយោបាយ កម្មវិធី | ១. ការបង្កើតវេទិកាប្រចាំត្រីមាស។<br>២. ចំនួនវេទិកាដែលបានរៀបចំ។<br>៣. ការបោះពុម្ពផ្សព្វផ្សាយព័ត៌មានស្ដីពីការងារអភិវឌ្ឍយុវជនដែលរាជធានី ខេត្តកំពុងធ្វើ។<br>៤. ការចូលរួមរបស់រាជធានី ខេត្ត ក្នុងវេទិកា | ២០១៦ - ២០១៨ | - **គ.ជ.យ.**<br>- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | | និងការផ្តួចផ្តើមការអភិវឌ្ឍយុវជនរាជធានីខេត្ត។<br>៤. រៀបចំសិក្ខាសាលាស្តីពីសារៈសំខាន់របស់គោលនយោបាយយុវជនរាជធានីខេត្ត និងសេចក្តីណែនាំការធ្វើផែនការកម្មវិធី។ | កិច្ចប្រជុំ និងសិក្ខាសាលានានា។<br>៥. ការរៀបចំនិងអនុវត្តឱ្យមានការពង្រឹងនិងពង្រីកបន្ថែមទៅលើគោលនយោបាយ និងកម្មវិធីថ្នាក់រាជធានី ខេត្តសម្រាប់ការអភិវឌ្ឍយុវជន។ | | |
| | ៣.១.៤- *ការសម្របសម្រួលជាមួយសង្គមស៊ីវិល* | ១. ប្រមែប្រមូល និងបញ្ជ្រាបការងារអភិវឌ្ឍយុវជនទៅក្នុងសង្គមស៊ីវិល ដោយប្រើប្រាស់ផែនការយុទ្ធសាស្ត្ររួមគ្នា ដូចជាសិក្ខាសាលា និងកិច្ចប្រជុំ។<br>២. ចូលរួមចំណែកយ៉ាងជាក់លាក់ក្នុងការកសាងសមត្ថភាពរបស់អង្គការយុវជនតាមរយៈកម្មវិធីបណ្តុះបណ្តាល និងការណែនាំបទពិសោធ អនុវត្តល្អៗ ដើម្បីឱ្យពួកគេមានលទ្ធភាពកាន់តែកើនឡើងខ្លាំងជាងមុនក្នុងការងារអភិវឌ្ឍយុវជន។<br>៣. ធានាការគាំទ្រសម្រាប់គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជន។<br>៤. ធ្វើសវនកម្មការផ្តួចផ្តើមនិងគម្រោងនានាដែលពាក់ព័ន្ធនឹងយុវជន ដែលនៅក្រៅរដ្ឋាភិបាល ហើយដែលត្រូវធ្វើបច្ចុប្បន្នកម្មនៅក្នុងផែនទីបង្ហាញផ្លូវរបស់អង្គការសង្គមស៊ីវិល។ | ១. កំណត់ហេតុអង្គប្រជុំនានា។<br>២. កម្រិតនៃការចូលរួមនិងការរួមចំណែករបស់រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលដើម្បីឆ្លើយតបនឹងតម្រូវការរបស់យុវជន។<br>៣.ការចូលរួមរបស់យុវជននៅក្នុងដំណើរការការអនុវត្ត និងការអភិវឌ្ឍបន្តលើគោល-នយោបាយជាតិស្តីពីយុវជន។<br>៤. ការធ្វើបច្ចុប្បន្នកម្មផែនទីបង្ហាញផ្លូវរបស់សកម្មភាពរបស់អង្គការសង្គមស៊ីវិល។ | ២០១៦ - ២០១៨ | - **គ.ជ.យ.**។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | | ៥. ស្តាប់ ចូលរួមពិគ្រោះយោបល់ និងស្វែងយល់អំពីក្តីព្រួយបារម្ភរបស់យុវជនតាមរយៈសមាគមតំណាង និងការស្ទាបស្ទង់មតិនានា។ | | | |
| | ៣.១.៥- ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា | ១. ជំនួយបច្ចេកទេសត្រូវបានផ្តល់ដោយក្រុមបច្ចេកទេសពាក់ព័ន្ធ។<br>២. សិក្ខាសាលានិងកិច្ចពិគ្រោះយោបល់។ | ១. ផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជន។<br>២. ក្រសួងនិងអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវធ្វើកិច្ចពិគ្រោះយោបល់។ | ២០១៦ - ២០១៨ | - គ.ជ.យ.។ |
| | ៣.១.៦- ការតស៊ូមតិនៅក្នុងសភាជាតិ ក្រសួង ស្ថាប័ន និងថ្នាក់រាជធានី ខេត្ត | ១. ការបង្កើតការិយាល័យក្រៅម៉ោងរបស់ គ.ជ.យ. នៅក្នុងសភាជាតិ។<br>២. ការបង្កើតទម្រង់នៃការវិភាគផលប៉ះពាល់គំរូ<br>៣. មន្ត្រីដែលមានសមត្ថភាពអនុវត្តការវិភាគផលប៉ះពាល់។<br>៤. ការផលិតកញ្ចប់ព័ត៌មានសម្រាប់សមាជិកសភាជាតិ និងអ្នកដឹកនាំក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។ | ១. សមាជិកសភាជាតិ អ្នកគ្រប់គ្រងរដ្ឋបាលនៅតាមក្រសួងស្ថាប័ន និងថ្នាក់ដឹកនាំរាជធានី ខេត្ត ត្រូវទទួលបាននូវព័ត៌មានពាក់ព័ន្ធយុវជននិងផលប៉ះពាល់របស់សេចក្តីព្រាងច្បាប់នានាដល់ការអភិវឌ្ឍយុវជន។<br>២. គ.ជ.យ. ទទួលបានការទទួលស្គាល់កាន់តែប្រសើរជាងមុនពីសំណាក់សភាជាតិ និងសមាជិកសភាជាតិ។<br>៣.សមាមាត្រនៃច្បាប់ ព្រះរាជក្រឹត្យ សេចក្តីណែនាំ។ល។ អំពីអ្វីដែលការវិភាគផលប៉ះពាល់ត្រូវបានអនុវត្ត។ | ២០១៦ - ២០១៨ | - គ.ជ.យ.<br>- សភាជាតិ។ |
| | ៣.១.៧- ការពិនិត្យកែសម្រួលនិងរៀបចំលិខិតបទដ្ឋានគតិយុត្ត | ១. ក្រុមពិនិត្យកែសម្រួលច្បាប់ពាក់ព័ន្ធយុវជន ត្រូវបង្កើតឡើងដោយមានតំណាងយេនឌ័រ ជនពិការ និងអ្នកតំណាងផលប្រយោជន៍ដទៃទៀត។ | ១. ចំនួនអង្គការយុវជន ក្រុមទទួលផលប្រយោជន៍ អង្គការក្រៅរដ្ឋាភិបាល និងក្រសួង ស្ថាប័ន ត្រូវបានធ្វើការពិភាក្សាជាមួយ។<br>២. ចំនួននៃការឆ្លើយតបចំពោះគោល- | ២០១៦ - ២០១៨ | - គ.ជ.យ.។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | ពាក់ព័ន្ធយុវជន | ២. ក្រុមពិនិត្យកែសម្រួលច្បាប់ពាក់ព័ន្ធយុវជន អភិវឌ្ឍកម្មវិធីការងារ និងបញ្ជាក់បង្ហាញពីឯកសារយោងនានា។<br>៣. ក្រុមពិនិត្យកែសម្រួលច្បាប់ពាក់ព័ន្ធយុវជន ធ្វើការស្ទាបស្ទង់មតិលើស្ថានភាពការងារនៃច្បាប់ពាក់ព័ន្ធនឹងអាយុ ដែលប៉ះពាល់យុវជន និងវិស័យចាំបាច់សម្រាប់យុវជន ធ្វើកិច្ចពិគ្រោះយោបល់ជាមួយយុវជននិងក្រុមពាក់ព័ន្ធដទៃទៀតស្ដីពីបញ្ហាការងារទាំងនេះ។ | នយោបាយ។<br>៣. ចំនួននៃការងារដែលត្រូវបានត្រួតពិនិត្យកែសម្រួលដោយក្រុម។<br>៤. ការផលិត និងការទទួលយកគោលនយោបាយដោយរាជរដ្ឋាភិបាល។ | | |
| | ៣.១.៨- ការស្រាវជ្រាវអំពីយុវជន | ១. ឯកសារយោងនានា (រួមមាន វិស័យស្រាវជ្រាវ វិធីសាស្ត្រគំរូស្ទាបស្ទង់មតិ ។ល។)<br>២. ការត្រួតពិនិត្យនិងគ្រប់គ្រងការស្រាវជ្រាវដែលមានស្រាប់។<br>៣. ការកំណត់អំពីការស្រាវជ្រាវដែលត្រូវទទួលការអនុញ្ញាត។<br>៤. ការអនុញ្ញាតឱ្យមានកម្មវិធីសម្រាប់ធ្វើការស្រាវជ្រាវ។<br>៥. ការប្រជុំទ្វេភាគីជាមួយក្រសួងសុខាភិបាល ក្រសួងអ.យ.ក. និងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីកសាង | ១. ចំនួនយុវជនដែលត្រូវបានធ្វើការស្ទាបស្ទង់មតិ។<br>២. ការកែសម្រួលគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជាដោយផ្អែកលើការស្រាវជ្រាវ។<br>៣.ការបោះពុម្ពផ្សាយ (អ៊ីនធឺណិត) ការស្រាវជ្រាវ ឯកសារ និងរបាយការណ៍ដែលទទួលបានការអនុញ្ញាត។ | ២០១៦ - ២០១៨ | **អ.ស.យ.**។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | | បាននូវការយល់ដឹងអំពីដំណើរការនៃការរៀបចំតាក់តែងសំណួរ និងការវិភាគពាក់ព័ន្ធនឹងយុវជននៅការងារស្រាវជ្រាវរបស់ពួកគេ។<br>៦. កិច្ចសហការជាមួយដៃគូសិក្សាធិការ និងផ្សេងទៀត។ | | | |
| | ៣.១.៩- *ការអភិវឌ្ឍធនធានមនុស្ស* | ១. **គ.ជ.យ.** ជួបជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំរបៀបរបបការងារសម្រាប់ឱ្យដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធ។<br>២. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីយុវជន និងអ្នកពាក់ព័ន្ធនឹងកំណត់នូវលក្ខខណ្ឌនិងលក្ខណសម្បត្តិក្នុងការជ្រើសរើសសិក្ខាកាមដើម្បីចូលរួមទទួលការបណ្តុះបណ្តាលនាពេលអនាគត។<br>៣. **គ.ជ.យ.** ជួបជាមួយតំណាងក្រសួង អ.យ.ក. តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតនូវមធ្យោបាយ ជួយឱ្យការទទួលស្គាល់អ្នកធ្វើការងារ យុវជនមានលក្ខណៈអាជីពប្រព្រឹត្តទៅបានដោយមានលក្ខណៈស្រប ទៅនឹងក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា។<br>៤. រៀបចំផែនការលម្អិតសម្រាប់ការបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន **គ.ជ.យ.**។ | ១. ផែនការកសាងសមត្ថភាពត្រូវបានពង្រាង។<br>២. វគ្គបណ្តុះបណ្តាលខ្លីៗ ត្រូវបានរៀបចំធ្វើ។<br>៣.ការទទួលស្គាល់ជាផ្លូវការចំពោះការងារយុវជនដែលមានដោយក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជានិងចំនួននៃការទទួលបានគុណវុឌ្ឍ។<br>៤. របាយការណ៍អំពីការវាយតម្លៃការផ្លាស់ប្តូរនៅក្នុងប្រសិទ្ធផលនៃការងារយុវជន។ | ២០១៦ - ២០១៨ | **គ.ជ.យ.**។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | *៣.១.១០- ការកៀរគរធនធាន* | ១. រៀបចំសន្និសីទម្ចាស់ជំនួយ។ | ១. ចំនួននៃប្រតិភូសន្និសីទ។<br>២. ការយល់ដឹងប្រសើរជាងមុននៅក្នុងចំណោមអង្គការយុវជនអំពីចំណាប់អារម្មណ៍និងលក្ខខណ្ឌនានារបស់ម្ចាស់ជំនួយ។<br>៣. ការយល់ដឹងប្រសើរជាងមុនក្នុងចំណោមទីភ្នាក់ងារម្ចាស់ជំនួយអំពីតម្រូវការនិងឱកាសនៃការអភិវឌ្ឍ និងការទទួលបានមូលនិធិផ្គត់ផ្គង់ការអភិវឌ្ឍ។ | ២០១៦ - ២០១៨ | - **គ.ជ.យ.**<br>- គណៈកម្មាធិការរៀបចំ (តំណាងមកពី **គ.ជ.យ.** អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារមួយចំនួនក៏ដូចជាអ្នកឧបត្ថម្ភដែលជាអ្នកជំនួញកម្ពុជា)។ |
| **៣.២- ការអនុវត្តយុទ្ធសាស្ត្រទី២ :**<br><br>**ការលើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាលនិងការអភិវឌ្ឍ** | *៣.២.១- សាលារៀនជាទីកន្លែងមូលដ្ឋានសម្រាប់រៀនសូត្រតាមរយៈការអប់រំមានគុណភាព* | ១. ពិនិត្យកែសម្រួលកម្មវិធីសិក្សា។<br>២. បង្កើនគុណភាពនៃការអប់រំ។<br>៣. បង្កើនគុណភាពព័ត៌មានសម្រាប់សិស្ស។<br>៤. បង្កើតឧត្តមភាពនៅក្នុងសហគមន៍ដែលងាយរងគ្រោះ។ | ១. ការបង្កើតនិងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP 2014-2018)។<br>២. អត្រាភាគរយខ្ពស់នៃចំនួនយុវជនចុះឈ្មោះចូលរៀនគ្រប់ភូមិសិក្សា។<br>៣. កម្មវិធីសិក្សាជាតិដែលមានបច្ចុប្បន្នកម្មនៅគ្រប់ភូមិសិក្សា។<br>៤. គណៈគ្រប់គ្រងសាលារៀនដែលបង្ហាញនូវចំណាប់អារម្មណ៍និងការប្តេជ្ញាចិត្តចំពោះការអប់រំយុវជន។<br>៥. ភាពប្រសើរឡើងនៃគុណភាពការអប់រំ ដូចបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨។ | ២០១៦ - ២០១៨ | - ក្រ.អ.យ.ក.<br>- មន្ទីរ.អ.យ.ក. រាជធានី ខេត្ត<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| **សមត្ថភាព** | ៣.២.២- យុវជនទទួលបាននូវគុណវុឌ្ឍខ្ពស់ | ១. អភិវឌ្ឍការអប់រំជំនាញសម្រាប់យុវជនពិការ។<br>២. ធ្វើសវនកម្ម និងផែនការសកម្មភាពដើម្បីធានាឱ្យមានអគារ សិក្សាដែលយុវជនពិការអាចប្រើប្រាស់បាន។<br>៣. ពង្រឹងគុណភាពផែនការ និងកែលម្អការអប់រំ។<br>៤. ធានាឱកាសទទួលបានការអប់រំដែលមានគុណវុឌ្ឍនានា។ | ១. ភាគរយនៃចំនួនយុវជនទទួលបានគុណ-វុឌ្ឍិវិជ្ជាជីវៈ។<br>២. ភាគរយនៃចំនួនយុវជនបានបញ្ចប់មធ្យមសិក្សាទុតិយភូមិ។<br>៣. អត្រាភាគរយខ្ពស់នៃចំនួនយុវជនចុះឈ្មោះ ចូលរៀននៅគ្រប់ភូមិសិក្សា។<br>៤. កម្មវិធីសិក្សាដែលមានបច្ចុប្បន្នកម្មសម្រាប់គ្រប់ភូមិសិក្សា។<br>៥. ភាគរយនៃអគារសិក្សាដែលយុវជនពិការអាចប្រើប្រាស់បាន។ | ២០១៦ - ២០១៨ | - ក្រ.អ.យ.ក.<br>- មន្ទីរ.អ.យ.ក. រាជធានី ខេត្ត<br>- គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.៣- ឱកាសទទួលបានការអប់រំលើកទីពីរ | ១. ពិនិត្យកែសម្រួល និងអភិវឌ្ឍកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ។<br>២. អភិវឌ្ឍមធ្យោបាយនិងដំណោះស្រាយដែលមានភាពទន់ភ្លន់ ហើយយុវជនអាចចាប់ផ្ដើមមកទទួលការអប់រំសាជាថ្មីពាក់ព័ន្ធនឹងបច្ចេកទេស វិជ្ជាជីវៈ និងសិក្សាធិការ។ | ១. ចំនួនយុវជនត្រឡប់មករកការអប់រំវិញបន្ទាប់ពីចាកចេញពីសាលារៀន។<br>២. កម្មវិធីសិក្សាជាតិដែលមានបច្ចុប្បន្នកម្មនៅគ្រប់កម្រិតភូមិសិក្សា រួមមានគុណវុឌ្ឍការបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅក្រោមក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា។ | ២០១៦ - ២០១៨ | - ក្រ.អ.យ.ក.<br>- មន្ទីរ.អ.យ.ក. រាជធានី ខេត្ត<br>- គណៈកម្មាធិការជាតិបណ្ដុះ-បណ្ដាល<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.៤- ការអភិវឌ្ឍលទ្ធភាពទទួលបានការសិក្សាបន្ត ឬការសិក្សាពេញមួយជីវិត | ១. ជម្រើសនៃការផ្ដត់ផ្គង់មូលនិធិបន្ថែមត្រូវបានបង្កើត។<br>២. ផែនការសម្រាប់ការអភិវឌ្ឍសិល្បៈសហគមន៍ និងមជ្ឈមណ្ឌលយុវជន។ | ១. ឱកាសកើនឡើងសម្រាប់យុវជននៅក្នុងការអប់រំក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ។<br>២. ប្រភពមូលនិធិបន្ថែមសម្រាប់យុវជននៅក្នុងការអប់រំ ជាពិសេស យុវនារីដែលមានតម្រូវការពិសេស។<br>៣. សិល្បៈសហគមន៍ និងមជ្ឈមណ្ឌលយុវជនត្រូវបានធ្វើផែនការបង្កើត/កំពុងដំណើរការ | ២០១៦ - ២០១៨ | - ក្រ.អ.យ.ក. និង មន្ទីរ.អ.យ.ក. រាជធានី ខេត្ត<br>- ក្រ.ការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- គណៈកម្មាធិការ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | | | បង្កើត/កំពុងប្រតិបត្តិ។ | | ជាតិបណ្តុះ-បណ្តាល<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.៥- *ការគាំទ្រយុវជននៅពេលពួកគេកំពុងឈានចូលពេញវ័យ* | ១. លើកកម្ពស់ឱកាសអប់រំបន្ត។ | ១. ការយល់ដឹងប្រសើរជាងមុនក្នុងចំណោមសិស្សនិស្សិត យុវជន និងសហគមន៍អំពីសេវាកម្មអប់រំ និងកម្មវិធីផ្សេងៗដទៃទៀត។<br>២. ការចូលរួមរបស់និយោជកនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីបំពេញបានតាមតម្រូវការរបស់និយោជក។<br>៣. ចំណេះដឹងអំពីផលប្រយោជន៍នៃការចុះឈ្មោះចូលរៀនបន្តនៅគ្រប់ផ្នែកទាំងអស់របស់អប់រំ។ | ២០១៦ - ២០១៨ | - ក្រ.អ.យ.ក.<br>- សង្គមស៊ីវិល និងអង្គភាពធុរកិច្ច<br>- ក្រ.ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- គណៈកម្មាធិការជាតិបណ្តុះបណ្តាល<br>- ទីភ្នាក់ងារជាតិមុខរបរ និងការងារ<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.៦- *សម្ភារៈនិងមធ្យោបាយបម្រើឱ្យយុវជនក្នុងសហគមន៍* | ១. ធ្វើសវនកម្មទីតាំងនិងបង្កើតក្រុមការងារមួយដើម្បីធ្វើការពិភាក្សាជាមួយក្រសួង ស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាលពាក់-ព័ន្ធ ដើម្បីពិនិត្យមើលកែសម្រួលការងារប្រសិនបើពង្រាងផែនការការអភិវឌ្ឍនិងថែរក្សាមជ្ឈមណ្ឌលយុវជនពហុបំណងត្រូវបានអនុម័ត។<br>២. សហការជាមួយអាជ្ញាធររាជធានី ខេត្ត | ១. ការធ្វើសវនកម្មលើទីតាំងនានា។<br>២. ការងារគ្រប់គ្រងការអនុវត្តត្រូវបានកំណត់។<br>៣. ផែនការមានសុពលភាព។ | ២០១៦ - ២០១៨ | - ក្រ.អ.យ.ក.<br>- ក្រ.សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រ.កិច្ចការនារី<br>- ក្រសួង ស្ថាប័ន |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | | ពាក់ព័ន្ធ ដើម្បីកំណត់នូវវិស័យសម្រាប់ការសាកល្បងមជ្ឈមណ្ឌលយុវជនពហុបំណង។<br>៣. សម្របសម្រួលការធ្វើផែនការនិងការបង្កើតមជ្ឈមណ្ឌលយុវជនពហុបំណង។ | | | និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.៧- *ការពង្រីកកម្មវិធីអប់រំក្រោយមធ្យមសិក្សានៅតាមសហគមន៍ និងមជ្ឈមណ្ឌលយុវជនសម្រាប់ យុវជនក្រៅសាលា ជាពិសេសយុវជនពិការ ដើម្បីឱ្យពួកគេមានឱកាសបានចូលរួមយ៉ាងសកម្ម ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ* | ១. ធានាការបញ្ចូលព័ត៌មានស្តីពីសិទ្ធិពលរដ្ឋ សិទ្ធិអត្ថកម្ម និងសិទ្ធិពិការភាពទៅក្នុងកម្មវិធីសិក្សាតាមរយៈគណៈកម្មាធិការក្របខណ្ឌកម្មវិធីសិក្សាជាតិ។<br>២. កំណត់មធ្យោបាយពង្រឹងសមត្ថភាពគណៈគ្រប់គ្រងសាលា ដើម្បីធានាឱ្យមានការឆ្លើយតបបានគ្រប់គ្រាន់ក្នុងបរិបទសាលារៀន។<br>៣. ជ្រើសរើសអ្នកសម្របសម្រួលគម្រោងមួយរូប ដើម្បីសហការជាមួយផ្នែកអនុវត្តគោលនយោបាយរបស់ **ក.ជ.យ.** និង ក្រ.អ.យ.ក. ក្នុងការអង្កេតលើកម្មវិធីសិក្សាបច្ចុប្បន្ន និងវិធីសាស្ត្របណ្តុះ-បណ្តាល ដែលដាក់ឱ្យប្រើប្រាស់ក្នុងកម្មវិធីអប់រំ ក្រោយមធ្យមសិក្សានានា។<br>៤. រៀបចំផែនការលម្អិតសម្រាប់គម្រោង។<br>៥. វាយតម្លៃគម្រោង។ | ១. ការចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីអប់រំក្រោយមធ្យមសិក្សារបស់យុវជនក្រៅប្រព័ន្ធអប់រំ និងពិការមកពីជនបទ។<br>២. វត្តមានកម្មវិធីសិក្សាការអប់រំពលរដ្ឋ នៅតាមសាលារៀន។<br>៣. ការលើកកម្ពស់ចំណេះដឹងអំពីព័ត៌មាន និងទំនួលខុសត្រូវចំពោះសិទ្ធិពលរដ្ឋ សិទ្ធិអត្ថកម្ម និងសិទ្ធិពិការភាពក្នុងចំណោមសិស្ស និស្សិត។<br>៤. គណៈគ្រប់គ្រងសាលា បំពេញតួនាទីបង្ហាញអំពីផលប្រយោជន៍ និងការប្តេជ្ញាចិត្តចំពោះការអប់រំសិទ្ធិស៊ីវិល។<br>៥. កម្រិតអត្រាអត្ថកម្មរបស់យុវជនក្រៅប្រព័ន្ធអប់រំ និងយុវជនពិការមានការកើនឡើង។<br>៦. ចំនួននៃក្រសួង ស្ថាប័ននិងនិយោជកដែលគោរពបានតាមចំនួនកំណត់របស់និយោជិកពិការ មានការកើនឡើង។ | ២០១៦ - ២០១៨ | - ក្រ.អ.យ.ក. និង មន្ទីរ.អ.យ.ក. រាជធានី ខេត្ត<br>- **ក.ជ.យ.**<br>- ក្រ.ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រ.សង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.៨- *ប្រាក់កម្ចីសិក្សាសម្រាប់សិស្ស* | ១. ចងក្រងគម្រោងហិរញ្ញវត្ថុសិស្សដែលមានស្រាប់ រួមមានអាហារូករណ៍ ប្រាក់ឧបត្ថម្ភការសិក្សា និងជំនួយឥតសំណងផ្សេងៗ។ | ១. ចំនួនគម្រោងហិរញ្ញវត្ថុ។<br>២. ជម្រើសហិរញ្ញវត្ថុ។ | ២០១៦ - ២០១៨ | - ក្រ. អ.យ.ក.<br>- **ក.ជ.យ.**<br>- អង្គការយុវជន |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | និងនិស្សិត | ២. អភិវឌ្ឍន៍ជម្រើសនានាសម្រាប់ការកើនឡើងទឹកប្រាក់ត្រូវបង់ពន្ធអាករនិងទម្រង់ហិរញ្ញវត្ថុផ្សេងៗ រួមគម្រោងផ្សេងៗទៀតដែលប្រសើរជាងនេះ។<br>៣. កំណត់គុណវុឌ្ឍអាទិភាពដែលប្រសើរជាងមុន និងបន្ថែមទៀត ដែលអាចទាក់ទាញអាហារូបករណ៍។ល។<br>៤. ពិភាក្សាជាមួយសាកលវិទ្យាល័យ និងស្ថាប័នអប់រំកម្រិតឧត្តមសិក្សានិងជាមួយសមាគមធុរកិច្ចអំពីព័ត៌មានទីផ្សារការងារ និងការទស្សន៍ទាយផ្សេងៗ។<br>៥. កិច្ចពិភាក្សាជាមួយអង្គការយុវជន និងសិស្ស និស្សិតនិងអ្នកពាក់ព័ន្ធដទៃទៀត។ | | | និងសិស្សនិស្សិត<br>- សមាគមហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.៩- ភាពជាតំណាងយុវជន | ១. បង្កើតឱ្យមានភាពតំណាងយុវជននៅក្នុងអាជ្ញាធរគុណវុឌ្ឍកម្ពុជា។<br>២. ផ្តល់ការបណ្តុះបណ្តាលនិងការគាំទ្រយុវជនដែលនឹងទៅជាអ្នកតំណាងយុវជន។<br>៣. បង្កើតយន្តការជ្រើសរើស/បោះឆ្នោតសម្រាប់ការជ្រើសរើសតំណាងយុវជន។ | ១. តំណាងយុវជនត្រូវបានបោះឆ្នោតជ្រើសរើស។<br>២. យុវជនចូលរួមនិងធ្វើវិភាគទានក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់អាជ្ញាធរគុណវុឌ្ឍកម្ពុជា។ | ២០១៦ - ២០១៨ | - **គ.ជ.យ.**<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.១០- ការលើកកម្ពស់ បណ្តាញការងារ និងគំរូនៅ | ១. រៀបចំផែនការសកម្មភាពដើម្បីបង្កើតចំណេះដឹង និងចំណាប់អារម្មណ៍ក្នុងចំណោមសិស្សសាលាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។<br>២. រៀបចំកម្មវិធីប្រកួតយកពានរង្វាន់យុវជន | ១. ចំនួនយុវជនមកពីក្រុមគោលដៅដែលបានឧទ្ទេសនាម ចូលរួមក្នុងពានរង្វាន់វិទ្យាសាស្ត្រយុវជន។<br>២. ចំនួនយុវជនមកពីក្រុមគោលដៅដែលបានឧទ្ទេសនាម ចូលរួមក្នុងក្លឹបវិទ្យាសាស្ត្រនិង | ២០១៦ - ២០១៨ | - ក្រ. អ.យ.ក.<br>- មន្ទីរ. អ.យ.ក. រាជធានី ខេត្ត<br>- ក្រុមហ៊ុនឯកជនក្នុងវិស័យវិទ្យា- |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | ក្នុងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | វិទ្យាសាស្ត្រ។<br>៣. បង្កើតនិងជំរុញក្លឹបវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាពិសេសនៅក្នុងសាលារៀន។<br>៤. ពិភាក្សាជាមួយមហាវិទ្យាល័យ និងសាកលវិទ្យាល័យនៅឧត្តមសិក្សាដើម្បីរិះរកមធ្យោបាយលើកកម្ពស់មុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាពក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សា។<br>៥. រៀបចំកូនសៀវភៅ រួមមានមុខរបរនៅក្នុងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់សិស្សនៅកម្រិតមធ្យមសិក្សា។<br>៦. ជំរុញការនាំចូលឬផលិតឧបករណ៍ និងសម្ភារៈវិទ្យាសាស្ត្រសម្រាប់សាលារៀន។ | បច្ចេកវិទ្យា។<br>៣. ការបោះពុម្ពនិងចែកផ្សាយវគ្គសិក្សាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងព័ត៌មានអំពីមុខរបរដល់សិស្សថ្នាក់ទី៧។<br>៤. ចំនួនយុវជនមកពីក្រុមគោលដៅដែលបានឧទ្ទេសនាម ចុះឈ្មោះសិក្សាក្នុងកម្មវិធីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅឧត្តមសិក្សា។ | | សាស្ត្រ និងបច្ចេកវិទ្យា<br>- ក្រសួងពាណិជ្ជ-កម្ម<br>- ទីភ្នាក់ងារជាតិមុខរបរ និងការងារ<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.២.១១- ព័ត៌មានវិទ្យានិងការអប់រំពីចម្ងាយ | អង្កេតលើវិធី និងមធ្យោបាយនានាដែលអាចបង្កើតលទ្ធភាពទទួលបានបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រដល់ការអប់រំនិងបណ្តុះបណ្តាលពីចម្ងាយ។ | ១. ការកំណត់អំពីតម្រូវការព័ត៌មាន និងការគាំទ្ររបស់អ្នកសិក្សាពីចម្ងាយនិងនៅជនបទ។<br>២. ការអភិវឌ្ឍសំណើគម្រោងសេវាកម្ម ការគ្រប់គ្រង និងលក្ខខណ្ឌហិរញ្ញវត្ថុដើម្បីបង្កឱ្យមានលទ្ធភាពទទួលបច្ចេកវិទ្យាព័ត៌មាននៅក្នុងសហគមន៍។ | ២០១៦ - ២០១៨ | - ក្រ. អ.យ.ក.<br>- វិទ្យាស្ថានជាតិអប់រំ<br>- សភាពាណិជ្ជកម្ម<br>- ក្រ.ពាណិជ្ជកម្ម<br>- អង្គការក្រៅរដ្ឋាភិបាល និងតាមសហគមន៍ផ្សេង<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| **៣.៣- ការអនុវត្តយុទ្ធសាស្ត្រទី៣ : ការបង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព** | *៣.៣.១- ការប្រឹក្សាយោបល់ស្តីពីសុខភាពយុវជន* | ១. ប្រមូលព័ត៌មានអំពីយុវជននៅក្នុងក្រុមគោលដៅតាមរយៈទីភ្នាក់ងារ និងអង្គការដែលសមស្រប។<br>២. ពិនិត្យកែសម្រួលសេចក្តីណែនាំនិងទម្រង់នានាដែលមានស្រាប់ (មិនមែនភាសាខ្មែរ និងមិនមានលាយលក្ខណ៍អក្សរ) និងកំណត់នូវតម្រូវការបច្ចុប្បន្ននានាប្រសិនបើមាន។<br>៣. ធ្វើសេចក្តីណែនាំថ្មីៗពេលដែលចាំបាច់ និងធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំដទៃទៀតក្នុងករណីចាំបាច់។<br>៤. អភិវឌ្ឍនិងអនុវត្តផែនការផ្សព្វផ្សាយតាមរយៈសេវាកម្មច្រកតែមួយ សាលារៀន មាតាបិតា អង្គការក្រៅរដ្ឋាភិបាល សាកលវិទ្យាល័យ និងសម្ភារៈនិងមធ្យោបាយនៅតាមមជ្ឈមណ្ឌលយុវជនពហុបំណង។<br>៥. ធ្វើការផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធព័ត៌មាន និងប្រព័ន្ធបណ្តាញសង្គម និងទទួលយកមតិត្រឡប់ពីយុវជនតាមរយៈទូរស័ព្ទក្នុងកម្មវិធីវិទ្យុដើម្បីធានាឱ្យព័ត៌មានទាំងនោះទៅដល់សហគមន៍ដាច់ស្រយាលរបស់ជនជាតិភាគតិច និងក្រុមដទៃទៀតដែលពិបាកក្នុងការបញ្ជូនព័ត៌មានទៅដល់។ | ១. ការទទួលបានព័ត៌មានប្រសើរជាងមុនរបស់ក្រុមគោលដៅសំខាន់ៗ។<br>២. ការផលិតសេចក្តីណែនាំ និងការផ្តល់ប្រឹក្សាយោបល់ថ្មីៗ ឬមានបច្ចុប្បន្នភាព។<br>៣. ចំណេះដឹងស្តីពីសុខភាពមានភាពប្រសើរជាងមុនក្នុងចំណោមយុវជន។<br>៤. លទ្ធភាពទទួលបានព័ត៌មានសុខភាពមានភាពប្រសើរជាងមុន។ | ២០១៦ - ២០១៨ | - ក្រ.សុខាភិបាល<br>- នា.សុខភាពសិក្សា<br>- អង្គការយុវជន<br>- អង្គការក្រៅរដ្ឋាភិបាល<br>- អង្គការនៅតាមសហគមន៍នានា<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | ៣.៣.២- ការយល់ដឹងអំពីយុវជននិងជំងឺកាមរោគ មេរោគអេដស៍និងជំងឺអេដស៍ | ១. ជានាប្រសិទ្ធភាពកម្មវិធីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ដែលផ្តោតលើយុវជន។<br>២. ពិនិត្យកែសម្រួលការស្រាវជ្រាវដែលមានស្រាប់អំពីយុវជននិងកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា។<br>៣. រៀបចំអត្ថបទសង្ខេបពាក់ព័ន្ធនឹងយុវជន ជំងឺកាមរោគ និង ជំងឺអេដស៍សម្រាប់យុទ្ធនាការព័ត៌មានសាធារណៈ។ | ១. ចំនួនយុវជន និងអង្គការយុវជនដែលត្រូវបានធ្វើការពិភាក្សាជាមួយមានការកើនឡើង។<br>២. ចំនួននៃអត្រាភាគរយប្រជាជនដែលបានមកទទួលសេវាកម្ម ជាពិសេស ជនពិការ ជនជាតិភាគតិច ជនងាយរងគ្រោះ អ្នកដែលនៅតំបន់ជនបទដាច់ស្រយាល ឬអ្នកដែលពិបាកក្នុងការប្រមូលមក។<br>៣. ការកំណត់នូវបញ្ហាសំខាន់ៗដែលប៉ះពាល់យុវជន និងជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍។<br>៤. ការផលិតនិងការអនុវត្តអត្ថបទសង្ខេបសម្រាប់យុទ្ធនាការព័ត៌មានសាធារណៈ។ | ២០១៦ - ២០១៨ | - អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍<br>- អង្គការយុវជន<br>- អង្គការនៅតាមសហគមន៍<br>- អង្គការក្រៅរដ្ឋាភិបាល<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.៣.៣- ការគាំទ្រយុវតីមានគភ៌ និងវត្តមានសិស្ស | ១. បង្កើតក្រុមការងារទទួលបន្ទុកបញ្ហាយុវតីមានគភ៌។<br>២. កំណត់អំពីសារៈសំខាន់នៃបញ្ហាមានគភ៌ក្នុងវ័យសិក្សា ដែលនៅតែបន្តមាន និងថាតើមានបញ្ហានេះនៅតាមមូលដ្ឋានណាខ្លះ។<br>៣. យល់ដឹងអំពីមូលហេតុគោលនយោបាយជាតិស្តីពីសាលារៀន មិនបានអនុវត្តបានពេញលេញ។<br>៤. កំណត់វិធានការធានាការអនុវត្តការងារពាក់ព័ន្ធ។<br>៥. កំណត់ការគាំទ្រ ការថែរក្សាគភ៌របស់យុវនារី។ | ១. ចំនួនសាលារៀនដែលអនុវត្តគោលនយោបាយជាតិស្តីពីសាលារៀនបានត្រឹមត្រូវ មានការកើនឡើង។<br>២. ចំនួនសិស្សដែលចាកចេញពីសាលារៀនដោយសារតែការមានគភ៌មានការថយចុះ។<br>៣. ការផលិតនិងចែកផ្សាយឯកសារព័ត៌មានការអប់រំ និងទំនាក់ទំនង។ | ២០១៦ - ២០១៨ | - ក្រ. អ.យ.ក.<br>- ក្រ.សុខាភិបាល<br>- **គ.ជ.យ.**<br>- ក្រុមប្រឹក្សាឆ្នប<br>- អង្គការក្រៅរដ្ឋាភិបាល<br>- គណៈកម្មាធិការសមភាពយេនឌ័រ<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | | ៦. រៀបចំនិងអនុវត្តសិក្ខាសាលាមួយចំនួននៅតាមរាជធានី ខេត្ត ដោយធ្វើការកំណត់អំពីតម្រូវការដើម្បីឆ្លើយតបនឹងបញ្ហាសិស្សមានគតិវិយក្មេងនិងការអនុវត្តគោលនយោបាយជាតិស្តីពីការចូលរៀន។<br>៧. រៀបចំឯកសារព័ត៌មាន ការអប់រំ និងទំនាក់ទំនងសម្រាប់ចែកចាយដល់សាលារៀន។ | | | |
| **៣.៤- ការអនុវត្តយុទ្ធសាស្ត្រទី៤ :**<br><br>**ការបណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ** | *៣.៤.១- ការប្រឹក្សាយោបល់ស្តីពីមុខរបរនៅតាមសាលារៀន* | ១. វាស់ស្ទង់ព័ត៌មានអំពីការប្រឹក្សាយោបល់ស្តីពីមុខរបរដល់សិស្សនិស្សិតនិងតម្រូវការ។<br>២. បណ្តុះបណ្តាលបុគ្គលិក និងមន្ត្រីទទួលបន្ទុកផ្តល់សេវា។<br>៣. ផ្តល់អនុសាសន៍អំពីមធ្យោបាយ និងវិធីសាស្ត្រនានាក្នុងការកែលម្អព័ត៌មានអំពីការប្រឹក្សាយោបល់ស្តីពីមុខរបរនៅក្នុងសាលារៀន។<br>៤. ផ្សព្វផ្សាយព័ត៌មានលទ្ធផលការងារសម្រាប់សិស្សនិស្សិតដែលបានបញ្ចប់ការសិក្សា។<br>៥. លើកសំណើនានា ដូចជារៀបផ្តល់ជូនព័ត៌មានបច្ចុប្បន្នកម្មដល់សាលារៀន និងសាកលវិទ្យាល័យ។ | ១. អនុសាសន៍ត្រូវបានទទួលយកនិងអនុម័តដោយគណៈកម្មាធិការជាតិកម្មវិធីសិក្សា។<br>២. ព័ត៌មានអំពីមុខរបរដែលមានបច្ចុប្បន្នភាពអាចស្វែងរកបានដោយងាយនៅតាមសាលារៀននិងសាកលវិទ្យាល័យ ដែលឆ្លុះបញ្ចាំងអំពីទំនោរទីផ្សារការងារនាពេលបច្ចុប្បន្ន។<br>៣. ព័ត៌មានអំពីលទ្ធផលមានការងារធ្វើត្រូវបានផ្សព្វផ្សាយសម្រាប់វិទ្យាល័យ ព្រមទាំងស្ថាប័ននិងគ្រឹះស្ថានឧត្តមសិក្សា។<br>៤. ចំនួនអ្នកផ្តល់ប្រឹក្សាយោបល់អំពីមុខរបរដែលទទួលបានការបណ្តុះបណ្តាល។ | ២០១៦ - ២០១៨ | - ក្រ. អ.យ.ក.<br>- **ន.ជ.យ.**<br>- ក្រ.ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ទីភ្នាក់ងារជាតិមុខរបរ និងការងារ<br>- ស្ថាប័នឧត្តមសិក្សា<br>- សមាគមនិយោជក<br>- គណៈកម្មាធិការជាតិកម្មវិធីសិក្សា<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | *៣.៤.២- សេវាកម្មប្រឹក្សាយោបល់ស្តីពីមុខរបរសម្រាប់យុវជន* | ១. រៀបចំឯកសារពិភាក្សាលើការវាយតម្លៃលើមជ្ឈមណ្ឌលការងារ និងបញ្ហានានារបស់យុវជននិងការផ្តល់ប្រឹក្សាយោបល់អំពីមុខរបរ។<br>២. អង្កេតលើលទ្ធភាពនៃការបង្កើតសេវាកម្មប្រឹក្សាយោបល់យុវជនអំពីមុខរបរដោយផ្តល់ការគាំទ្រជាក់ស្តែងសម្រាប់ការបង្កើត និងការគ្រប់គ្រងទីតាំងសេវាកម្មក្នុងមូលដ្ឋាន និងសេវាកម្មជាតិតាមប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធទូរស័ព្ទ។<br>៣. សិក្សាអំពីតម្រូវការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកផ្តល់ប្រឹក្សាយោបល់អំពីមុខរបរដោយផ្សារភ្ជាប់នឹងតម្រូវការបណ្តុះ-បណ្តាលអ្នកផ្តល់ប្រឹក្សាយោបល់នៅតាមសាលារៀន។<br>៤. អភិវឌ្ឍសៀវភៅណែនាំអំពីការផ្តល់ប្រឹក្សាយោបល់អំពីមុខរបរ ឬឯកសារបណ្តុះបណ្តាល។<br>៥. រៀបចំសន្និសីទថ្នាក់ជាតិស្តីពីយុវជន និងភាពគ្មានការងារធ្វើ។<br>៦. លើកសំណើនានាសម្រាប់កម្មវិធីសេវាកម្មប្រឹក្សាយោបល់ជាតិយុវជនអំពីមុខរបរ។ | ១. របាយការណ៍អំពីលទ្ធភាពបង្កើតមជ្ឈមណ្ឌលសេវាប្រឹក្សាយោបល់ស្តីពីមុខរបរ។<br>២. សំណើនានាសម្រាប់កម្មវិធីប្រឹក្សាយោបល់ជាតិយុវជនអំពីមុខរបរ។<br>៣. សន្និសីទថ្នាក់ជាតិស្តីពីយុវជននិងភាពគ្មានការងារ។ | ២០១៦ - ២០១៨ | - ក្រ.ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ទីភ្នាក់ងារជាមុខរបរនិងការងារ<br>- ក្រ. អ.យ.ក.<br>- **គ.ជ.យ.**<br>- ស្ថាប័នអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ<br>- សាកលវិទ្យាល័យ<br>- ក្រ.ឧស្សាហកម្មនិងសិប្បកម្ម<br>- ក្រ.សង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា<br>- អង្គការក្រៅរដ្ឋាភិបាល និងតាមសហគមន៍<br>- វិស័យឯកជន<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | ៣.៤.៣- *ការបង្កើតការងារសម្រាប់យុវជន* | ១. រៀបចំគោលនយោបាយជាតិស្តីពីការងារដែលផ្តោតលើយុវជន និងយុវនារី។<br>២. សម្របសម្រួលសកម្មភាពលើកកម្ពស់ការងារយុវជន។<br>៣. កំណត់និងស្រាវជ្រាវអំពីបញ្ហានានាដែលប៉ះពាល់យុវជន គ្មានការងារធ្វើ ដូចជាការវិភាគទីផ្សារការងារ។<br>៤. ធ្វើកិច្ចព្រមព្រៀងរៀបចំកម្មវិធីបណ្តុះ-បណ្តាលយុវជន។<br>៥. ជំរុញនិងលើកកម្ពស់វិស័យមួយចំនួនដែលពាក់ព័ន្ធការធ្វើការងាររបស់យុវជន (ឧទា. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា)។ | ១. ចំនួនយុវជនទទួលបានការងារធ្វើតាមរយៈកម្មសិក្សា ការហ្វឹកហ្វឺនការងារ កិច្ចព្រមព្រៀង បណ្តុះបណ្តាល ឬគម្រោងផ្សេងៗទៀតដែលកើតមានឡើងតាមរយៈកម្មវិធី។<br>២. ចំនួនយុវនារី យុវជនពិការ និងអ្នកមកពីក្រុមជនជាតិភាគតិចទទួលបានការងារតាមរយៈកម្មសិក្សា ការហ្វឹកហ្វឺនការងារ កិច្ចព្រមព្រៀង បណ្តុះបណ្តាលឬគម្រោងផ្សេងៗទៀតដែលកើតមានឡើងតាមរយៈកម្មវិធី។<br>៣. ការផ្សព្វផ្សាយ ការចែកចាយ និងការឆ្លើយតបចំពោះសកម្មភាពកម្មវិធីការងារយុវជន។ | ២០១៦ - ២០១៨ | - ក្រ.ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- អង្គការអន្តរជាតិខាងការងារ<br>- ក្រ.អ.យ.ក.<br>- **គ.ជ.យ.**<br>- អង្គការមិនមែនរដ្ឋាភិបាល<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.៤.៤- *ការតស៊ូមតិនិងភាពជាតំណាងយុវជននៅក្នុងស្ថាប័នរដ្ឋបាលនានា* | ១. បង្កើតឱ្យមានការចូលរួមរបស់យុវជននៅក្នុងស្ថាប័នទទួលខុសត្រូវអភិបាលកិច្ចកម្មវិធីការងារ និងបណ្តុះបណ្តាលនានា។<br>២. ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដល់យុវជនដែលនឹងត្រូវបានជ្រើសរើសជាតំណាង។<br>៣. បង្កើតយន្តការជ្រើសរើស/ការបោះឆ្នោតសម្រាប់ភាពជាតំណាង។ | ១. តំណាងយុវជនត្រូវបានជ្រើសរើស។<br>២. អត្រាភាគរយនៃស្ថាប័នរដ្ឋបាលដែលមានតំណាងយុវជនសកម្ម។ | ២០១៦ - ២០១៨ | - ក្រ.ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- **គ.ជ.យ.**<br>- ក្រុមប្រឹក្សា-ភិបាលជាតិបណ្តុះបណ្តាល<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.៤.៥- *ការអប់រំ* | ១. រៀបចំការប្រជុំកម្រិតខ្ពស់ដើម្បីធានាឱ្យមានការព្រមព្រៀងលើការធ្វើសមាហរណកម្ម | ១. ការប្រជុំកម្រិតខ្ពស់ជាមួយក្រសួង និងដៃគូសំខាន់ៗដោយទទួលបានការឯកភាពលើ | ២០១៦ - ២០១៨ | - ក្រ. អ.យ.ក.<br>- ក្រ.ការងារ និង |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ ទទួលខុសត្រូវ អនុវត្ត |
|---|---|---|---|---|---|
| | យុវសហគ្រិនភាព | ការអប់រំសហគ្រិនភាពទៅក្នុងកម្មវិធីសិក្សា។<br>២. អនុវត្តមេរៀន “ការយល់ដឹងអំពីធុរកិច្ច (KnowAbout Busi ness)” នៅក្នុងសាលានិងសាកលវិទ្យាល័យដែលបានជ្រើសរើសមុននឹងបញ្ចូលនិងផ្សព្វផ្សាយទូទាំងប្រទេស។ | ផែនការគម្រោងនានា។<br>២. មេរៀនត្រូវបានសាកល្បងនិងទទួលបានការវាយតម្លៃខ្ពស់នៅក្នុង សាលារៀន និងសាកលវិទ្យាល័យដែលបានជ្រើសរើស។<br>៣. ការតាមដានការអនុវត្តការអប់រំសហគ្រិន-ភាពនៅទូទាំងប្រទេស។ | | បណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រ.ឧស្សាហកម្ម និងសិប្បកម្ម<br>- ដៃគូសំខាន់ៗ<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | ៣.៤.៦- ការផ្តួចផ្តើមការអភិវឌ្ឍយុវសហគ្រាសជាតិ | ១. រៀបចំយន្តការសម្របសម្រួលការត្រួតពិនិត្យការផ្តួចផ្តើម ការអភិវឌ្ឍសហគ្រិន-ភាពដែលរួមបញ្ចូលអ្នកពាក់ព័ន្ធសំខាន់ៗ។<br>២. បណ្តុះបណ្តាលយន្តការគាំទ្រធុរកិច្ច។<br>៣. លើកសំណើធុរកិច្ចដើម្បីរៀបចំការប្រកួតប្រជែងសហគ្រិនភាព។ | ១. ចំនួនវគ្គបណ្តុះបណ្តាល។<br>២. លទ្ធផលនៃការបណ្តុះបណ្តាលធុរកិច្ចមាននិរន្តរភាព ទាំងអត្រាភាគ និងលក្ខខណ្ឌដើមទុន។<br>៣. ការវាស់ស្ទង់ការធ្វើធុរកិច្ចដែលមានដំណើរការងាយស្រួល។<br>៤. ការបង្កើតនិងផ្តល់សេវាកម្មអភិវឌ្ឍធុរកិច្ច<br>៥. មូលនិធិអភិវឌ្ឍសហគ្រិនភាព។ | ២០១៦ - ២០១៨ | - មជ្ឈមណ្ឌលលើកកម្ពស់អាជីវកម្មខ្នាតតូច<br>- ក្រ.ឧស្សាហកម្ម និងសិប្បកម្ម<br>- អង្គការក្រៅរដ្ឋាភិបាល<br>- សមាគមធុរកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ<br>- ទីភ្នាក់ងារយុវជនសំខាន់ៗ<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| ៣.៥- ការអនុវត្តយុទ្ធសាស្ត្រទី៥ : | ៣.៥.១- ការពង្រឹងនិងពង្រីកក្រុមប្រឹក្សាកុមារនិងយុវជន | ១. ប្រជុំបូកសរុបការងារប្រឡងប្រណាំងចលនាពល្អ ធ្វើឡើងរៀងរាល់ឆ្នាំ។<br>២. ទស្សនកិច្ចសិក្សានិងជំរែសម្រាប់ក្រុមប្រឹក្សាយុវជន ក៏ដូចជាកម្មវិធីផ្លាស់ប្តូររវាង | ១. សិស្សចាប់ពីថ្នាក់ទី៤ដល់ទី៩ បានចូលរួមក្នុងក្រុមប្រឹក្សាកុមារ ចំនួន១០០% ក្នុងឆ្នាំ ២០១៨។<br>២. សិស្សចាប់ពីថ្នាក់ទី១០ដល់ទី១២ បាន | | - ក្រ. អ.យ.ក. |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| **បង្កើនការចូលរួមរបស់យុវជន** | | រាជធានី ខេត្ត។<br>៣. ការបណ្តុះបណ្តាលប្រធានក្រុមប្រឹក្សាយុវជននិងកីឡាករ។<br>៤. ការរៀបចំសេចក្តីណែនាំសម្រាប់ក្រុមប្រឹក្សា។ | ចូលរួមក្នុងក្រុមប្រឹក្សាយុវជន ចំនួន១០០% ក្នុងឆ្នាំ២០១៨។<br>៣. ពិន្ទុគុណភាពសរុបសម្រាប់ក្រុមប្រឹក្សានិមួយៗ។ | | |
| **៣.៦- ការអនុវត្តយុទ្ធសាស្ត្រទី៦ : ការបង្កើនការងារស្ម័គ្រចិត្ត** | *៣.៦.១- កម្មវិធីសេវាកម្មជាតិយុវជន* | ១. ផ្តល់ជំនាញ និងជំបូន្មានបច្ចេកទេស។<br>២. បង្កើតក្រុមបច្ចេកទេស។<br>៣. បង្កើតគណៈកម្មាធិការ នៅក្នុង **គ.ជ.យ.** ដើម្បីទទួលឯកសារជម្រើសគោល-នយោបាយនានា។<br>៤. ចងក្រងនិងចែកចាយសេចក្តីព្រាងឯកសារជម្រើសគោលនយោបាយនានាដើម្បីទទួលមតិយោបល់។<br>៥. រៀបចំកិច្ចប្រជុំកំពូលថ្នាក់ជាតិស្តីពីកម្មវិធីសេវាកម្មជាតិយុវជនដែលបានអនុវត្ត។<br>៦. ដាក់ជូន **គ.ជ.យ.** នូវឯកសារជម្រើសគោលនយោបាយនានាដែលបានចងក្រង។<br>៧. ចាប់ផ្តើម សាកល្បង និងវាយតម្លៃការអនុវត្តកម្មវិធី។ | ១. ចំនួនអង្គការយុវជន និងក្រសួងរដ្ឋាភិបាលដែលបានធ្វើការពិគ្រោះពិភាក្សាជាមួយ។<br>២. ឯកសារជម្រើសគោលនយោបាយនានា។<br>៣. ចំនួនយុវជនដែលបង្ហាញអំពីចំណាប់អារម្មណ៍ក្នុងការចូលរួមក្នុងកម្មវិធី។<br>៤. ការយល់ដឹង និងការទទួលយករបស់សាធារណជនអំពីគោលការណ៍ កម្មវិធី។<br>៥. ច្បាប់ស្តីពីការងារស្ម័គ្រចិត្តត្រូវបានអនុម័ត។<br>៦. កម្មវិធីសាកល្បងត្រូវបានចាប់ផ្តើម។<br>៧. របាយការណ៍ស្តីពីដំណើរការពិគ្រោះយោបល់។ | ២០១៦ - ២០១៨ | - ក្រុមបច្ចេកទេស<br>- **គ.ជ.យ.**<br>- ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ។ |
| | *៣.៦.២- ការលើកកម្ពស់ ការផ្តួចផ្តើមសហគមន៍* | ១. រៀបចំឯកសារពិភាក្សារវាងមិត្តនិងមិត្តអំពីតួនាទីនិងលក្ខណសម្បត្តិនៃកម្មវិធីលើកកម្ពស់ការជួយខ្លួនឯង ការផ្តួចផ្តើមការងារស្ម័គ្រចិត្ត ដើម្បីធ្វើការពិគ្រោះយោបល់ នៅក្នុងសិក្ខាសាលានៅតាមរាជធានី ខេត្តមួយចំនួន ដោយត្រូវ | ១. ចំនួនការពិគ្រោះយោបល់។<br>២. ចំនួនអ្នកពាក់ព័ន្ធដែលចូលរួម និងប្តេជ្ញាចិត្តចំពោះដំណើរការ។<br>៣. កម្រិតនៃការយល់ស្របជាទូទៅអំពីការគាត់ តែងកម្មវិធី និងលទ្ធភាពអនុវត្តរបស់កម្មវិធី។ | ២០១៦ - ២០១៨ | - ក្រ.សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រ. អ.យ.ក.<br>- **គ.ជ.យ.** |

| យុទ្ធសាស្ត្រ | សកម្មភាពគោល | សកម្មភាពរង | សូចនាករ | ពេលវេលាកំណត់ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| | | កំណត់ពីតម្រូវការ ចំណាប់អារម្មណ៍ បំណងប្រាថ្នា និងសមត្ថភាពរបស់អង្គការយុវជននៅតាមសហគមន៍ពាក់ព័ន្ធនឹងកម្មវិធីបែបនេះ។<br>២. រៀបចំឯកសារកម្មវិធីពិភាក្សាជាមួយក្រសួង និងអង្គការពាក់ព័ន្ធដទៃទៀត រួមទាំងទីភ្នាក់ងារម្ចាស់ជំនួយ។<br>៣. ធ្វើផែនការការងារដើម្បីអនុវត្តកម្មវិធីដែលបានស្នើ។ | ៤. ការអនុវត្តកម្មវិធីសាកល្បង។ | | |
| | ៣.៦.៣- ការសម្របសម្រួល និងការអភិវឌ្ឍអង្គភាពជាមួយកាយរឹទ្ធិកម្ពុជា | ១. ជំនួយបច្ចេកទេសនៅក្នុងការអភិវឌ្ឍអង្គភាពដើម្បីអភិវឌ្ឍផែនការយុទ្ធសាស្ត្រនិងកិច្ចព្រមព្រៀងលើការគាំទ្រ។<br>២. ការប្តេជ្ញាចិត្តនិងការរួមចំណែកពីសំណាក់អ្នកពាក់ព័ន្ធដើម្បីអភិវឌ្ឍផែនការយុទ្ធសាស្ត្រ។<br>៣.រៀបចំកិច្ចប្រជុំ ការពិគ្រោះយោបល់ជាមួយ សមាជិកកាយរឹទ្ធិនិងសិក្ខាសាលា។ | ១. ការចូលរួមរបស់អ្នកពាក់ព័ន្ធនិងក្រសួងអយក/អគ្គលេខាធិការដ្ឋាន **គ.ជ.យ.** ។<br>២. ការពិគ្រោះយោបល់ កិច្ចប្រជុំ និងសិក្ខា-សាលា។<br>៣. ការផលិតផែនការយុទ្ធសាស្ត្រ និងកិច្ចព្រមព្រៀងលើការគាំទ្ររវាងរាជរដ្ឋាភិបាលកម្ពុជា និងកាយរឹទ្ធិកម្ពុជា។ | ២០១៦ - ២០១៨ | - ផ្នែកអនុវត្តគោលនយោបាយនៃ **គ.ជ.យ.** |

## ៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត

ផ្នែកនេះពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៥.១នៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា៖ អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការដែលមានយុទ្ធសាស្ត្ររងចំនួនបីគ្រប់ដណ្តប់លើឯកសារទាំងមូលពិសេស ផ្នែកទី៣ដែលស្តីពីផែនការសកម្មភាព។

## ៥- គម្រោងចំណាយ

ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ឆ្នាំ២០១៦-២០១៨នេះ ត្រូវប្រើប្រាស់ថវិកាជាតិ តាមរយៈក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលត្រូវគ្រោងថវិកានៅក្នុងកញ្ចប់ថវិការបស់សាមីក្រសួង ស្ថាប័ននីមួយៗ និងថវិកាដែលបានមកពីដៃគូអភិវឌ្ឍ ផ្នែកឯកជន សង្គមស៊ីវិល និងសប្បុរសជន។

## ៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា នឹងធានាយ៉ាងណាឱ្យគោលនយោបាយនេះអាចបំពេញបានតាមគោលបំណងរបស់ខ្លួន និងសម្រេចបាននូវលទ្ធផលរំពឹងទុក។ លើសពីនេះ ការកំណត់ការទទួលខុសត្រូវក្នុងការគ្រប់គ្រង ការតាមដាន និងរបាយការណ៍ ព្រមទាំងការសិក្សាស្រាវជ្រាវ ត្រូវបានចាត់ទុកជាអាទិភាពខ្ពស់។ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជន និងក្រុមប្រឹក្សាជាតិដើម្បីអភិវឌ្ឍយុវជន ត្រូវរៀបចំប្រព័ន្ធ ឬយន្តការពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធី និងសកម្មភាពអភិវឌ្ឍយុវជនតាមវិស័យរៀងៗខ្លួន។

### *៦.១- ការពិនិត្យផលប៉ះពាល់*

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានឹងត្រូវពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិក្នុងឆ្នាំ២០១៧ និងពិនិត្យឡើងវិញចុងក្រោយឆ្នាំ២០១៨ ដើម្បីវាយតម្លៃផលប៉ះពាល់នៃការអនុវត្តទាំងមូល។ ការវាយតម្លៃពាក់កណ្តាលអាណត្តិនិងចុងក្រោយនឹងធ្វើឡើង តាមរយៈរបាយការណ៍វាយតម្លៃឯករាជ្យ។ ការពិនិត្យឡើងវិញត្រូវគ្រប់គ្រងដោយ **ក.ជ.យ.** ដែលត្រូវពិនិត្យឡើងវិញនូវហេតុផលនៃគុណភាព និងប្រសិទ្ធភាពរបស់យុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាព។

### *៦.២- ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពជាតិ*

ការប្រជុំបូកសរុបលទ្ធផលការងារពាក់កណ្តាលឆ្នាំ និងការប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំនឹងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០១៦ដល់២០១៨ ក្នុងគោលបំណងពិនិត្យវឌ្ឍនភាពសូចនាករលទ្ធផលដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនីមួយៗ។ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំរបាយការណ៍លទ្ធផលតាមយុទ្ធសាស្ត្រ និងកម្មវិធីនីមួយៗជូន **ក.ជ.យ.** ដើម្បីបូកសរុប និងរៀបចំការប្រជុំត្រួតពិនិត្យលទ្ធផលរួមគ្នាមុននឹងរាយការណ៍អំពីវឌ្ឍនភាពជូនរាជរដ្ឋាភិបាល និងប្រធានក្រុមប្រឹក្សាជាតិ។

### *៦.៣- ការពិនិត្យតាមដានការអនុវត្តកម្មវិធីនិងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍយុវជនតាមវិស័យ*

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដើម្បីវាយតម្លៃផលប៉ះពាល់នៃកម្មវិធី ឬយុទ្ធសាស្ត្រនីមួយៗតាមវិស័យ និងពិនិត្យតាមដានការអនុវត្តការអភិវឌ្ឍយុវជននៅថ្នាក់ក្រសួង ស្ថាប័ន ថ្នាក់ក្រោមជាតិ និងថ្នាក់សេវាផ្ទាល់។ ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃតាមវិស័យត្រូវផ្សារភ្ជាប់ជាមួយផែនការនៃការចុះពិនិត្យតាមដាន ការផ្តល់និងបញ្ជូនរបាយការណ៍ ព្រមទាំងទម្រង់ពាក់ព័ន្ធនៃសកម្មភាពចុះពិនិត្យតាមដានលើលទ្ធផលនៃសេវានីមួយៗ។

អគ្គលេខាធិការដ្ឋាននៃ **ក.ជ.យ.** ត្រូវសម្របសម្រួលយន្តការនៃការពិនិត្យតាមដាន និងវាយតម្លៃតាមវិស័យនីមួយៗ ព្រមទាំងសម្របសម្រួលក្នុងការប្រមូលរបាយការណ៍លទ្ធផលអនុវត្តកម្មវិធីការអភិវឌ្ឍយុវជនកម្ពុជាទាំងអស់ និងរបាយការណ៍នៃការពិនិត្យតាមដាននិងវាយតម្លៃតាមវិស័យ ជាពិសេសសម្របសម្រួលការរៀបចំរាល់ការប្រជុំពិនិត្យលទ្ធផលនិងពិនិត្យផលប៉ះពាល់ក្នុងការអនុវត្តផែនការសកម្មភាពជាតិ និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។

លើសពីនេះទៅទៀត កម្មវិធីអភិវឌ្ឍយុវជនដែលគាំទ្រដោយដៃគូអភិវឌ្ឍ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន នឹងត្រូវបានពិនិត្យនិងវាយតម្លៃដោយ **ក.ជ.យ.**។ បទពិសោធទទួលបានពីអន្តរាគមន៍ទាំងនោះគួរត្រូវបានចងក្រងជាឯកសារត្រឹមត្រូវ និងបានពិនិត្យនៅ ក្នុងលក្ខខណ្ឌនៃផលប៉ះពាល់ប្រសិទ្ធភាពក្នុងការសម្របសម្រួលអន្តរវិស័យ ប្រសិទ្ធភាពចំណាយ និងការកំណត់

## ៧. សេចក្តីសន្និដ្ឋាន

ភាពជោគជ័យក្នុងការអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជន គឺជាទំនួលខុសត្រូវរបស់សង្គមទាំងមូល។ គោលនយោបាយជាតិនិងផែនការសកម្មភាពជាតិនេះជាតំណាងឱ្យចំណុចចាប់ផ្តើមនៃទស្សនវិស័យដែលមានគោលការណ៍ច្បាស់លាស់ មានសមាហរណកម្ម និងមានលក្ខណៈសម្របសម្រួល ដើម្បីឈានឆ្ពោះទៅរកការអភិវឌ្ឍយុវជនកម្ពុជា។

ការអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលអាចសម្រេចទៅបាន ប្រសិនបើវិស័យទាំងអស់របស់សង្គមទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍយុវជន និងយល់ដឹងពីតួនាទីរបស់ពួកគេ ក្នុងការរួមចំណែកអភិវឌ្ឍយុវជន។

មាត្រដ្ឋាននៃចំណាយច្បាស់លាស់ ដើម្បីឱ្យរាជរដ្ឋាភិបាល ក៏ដូចជា **គ.ជ.យ.** អាចពង្រីកសេវាអភិវឌ្ឍយុវជនកម្ពុជាស្របតាមលទ្ធភាពនិងសមត្ថភាពរបស់ខ្លួន។

### ៦.៤- ការរៀបចំឯកសារឧបសម្ព័ន្ធផែនការសកម្មភាពជាតិ

សូចនាករនិងចំណុចដៅលម្អិតតាមឆ្នាំនីមួយៗ ផែនការថវិកាលម្អិតតាមយុទ្ធសាស្ត្រ និងការកំណត់សកម្មភាពជាអាទិភាពតាមវិស័យពាក់ព័ន្ធ (ដូចក្នុងឧបសម្ព័ន្ធភ្ជាប់) នឹងក្លាយជាឧបករណ៍សម្រាប់ធ្វើការតាមដានលទ្ធផលដែលបានអនុវត្ត និងសម្រាប់វិភាគក្នុងការរៀបចំផែនការបន្ត ឬផែនការលម្អិតតាមឆ្នាំនីមួយៗក្នុងវិស័យពាក់ព័ន្ធ។

| ប្រភេទនៃការពិនិត្យតាមដាន | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|
| ១- ការពិនិត្យឡើងវិញចុងអាណត្តិ | ២០១៨ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន |
| ២- វឌ្ឍនភាពនៃការអភិវឌ្ឍយុវជនតាមវិស័យ | ២ដងក្នុង១ឆ្នាំ | អគ្គលេខាធិការដ្ឋាន **គ.ជ.យ.** |
| ៣- វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ | ៤ដងក្នុង១ឆ្នាំ | អគ្គលេខាធិការដ្ឋាន **គ.ជ.យ.** |